# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣១ លេខ ៤ ខែមេសា

ព.ស. ២៥០១ គ.ស. ១៩៥៩

ភ្នំពេញ

A 168

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា　　　　បញ្ជីរឿង　　　　ទំព័រ

- តុទ្ទកថា របស់ព្រះបាឡាត់បទុមវង្ស ហ៊ុង-កេង . . . . . . . . ៣៥៩
- រឿងសត្វតាប និងដំរីស្ដ លោក ប៊ូ-ប៊ូ រៀបរៀង. . . . . . . . . ៣៦៨
- សុរពជាតក ( តមក ) លោក ជីង-វង ចម្លងពីសាស្ត្រស្លឹករឹត . . . ៣៧៣

ផ្នែកអក្សរសាស្ត្រ

- អក្សរសាស្ត្រខ្មែរក្រោយសម័យអង្គរ លោក ស៊ិន-ហ៊ាន រៀបរៀង . . . . ៣៩៧
- រឿងសព្វសិទ្ធិ របស់ហ្លួនភក្ដីអក្សរ គង់ លោក ប៊ូ-ប៊ូ ចំលងពីសាស្ត្រស្លឹករឹត . ៤០៤
- រឿងកេង្សយន្ត លោក អ៊ឹម-ភន ចម្លងពីសាស្ត្រស្លឹករឹត. . . . . . . ៤៣១
- សុភាសិតភាគិ ប្អូន បិន លោក ភ័យ-ប៊ុក ដកស្រង់រៀបរៀង . . . . ៤៤៧
- ពិធីបុណ្យចូលឆ្នាំថ្មី លោក ស្រី-អ៊ូ រៀបរៀង . . . . . . . . . . ៤៥១
- រឿងសាមទុក (តមក) ឧកញ៉ា នូ-កន ប្រែ . . . . . . . . . ៤៥៥

ផ្នែកកំណត់និងប្រវត្តិការណ៍

- គណៈប្រតិភូខ្មែរខាងសាសនា ទៅរួមក្នុងពិធីបុណ្យពុទ្ធជយន្តីនៅប្រទេសជប៉ុន . ៤៧២
- វចនានុក្រមសំស្ក្រឹត-ខ្មែរ ( តមក ) ព្រះមហា ជាំង-ខាត់ រៀបរៀង. . . . ៤៧៦

មួយឆ្នាំមាន ១២ សៀវភៅ តំឡៃជារៀល ២៣០.០០

# KAMBUJASURIYA

Revue religieuse et litteraire
éditée par l'Institut Bouddhique

## sommaire

### Partie religieuse :

-Sukhakatha par le Vén. HING-KENG . . . . . . . . 359
-Légende du moineau et de l'éléphant par M. BOU-PO . . . 368
-Surabajataka ( suite ) relevé du manuscrit sur
feuilles de latanier par M. THANG - VONG . . . 373

### Partie littéraire :

-La littérature Khmère après l'époque angkorienne par SIN-HEAN 297
-Histoire de Sabbasiddhi ( suite ) par Phakdei Aksar TAN revue
et corrigée par M. BOU-PO . . . . . . . . . 404
-Histoire de Hang-Yon relevée du manuscrit sur feuilles de
latanier par M. IM-PHON . . . , . . . : . 431
-Proverbes chinois et vietnamiens traduits par M. RAY-BUC . 447
-La fête du Nouvel An par SREY-OU . . . . . . . . 451
-Histoire de Sam Kok (suite) par l'oknha NOU-KAN . . . 455

### Notes et Chroniques :

-Délégation cambodgienne au Bouddha Jayanti du Japon . . 472
-Dictionnaire Sanskrit-Khmer (suite) par vén. PANG-KHAT . . 476

Prix d'abonnement annuel (comprenant 12 numéros): 230$00 .

ផ្នែកសាសនា

# សុខភាព

## ពណ៌នាអំពី សេចក្ដីសុខ ពីរប្រការ

របស់ព្រះ ជ.ឡាត់ បទុមវង្ស ហ៊ឹង.កេង វត្តបទុមវតីរាជវរារាម

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៗ

សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ៗ

លំដាប់តទៅនេះ អាត្មាភាពនឹងសំដែងអំពីសុខគាថាដែលមានមក ក្នុងគម្ពីរទុកនិបាត អង្គុត្តរនិកាយ ពណ៌នាអំពីសេចក្ដីសុខ ២ ប្រការ ដូចមានបាលីថា ទ្វេមានិ ភិក្ខវេ សុខានិ កតមានិ ទ្វេ សាមិសញ្ច សុខំ និរាមិសញ្ច សុខំ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានីតិ ដូច្នេះ ដើម្បីឲ្យសម្រេចប្រយោជន៍ ដល់សាធុជនដែលប្រាថ្នាធម៌ តាមសមគួរដល់ពេលវេលា ដូចមានសេចក្ដីអធិប្បាយ ដោយសង្ខេបតទៅនេះ ៖

បណ្ដាមនុស្សសត្វទាំងអស់ ដែលកើតមកក្នុងលោកនេះ មានច្រើនបែប ច្រើនប្រភេទផ្សេងៗ គ្នា ដោយជាតិខ្លះ ដោយភាសាខ្លះ ដោយវង្សត្រកូលខ្លះ បើទុកជាច្រើនដូច្នោះក៏ដោយ តែគង់មានការ

ប្រាថ្នាសេចក្តីសុខដូចៗគ្នាទាំងអស់ មិនមានអ្នកណាមួយត្រូវការប្រាថ្នាសេចក្តីទុក្ខឡើយ ស្មើពាក្យថា ទុក្ខក៏មិនចង់ឮផង សមដូចសុភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយថា សុខកាមានិ ភូតានិ "សត្វទាំងឡាយ ជាអ្នកប្រាថ្នាសេចក្តីសុខគ្រប់ៗគ្នា" ។

ហេតុដូច្នោះ បានជាសត្វទាំងឡាយ តែងនាំគ្នាស្វែងរកសេចក្តីសុខតែសត្វៗខ្លួន តែការដែលបានផលនៃសេចក្តីសុខនោះមិនដូចគ្នាទេ សត្វខ្លះក៏បានយ៉ាងដ៏ខ្ពណាយទៅ សត្វខ្លះក៏បានយ៉ាងកណ្តាល សត្វខ្លះក៏បានយ៉ាងស្តួចស្តើង សត្វខ្លះត្រឡប់ជាបានទុក្ខទៅវិញក៏មាន ។ ដូច្នេះឃើញថា ការដែលបានសេចក្តីសុខក្តីទុក្ខក្តី ក៏មិនមែនកើតឡើងដោយហេតុដទៃ ក្រៅចាកការធ្វើការប្រកបរបស់ខ្លួននោះទេ ។ សេចក្តីសុខ-ទុក្ខនេះ ជាធម៌មាននៅប្រចាំគតិធម្មតា អ្នកណាធ្វើក៏ជារបស់អ្នកនោះនឹងផ្លាស់ប្តូរចែករំលែកឲ្យគ្នាមិនបាន ហើយជាធម៌រេចឲ្យផលផ្លាស់ប្តូរវេនគ្នាម្តងម្នាក់ គឺជួនកាលក៏សុខ ជួនកាលក៏ទុក្ខ ។ ក្នុងពេលណាដែលបានសោយសុខជាផលហើយ បន្ទាប់ពីនោះ គង់បានសោយទុក្ខពុំខាន ។ ហេតុនេះ អ្នកប្រាថ្នាសេចក្តីសុខ ទើបត្រូវលះសេចក្តីអាក្រក់ចេញ ខំប្រព្រឹត្តសេចក្តីល្អឡើង ។ ឯសេចក្តីល្អបើបុគ្គលធ្វើបន្តិចបន្តួច ផលនៃសេចក្តីសុខ ក៏បានបន្តិចបន្តួច នឹងប្រាថ្នាឲ្យបានសុខវិសេសឡើងទៅនោះមិនបាន បើធ្វើច្រើនក៏បានច្រើន ។ សេចក្តីសុខ

នេះ ហើយទើបត្រឹមថ្នាក់ណាជាន់ណា ក៏បានត្រឹមថ្នាក់នោះជាន់នោះដែរ តែថា សេចក្ដីសុខចំពួកខ្លះ ឲ្យផលបានត្រឹមមួយគ្រា ៗ មិនឋិតថេរថាវរៈឡើយ សេចក្ដីសុខចំពួកខ្លះ បរិសុទ្ធស្អាត តាំងនៅអស់កាលដ៏យូរ មិនត្រឡប់កើតសេចក្ដីក្ដៅក្រហាយវិញ ៗ សម្ដេចព្រះពុទ្ធអង្គទ្រង់សំដែងថា សេចក្ដីសុខណា មិនបរិសុទ្ធ អាចត្រឡប់បានទុក្ខវិញ សេចក្ដីសុខនោះហៅថា សាមិសសុខ គឺសុខនៅប្រឡំដោយអាមិសគ្រឿងជន្ទួចិត្ត ៗ សេចក្ដីសុខឯណាដែលបរិសុទ្ធស្អាត មិនត្រឡប់បានទុក្ខវិញ សេចក្ដីសុខនោះឯង ហៅថា និរាមិសសុខ ជាសុខប្រាសចាកអាមិសគ្រឿងជន្ទួចិត្ត ដូចពុទ្ធភាសិត ដែលបាននិពន្ធទុកខាងដើមថា ទ្វេមានិ ភិក្ខវេ សុខានិ ដូច្នេះជាដើម សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខមាន ២ ប្រការ ពីរប្រការនោះដូចម្ដេច? គឺសាមិសសុខ ១ និរាមិសសុខ ១ ម្នាលភិក្ខុទាំងឡាយ សេចក្ដីសុខមាន ២ ប្រការដូច្នេះឯង ៗ

ពាក្យថា សុខ នេះ បានដល់អាការដែលសប្បាយកាយ សប្បាយចិត្ត កើតឡើងព្រោះការស្រេចបានបំពេញហេតុ ដែលសមគួរល្មមល្មម ដូចពនឹកាយបានទទួលសេចក្ដីក្ដៅក្រហល់ក្រហាយ លុះបានមុជទឹកជម្រះកាយ ក៏កើតសេចក្ដីត្រជាក់ជាសុខបាន ឬពនឹកាយស្រេកឃ្លាន កើតសេចក្ដីពេលពលរសាប់រសល់ លុះបានបរិភោគអាហារឆ្អែតស្កប់ស្កល់ ក៏ជាសុខ

បានមួយគ្រាមួយស្របក់ • ឬក៏សេចក្ដីល្មោភក្រោធវង្វេង កើតឡើង ធ្វើចិត្តឲ្យក្ដៅអន្ទះអន្ទែង កាលបើបានរម្ងាប់សេចក្ដីល្មោភ-ក្រោធ-វង្វេងបានហើយ ក៏ជាសុខដូច្នេះជាដើម តែសេចក្ដីសុខត្រឹមថ្នាក់ណាជាន់ណា ក៏ស្រេចហើយតែហេតុដែលខ្លួនបានបំពេញ ៗ បើហេតុនោះ ជាចំណែករូប-ក្លិន-រស-ផោដ្ឋព្វៈ-ធម្មារម្មណ៍ក្ដី ឬ សុខដែលកើតអំពីលាភ-យស-សរសើរ កើតអំពីការងារដែលធ្វើដោយបំណង ប្រយោជន៍ដ៏គាប់ចិត្ត ដូចប្រាថ្នាផលបំណាញហើយបរិច្ចាគទាន រក្សាសីល ជាដើមក្ដី ទាំងអម្បាលនេះជាសាមិសសុខ គឺ សេចក្ដីសុខដែលអែបអាស្រ័យអាមិសគ្រឿងជន្ទចិត្ត ៗ អ្នកដែលបានសាមិសសុខនោះ លោកប្រដៅឲ្យដឹងថាប្រហែលគ្នានឹងអេះរមាស់ បានស្រួលគន់ វេលាអេះមួយគ្រាមួយខណៈប៉ុណ្ណោះ ក្រៅពីនោះ លោកឲ្យពិចារណាប្រៀបធៀបនឹងអ្នកផឹកទឹកស្រវឹងលឹងធ្វើឲ្យជាប់ចិត្ត ហើយសប្បាយក្នុងវេលានោះ តែតមក ទើបកើតឡើងជាទោស ឬ ប្រៀបដូចត្រីដែលឃើញនុយត្រង់ចុងសន្ទូច ក៏ត្របាក់យក ហើយទើបគេងស្លាប់ខ្លួន ដោយនុយនោះ ៗ សេចក្ដីសុខ ដែលជាហេតុឲ្យប្រទូសរ៉ាយដល់ខ្លួន មានការតុះតាវក្ដៅក្រហាយចិត្តជាខាងក្រោយ ដូច្នេះ ហៅថា សាមិសសុខ គឺសុខដែលជាហេតុឲ្យពេញចិត្ត តែខាងក្រោយមកមានទុក្ខជាផល ៗ ដូចមនុស្សបរិភោគរបស់ដែល

ស្វែងនឹងភោគ  បានសេចក្ដីគាប់ចិត្តក្នុងពេលដែលបរិភោគ  តែភោគ ត្រឡប់ជាវេទនាវិញដូច្នោះ ។

សេចក្ដីសុខ ដែលតែងអាស្រ័យអាមិសជាគ្រឿងជន្ទ ធ្វើឲ្យសត្វ ជាប់ចិត្តជិតនៅ ក្នុងអំណាចក្រោ អ្នកដែលមានបញ្ញា នឹងអាចគេចវេះជម្លោះ ខ្លួនឲ្យរួតផុតចេញទៅបាន ព្រោះសេចក្ដីសុខបែបនេះ ជាសេចក្ដីសុខ ដែលកើតឡើងតែត្រួតត្រាចិត្ត ទុកឲ្យទៅក្នុងអំណាចនៃកិលេសតែម្យ៉ាង ៗ ដូច្នេះ ក្នុងផ្លូវព្រះពុទ្ធសាសនា លោកទើបប្រដៅឲ្យពិចារណាឲ្យឃើញ ច្បាស់ថា សេចក្ដីសុខក្នុងជាន់នេះមិនទៀង មិនមាំមួនថាវរៈប៉ុន្មានគ្រាន់ តែអាស្រ័យមួយគ្រាមួយខណៈប៉ុណ្ណោះ ដូចមនុស្សដែលនៅក្នុងមហា សមុទ្រ គេនឹងអាស្រ័យសំពៅ លុះដល់កំពង់ជាទីត្រាណ ថ្នាលស្រួលហើយ ក៏ឡើងទៅកាន់ច្រាំង មិនអាឡោះអាល័យក្ដីការនៅក្នុងសំពៅនោះ ទៀត ។ មនុស្សទាំងឡាយដែលនៅក្នុងលោក គេនឹងអាស្រ័យសេចក្ដី សុខដែលជាចំណែកលោកគ្រប់យ៉ាងគ្រប់ប្រការ តែត្រូវមានបញ្ញាចេះ ពិចារណាឲ្យឃើញតាមសភាវៈពិតថា គ្រាន់តែជាសាមិសសុខ ជា សុខអាស្រ័យមួយពេលមួយគ្រាប៉ុណ្ណោះ ទីនឹងជាសុខមានអាការកើត ឡើងហើយត្រូវរលត់ទៅវិញជាធម្មតា មិនឋិតថេរថាវរៈ តាំងមាន សេចក្ដីទុក្ខជាផល ។

ហេតុនេះ ពុទ្ធបរិស័ទទាំងឡាយ កាលបើប្រាប់ដូច្នោះហើយ គួរស្វែង

រកសេចក្ដីសុខដែលប្រណីតល្អិតលើសឡើងទៅទៀត តាមសមគួរដល់ឱកាស និងសេចក្ដីព្យាយាមរបស់ខ្លួន មិនគួរពេញចិត្តតែក្នុងសេចក្ដីសុខដែលនៅប្រឡូកដោយអាមិសគ្រឿងរឹតរួតចិត្ត ឲ្យជាប់នៅក្នុងអំណាចរបស់កិលេសគ្រប់ពេលវេលាឡើយ គួរណាស់ហើយតែបំពេញខវត្តបដិបត្តិឲ្យជាកំលាំងខាងក្នុង ដើម្បីជាបច្ច័យឲ្យបានជួបប្រទះនឹងនិរាមិសសុខក្នុងកាលជាទីបំផុត ។ ឯនិរាមិសសុខនោះបានដល់សេចក្ដីសុខ ដែលប្រាសចាកអាមិសគ្រឿងជន្ទួចិត្ត ។ ក៏សេចក្ដីសុខនេះទៀតសោត នឹងកើតឡើងបាន ក៏ព្រោះអាស្រ័យហេតុនៃការប្រកប ។ ឯហេតុដែលឲ្យកើតនិរាមិសសុខនោះ បានដល់វិវេកសេចក្ដីស្ងប់ស្ងាត់ ៣ ប្រការគឺ កាយវិវេកស្ងាត់កាយ បានដល់បុគ្គលដែលមានកាយស្ងប់ស្ងាត់ ត្រេកអរក្នុងនេក្ខម្ម: លះបង់ចោលពួកគណ: ហើយប្រព្រឹត្តទៅតែម្នាក់ឯង ១ ចិត្តវិវេក ស្ងាត់ចិត្ត បានដល់បុគ្គលដែលមានចិត្តបរិសុទ្ធផូរផង់ លះបង់ចោលនូវកិលេស ដោយអំណាចសមាបត្តិ ៨ ជាអ្នកមានចិត្តថ្លាស្អាតជ្រះស្រឡះចាកគ្រឿងរំខាន ១, ឧបធិវិវេក បានដល់បុគ្គលដែលមិនមានកិលេស មិនមានសង្ខារ គឺជាអ្នកបានធ្វើចិត្តឲ្យស្ងាត់ចាកកិលេសទាំងឡាយ ដោយប្រើបញ្ញាពិនិត្យ ពិចារណាឲ្យឃើញច្បាស់ ដឹងច្បាស់ក្នុងរឿងសង្ខារ ផុតបទាល់តែចិត្តលែងជាប់ប្រកាន់មាំ ក្នុងសង្ខារដោយអំណាចតណ្ហា-ឧបាទាន ១ ។ សេចក្ដីស្ងប់ស្ងាត់ទាំង៣ប្រការនេះ

សុទ្ធតែជាគ្រឿងបំពេញបំពូនបញ្ញាឱ្យកើតសេចក្ដីសុខដ៏ឧត្ដមលើសលុបឡើងៈទៅទាំងអស់ ។ សេចក្ដីសុខដែលកើតអំពីចិត្តវិវេក និងឧបធិវិវេកទាំង២ នេះ ចាត់ជានិរាមិសសុខ ជាសុខមិនប្រឡូកដោយអាមិសគ្រឿងជំពាក់ចិត្ត គឺជាសេចក្ដីសុខថ្លាស្អាតបរិសុទ្ធ នឹងនួនមិនប្រែប្រួល ។

និរាមិសសុខនេះឯង ជាសុខពិតប្រាកដ មិនអែបអាស្រ័យអាមិសគ្រឿងធ្វើចិត្តឱ្យវង្វេងវង្វាន់ ជាប់ពន្ធនាការកិលេស ជាសន្តិសុខ គឺសុខដែលកើតអំពីសេចក្ដីស្ងប់ចិត្ត ដែលមានរស-មានអាការមាំទាំជាងសុខទាំង-ឡាយទាំងពួង សមដូចសុភាសិតថា: នត្ថិ សន្តិបរំ សុខំ សេចក្ដីសុខដទៃក្រៅពីសេចក្ដីស្ងប់មិនមាន ។

សាធុជន បពិត្រសប្បុរសទាំងឡាយ កាលបើបានជ្រាបសេចក្ដីសុខទាំង២ប្រការ ព្រមទាំងហេតុប្បច្ច័យច្បាស់លាស់ ដោយន័យដូច្នេះហើយគួរព្យាយាមស្វែងរកសេចក្ដីសុខទាំងពីរប្រការនោះ ឱ្យកើតមានឡើងក្នុងខ្លួន សូម្បីជាចំណែកសាមិសសុខ ក៏គួរស្វែងរកបំពេញឡើងទុកឱ្យបរិបូណ៌ តែមិនត្រូវភ្លេចខ្លួនទេ ត្រូវមានបញ្ញាជាគ្រឿងពិចារណាផង កុំបណ្ដោយឱ្យចិត្តជាប់ជំពាក់ស្រវឹងវង្វេង ត្រូវដឹងថា សាមិសសុខនេះមិនឋិតថេរជាររៈមាំមួនទេ ជាសុខដែលកើតឡើងមួយពេលមួយខណៈ តោងផ្លាស់ប្ដូរប្រែប្រួលទៅវិញ តាមសភាវៈធម្មតា ដូចបុគ្គលដែលអេះមោស់ជាដើមសុទ្ធតែមានសេចក្ដីទុក្ខប្រចាំនៅខាងមុខជានិច្ច ឬដូចសេចក្ដីសុខដែលកើត

អំពីមានទ្រព្យ ដែលជាទីប្រាថ្នារបស់បុថុជ្ជនគ្រប់គ្នា តែទ្រព្យនោះក៏ពុំបានឲ្យកើតសេចក្ដីសុខពិត ៗ ទេ វេលាបានមកក៏ត្រេកអរ តែអានសេចក្ដីទុក្ខនៅអមផង ចាប់តាំងអំពីការប្រើប្រាស់ទុកដាក់ថែរក្សាជាដើមទៅ បើប្រើខុសទំនងក៏រឹតតែកើតជាទោស មានសេចក្ដីពុះពោរ ក្ដៅក្រហាយចិត្តជាផល ៗ ដូច្នេះ សាធុជនពុទ្ធបរិស័ទទាំងឡាយ គួរប្រញាប់ចាប់យកប្រយោជន៍អំពីរបស់ទាំងអម្បាលនេះ ឲ្យសមតាមទំនង ដូចការខ្ចីរបស់អ្នកដទៃមកប្រើ ត្រូវប្រញាប់ប្រើឲ្យបានសំរេចប្រយោជន៍ សមតាមប្រាថ្នា ហើយជូនត្រឡប់ទៅឲ្យគេវិញ ដោយមិនមានអាល័យ ៗ ឬដូចជាសត្វហង្ស ដែលចុះស៊ីចំណីក្នុងភក់ ឆ្អែតហើយក៏ហើរទៅ មិនធ្វើសេចក្ដីអាល័យជាប់នៅក្នុងទីនោះ; លំដាប់តមក គួរស្វែងរកនិរាមិសសុខ ដែលជាសុខកើតអំពីការបដិបត្តិផ្លូវចិត្តខាងក្នុង ដោយបំពេញវិវេក គឺសេចក្ដីស្ងាត់ ៣ ប្រការឲ្យបរិបូណ៌ លុះវិវេកទាំង៣ ប្រការកើតឡើងហើយ រមែងជាគ្រឿងកំចាត់ផុសលាងសេចក្ដីសៅហ្មងក្នុងចិត្ត ឲ្យអស់ទៅដោយអំណាចវិវេកនោះ ៗ ជាចិត្តដល់នូវសេចក្ដីផូរផង់ សុខដែលជាផលក៏កើតឡើងជាកំឡាំងខាងក្នុង ឈ្មោះថា បានក្រេបផឹកនូវរសនៃនិរាមិសសុខ ជាសុខមិនប្រែប្រួល គោលគឺព្រះនិព្វាន សមដូចពុទ្ធភាសិតថា និព្វានំ បរមំ សុខំ "ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង" ។

## ផ្នែកសាសនា

# សុខកថា

*ពណ៌នាអំពី សេចក្ដីសុខ ពីរប្រការ*

របស់ព្រះ បាឡាត់ បទុមវង្ស ហ៊ុង.កេង វត្តបទុមវតីរាជវរារាម

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ៚

*សូមនមស្ការ ចំពោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រះអង្គនោះ ព្រមទាំងព្រះធម៌ និងព្រះអរិយសង្ឃ ដោយសេចក្ដីគោរព ៗ*

*លំដាប់តទៅនេះ អាត្មាភាពនឹងសំដែងអំពីសុខកថាដែលមានមក ក្នុងគម្ពីរទុកនិបាត អង្គុត្តរនិកាយ ពណ៌នាអំពីសេចក្ដីសុខ ២ ប្រការ ដូចមានបាលីថា* ទ្វេមានិ ភិក្ខវេ សុខានិ កតមានិ ទ្វេ សាមិសញ្ច សុខំ និរាមិសញ្ច សុខំ ឥមានិ ខោ ភិក្ខវេ ទ្វេ សុខានីតិ *ដូច្នេះ ដើម្បីឲ្យសម្រេចប្រយោជន៍ ដល់សាធុជនដែលប្រាថ្នាធម៌ តាមសមគួរដល់ពេលវេលា ដូចមានសេចក្ដីអធិប្បាយ ដោយសង្ខេបតទៅនេះ ៖*

*បណ្ដាមនុស្សសត្វទាំងអស់ ដែលកើតមកក្នុងលោកនេះ មានច្រើនបែប ច្រើនប្រភេទផ្សេង ៗ គ្នា ដោយជាតិខ្លះ ដោយភាសាខ្លះ ដោយវង្សត្រកូលខ្លះ បើទុកជាច្រើនដូច្នោះក៏ដោយ តែតង់មានការ*

ប្រាថ្នាសេចក្ដីសុខដូចៗគ្នាទាំងអស់ មិនមានអ្នកណាមួយត្រូវការប្រាថ្នាសេចក្ដីទុក្ខឡើយ សូម្បីពាក្យថា ទុក្ខក៏មិនចង់ឮផង សមដូចសុភាសិតក្នុងគម្ពីរធម្មបទ ខុទ្ទកនិកាយថា សុខកាមានិ ភូតានិ "សត្វទាំងឡាយ ជាអ្នកប្រាថ្នាសេចក្ដីសុខគ្រប់ៗគ្នា" ។

ហេតុដូច្នោះ បានជាសត្វទាំងឡាយ តែងនាំគ្នាស្វែងរកសេចក្ដីសុខតែសត្វៗខ្លួន តែការដែលបានផលនៃសេចក្ដីសុខនោះមិនដូចគ្នាទេ សត្វខ្លះក៏បានយ៉ាងទូលំទូលាយទៅ សត្វខ្លះក៏បានយ៉ាងកណ្ដាល សត្វខ្លះក៏បានយ៉ាងស្តួចស្តើង សត្វខ្លះត្រឡប់ជាបានទុក្ខទៅវិញក៏មាន ។ ដូច្នេះឃើញថា ការដែលបានសេចក្ដីសុខក្ដីទុក្ខក្ដី ក៏មិនមែនកើតឡើងដោយហេតុដទៃ ក្រៅពីការធ្វើការប្រកបរបស់ខ្លួននោះទេ ។ សេចក្ដីសុខ-ទុក្ខនេះ ជាធម៌មាននៅប្រចាំគតិធម្មតា អ្នកណាធ្វើក៏ជារបស់អ្នកនោះនឹងផ្លាស់ប្ដូរចែករំលែកឲ្យគ្នាមិនបាន ហើយជាធម៌អាចឲ្យផលផ្លាស់ប្ដូរវេនតាមលំដាប់ គឺជួនកាលក៏សុខ ជួនកាលក៏ទុក្ខ ។ ក្នុងពេលណាដែលបានសោយសុខជាផលហើយ បន្ទាប់ពីនោះ គង់បានសោយទុក្ខពុំខាន ។ ហេតុនេះ អ្នកប្រាថ្នាសេចក្ដីសុខ ទើបគួរលះសេចក្ដីអាក្រក់ចេញ ខំប្រព្រឹត្តសេចក្ដីល្អឡើងៗ ឯសេចក្ដីល្អរបស់បុគ្គលធ្វើបន្តិចបន្តួច ផលនៃសេចក្ដីសុខ ក៏បានបន្តិចបន្តួច នឹងប្រាថ្នាឲ្យបានសុខវិសេសលើសនៅនោះមិនបាន បើធ្វើច្រើនក៏បានច្រើន ។ សេចក្ដីសុខ

នេះ យើងធ្វើត្រឹមថ្នាក់ណា ជាន់ណា ក៏បានត្រឹមថ្នាក់នោះជាន់នោះដែរ តែថា សេចក្តីសុខបំពួកនុះ ឲ្យផលបានត្រឹមមួយគ្រា ៗ មិនឋិតថេរថាវរៈឡើយ សេចក្តីសុខបំពួកនុះ បរិសុទ្ធស្អាត តាំងនៅអស់កាលដ៏យូរ មិនត្រឡប់កើតសេចក្តីក្តៅក្រហាយវិញ ៗ សម្តេចព្រះពុទ្ធអង្គទ្រង់សំដែងថា សេចក្តីសុខណា មិនបរិសុទ្ធ គាប់ត្រឡប់បានទុក្ខវិញ សេចក្តីសុខនោះហៅថា សាមិសសុខ គឺសុខនៅប្រឡំដោយអាមិសគ្រឿងជន្ទចិត្ត ៗ សេចក្តីសុខឯណាដែលបរិសុទ្ធស្អាត មិនត្រឡប់បានទុក្ខវិញ សេចក្តីសុខនោះឯង ហៅថា និរាមិសសុខ ជាសុខប្រាសចាកអាមិសគ្រឿងជន្ទចិត្ត ដូចពុទ្ធភាសិត ដែលបាននិពន្ធទុកខាងដើមថា នេក្ខម្មាធិ ភិក្ខវេ សុខាធិ ដូច្នេះជាដើម សេចក្តីថា ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខមាន ២ ប្រការ តើប្រការនោះដូចម្តេច? គឺសាមិសសុខ ១ និរាមិសសុខ ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីសុខមាន ២ ប្រការដូច្នេះឯង ៗ

ពាក្យថា សុខ គេបានដល់អាការដែលសប្បាយកាយ សប្បាយចិត្ត កើតឡើងព្រោះតែប្រយោជន៍បានពេញ ហេតុ ដែលសមគួរល្មមល្អ ដូចពេលកាយបានទទួលសេចក្តីក្តៅក្រហាយ លុះបានមុជទឹកដូច្នេះ កាយក៏កើតសេចក្តីត្រជាក់ជាសុខបាន ឬពេលកាយស្រេកឃ្លាន កើតសេចក្តីពេលពលសោយសេល់ លុះបានរិភោគអាហារឆ្អែតស្កប់ស្កល់ ក៏ជាសុខ

បានមួយគ្រាមួយស្របក់ ឬក៏សេចក្ដីលោភក្រោធវង្វេង កើតឡើង ធ្វើចិត្តឲ្យក្ដៅអន្ទះអន្ទែង កាលបើបានរម្ងាប់សេចក្ដីលោភ ក្រោធ វង្វេងបានហើយ ក៏ជាសុខដូច្នេះជាដើម តែសេចក្ដីសុខត្រឹមថ្នាក់ណាជាន់ណា ក៏ស្រេចហើយតែហេតុដែលខ្លួនបានបំពេញ ។ បើហេតុនោះ ជាចំណែករូប-ក្លិន-រស-ផោដ្ឋព្វៈ-ធម្មារម្មណ៍ក្ដី ឬ សុខដែលកើតអំពីលាភ-យស-សរសើរ កើតអំពីការងារដែលធ្វើដោយបំណង ប្រយោជន៍ដ៏គាប់ចិត្ត ដូចប្រាថ្នាផលចំណេញហើយបរិច្ចាគទាន រក្សាសីល ជាដើមក្ដី តាំងអម្បាលនេះជាសាមិសសុខ គឺ សេចក្ដីសុខដែលអែបអាស្រ័យអាមិសគ្រឿងជន្ទចិត្ត ។ អ្នកដែលបានសាមិសសុខនោះ លោកប្រដៅឲ្យដឹងថាប្រហែលគ្នានឹងអេះមាស់ បានស្រួលគង់វេលាអេះមួយគ្រាមួយខណៈប៉ុណ្ណោះ ក្រៅពីនោះ លោកឲ្យពិចារណាប្រៀបធៀបនឹងអ្នកផឹកទឹកស្រវឹងសឹងធ្វើឲ្យជាប់ចិត្ត ហើយសប្បាយគង់វេលានោះ តែតមក នឹងកើតឡើងជាទោស ឬ ប្រៀបដូចត្រីដែលឃើញនុយត្រង់ចុងសន្ទូច ក៏ត្របាក់យក ហើយនឹងគាំងស្លាប់ខ្លួន ដោយនុយនោះ ។ សេចក្ដីសុខ ដែលជាហេតុឲ្យប្រទូសរ៉ាយដល់ខ្លួន . មានការពុះពារក្ដៅក្រហាយចិត្តជាខាងក្រោយ ដូច្នេះ ហៅថា សាមិសសុខ គឺសុខដែលជាហេតុឲ្យពេញចិត្ត តែខាងក្រោយមកមានទុក្ខជាផល ។ ដូចមនុស្សបរិភោគរបស់ដែល

ស្វែងនឹងសេព បានសេចក្ដីគាប់ចិត្តក្នុងពេលដែលបរិភោគ តែពេល ត្រឡប់ជារំខានទៀតវិញដូច្នោះ ។

សេចក្ដីសុខ ដែលកើតអាស្រ័យកាមរសជាគ្រឿងជន្ទ ធ្វើឲ្យសត្វ ជាប់ចិត្តជំពាក់នៅ ក្នុងអំណាចគេ អ្នកដែលមានបញ្ញា ទើបអាចគេចវេះដោះ ខ្លួនឲ្យរួចផុតចេញទៅបាន ព្រោះសេចក្ដីសុខបែបនេះ ជាសេចក្ដីសុខ ដែលធ្វើឲ្យតែតណ្ហាពន្ធចិត្ត ទុកឲ្យនៅក្នុងអំណាចនៃកិលេសតែម្យ៉ាង ។ ដូច្នេះ ក្នុងផ្លូវព្រះពុទ្ធសាសនា លោកទើបប្រដៅឲ្យពិចារណាឲ្យឃើញ ច្បាស់ថា សេចក្ដីសុខក្នុងជាន់នេះមិនទៀង មិនមាំមួនថាវរៈប៉ុន្មានគ្រាន់ តែអាស្រ័យមួយគ្រាមួយខណៈប៉ុណ្ណោះ ដូចមនុស្សដែលទៅក្នុងមហា សមុទ្រ គេតែងអាស្រ័យសំពៅ លុះដល់កំពង់ជាទីប្រាថ្នារបស់ខ្លួនហើយ ក៏ឡើងទៅកាន់ច្រាំង មិនអាឡោះអាល័យគេក្ដីការនៅក្នុងសំពៅនោះ ទៀត ។ មនុស្សទាំងឡាយដែលនៅក្នុងលោក តែងអាស្រ័យសេចក្ដី សុខដែលជាចំណែកលោកគ្រប់យ៉ាងគ្រប់ប្រការ តែត្រូវមានបញ្ញាចេះ ពិចារណាឲ្យឃើញតាមសភាវៈពិតថា ខ្លះគ្រាន់តែជាសាមិសសុខ ជា សុខអាស្រ័យមួយពេលមួយគ្រាប៉ុណ្ណោះ ទីផុតសុខមានសភាពកើត ទៀតហើយត្រូវរលត់ទៅវិញជាធម្មតា មិនឋិតថេរថាវរៈ ទាំងមាន សេចក្ដីទុក្ខជាផល ។

ហេតុនេះ ពុទ្ធបរិស័ទទាំងឡាយ កាលបើជ្រាបដូច្នោះហើយ គួរស្វែង

រកសេចក្តីសុខដែលប្រណីតល្អិតលើសឡើងទៅទៀត  តាមសមគួរដល់ឱកាស  ទីរសេចក្តីព្យាយាមរបស់ខ្លួន  មិនគួរពេញចិត្តតែក្នុងសេចក្តីសុខដែលនៅប្រឡំដោយអាមិសគ្រឿងរឹតរួតចិត្ត ឲ្យជាប់នៅក្នុងអំណាចរបស់កិលេសគ្រប់ពេលវេលាឡើយ  គួរណាស់ហើយតែបំពេញខវត្តបដិបត្តិឲ្យជាកំលាំងខាងក្នុង  ដើម្បីជាបច្ច័យឲ្យបានជួបប្រទះនឹងនិរាមិសសុខក្នុងកាលជាទីបំផុត ។  ឯនិរាមិសសុខនោះបានដល់សេចក្តីសុខ ដែលប្រាសចាកអាមិសគ្រឿងជន្ទួចិត្ត ។ ក៏សេចក្តីសុខនេះទៀតសោត នឹងកើតឡើងបាន  ក៏ព្រោះអាស្រ័យហេតុនៃការប្រកប ។ ឯហេតុដែលឲ្យកើតនិរាមិសសុខនោះ  បានដល់វិវេកសេចក្តីស្ងប់ស្ងាត់ ៣ ប្រការគឺកាយវិវេកស្ងាត់កាយ  បានដល់បុគ្គលដែលមានកាយស្ងប់ស្ងាត់ ត្រេកអរក្នុងនេក្ខម្មៈ  លះបង់ចោលពួកគណៈ  ហើយប្រព្រឹត្តនៅតែម្នាក់ឯង ១ ចិត្តវិវេក  ស្ងាត់ចិត្ត  បានដល់បុគ្គលដែលមានចិត្តបរិសុទ្ធផូរផង់  លះបង់ចោលនូវកិលេស  ដោយអំណាចសមាបត្តិ ៨  ជាអ្នកមានចិត្តថ្លាស្អាតជ្រះស្រឡះចាកគ្រឿងរាំងរក ១,  ឧបធិវិវេក  បានដល់បុគ្គលដែលមិនមានកិលេស មិនមានសង្ខារ គឺជាអ្នកបានធ្វើចិត្តឲ្យស្ងាត់ចាកកិលេសទាំងឡាយ  ដោយប្រើបញ្ញាពិនិត្យ  ពិចារណាឲ្យឃើញច្បាស់  ដឹងច្បាស់ក្នុងរឿងសង្ខារ  ផកបពាល់តែចិត្តលែងចាប់ប្រកាន់មាំ ក្នុងសង្ខារដោយអំណាចតណ្ហា-ឧបាទាន ១ ។ សេចក្តីស្ងប់ស្ងាត់ទាំង៣ប្រការនេះ

សុទ្ធតែជាគ្រឿងបំពេញបំពូនបញ្ចូនឲ្យកើតសេចក្តីសុខដ៏ឧត្តមលើសលុបឡើងទៅទាំងអស់ ។ សេចក្តីសុខដែលកើតអំពីចិត្តវិវេក ទីឯឧបធិវិវេកទាំង២ នេះ បាត់ជានិរាមិសសុខ ជាសុខមិនប្រឡូកដោយអាមិសគ្រឿងជំពាក់ចិត្ត គឺជាសេចក្តីសុខថ្លាស្អាតបរិសុទ្ធ ទីឯទួនមិនប្រែប្រួល ។

និរាមិសសុខនេះឯង ជាសុខពិតប្រាកដ មិនអែបអាស្រ័យអាមិសគ្រឿងធ្វើចិត្តឲ្យរង្វើនរង្វាន់ ជាប់ព័ន្ធកដ៏កិលេស ជាសន្តិសុខ គឺសុខដែលកើតអំពីសេចក្តីស្ងប់ចិត្ត ដែលមានរស-មានអាការមាំទាំជាងសុខទាំង-ឡាយទាំងពួង សមដូចសុភាសិតថា: នត្ថិ សន្តិបរំ សុខំ សេចក្តីសុខដទៃក្រៅពីសេចក្តីស្ងប់មិនមាន ។

សាធុជន បពិត្រសប្បុរសទាំងឡាយ កាលបើបានជ្រាបសេចក្តីសុខទាំង២ប្រការ ព្រមទាំងហេតុប្បច្ច័យច្បាស់លាស់ ដោយន័យដូច្នេះហើយគួរព្យាយាមស្វែងរកសេចក្តីសុខទាំងពីរប្រការនោះ ឲ្យកើតមានឡើងក្នុងខ្លួន សូម្បីជាចំណែកសាមិសសុខ ក៏គួរស្វែងរកបំពេញឡើងទុកឲ្យបរិបូណ៌ តែមិនត្រូវភ្លេចខ្លួនទេ ត្រូវមានបញ្ញាជាគ្រឿងពិចារណាផង កុំបណ្តោយឲ្យចិត្តជាប់ជំពាក់ស្រវឹងវង្វេង ត្រូវដឹងថា សាមិសសុខនេះមិនឋិតថេរជាវរៈមាំមួនទេ ជាសុខដែលកើតឡើងមួយពេលមួយខណៈ តែងផ្លាស់ប្តូរប្រែប្រួលទៅវិញ តាមសភាវៈធម្មតា ដូចបុគ្គលដែលអេះរមាស់ជាដើមសុទ្ធតែមានសេចក្តីទុក្ខប្រចាំនៅខាងមុខជានិច្ច ឬដូចសេចក្តីសុខដែលកើត

អំពីមានទ្រព្យ ដែលជាទីប្រាថ្នារបស់បុថុជ្ជនគ្រប់គ្នា តែទ្រព្យនោះក៏ពុំបានឲ្យកើតសេចក្ដីសុខពិត ៗ ទេ វេលាបានមកក៏ត្រេកអរ តែងានសេចក្ដីទុក្ខនៅអមផង ចាប់តាំងអំពីការប្រើប្រាស់ទុកដាក់ថែរក្សាជាដើមទៅ បើប្រើខុសទំនងក៏រឹតតែកើតជាទោស មានសេចក្ដីពុះពោរ ក្ដៅក្រហាយចិត្តជាផល ៗ ដូច្នេះ សាធុជនពុទ្ធបរិស័ទទាំងឡាយ គួរប្រញាប់រាប់យកប្រយោជន៍អំពីរបស់ទាំងអម្បាលនេះ ឲ្យសមតាមទំនង ដូចការខ្ចីរបស់អ្នកដទៃមកប្រើ ត្រូវប្រញាប់ប្រើឲ្យបានសំរេចប្រយោជន៍ សមតាមប្រាថ្នា ហើយជូនគ្រឡប់ទៅឲ្យគេវិញ ដោយមិនមានអាល័យ ៗ ឬដូចជាសត្វហង្ស ដែលចុះស៊ីចំណីក្នុងភក់ ឆ្អែតហើយក៏ហើរទៅ មិនត្រូវសេចក្ដីអាល័យជាប់នៅក្នុងទីនោះ; លំដាប់តមក គួរស្វែងរកនិរាមិសសុខ ដែលជាសុខកើតអំពីការបដិបត្តិផ្លូវចិត្តខាងក្នុង ដោយបំពេញវិវេក គឺសេចក្ដីស្ងាត់ ៣ ប្រការឲ្យបរិបូណ៌ លុះវិវេកទាំង៣ ប្រការៈកើតឡើងហើយ រមែងជាគ្រឿងកំចាត់ផ្សលាងសេចក្ដីសៅហ្មងក្នុងចិត្ត ឲ្យអស់ទៅដោយអំណាចវិវេក នោះ ៗ ជាចិត្តដល់នូវសេចក្ដីផូរផង់ សុខដែលជាផលក៏កើតឡើងជាកំឡាំងខាងក្នុង ឈ្មោះថា បានក្រេបផឹកនូវរសនៃនិរាមិសសុខ ជាសុខមិនប្រែប្រួល ពោលគឺព្រះនិព្វាន សមដូចពុទ្ធភាសិតថា និព្វានំ បរមំ សុខំ "ព្រះនិព្វាន ជាសុខយ៉ាងក្រៃលែង" [illegible]:

អាត្មាភាព សំដែងអំពីសុខកថា ពណ៌នាអំពីសេចក្តីសុខ ២ ប្រការ គឺល្មមសមគួរដល់ពេលវេលាតែប៉ុណ្ណេះ ។

ដោយអំណាចនៃធម្មទាននេះ អាត្មាភាពសូមប្រមូលកុសលរាសីទាំងអស់ ថ្វាយចំពោះព្រះករុណាជាម្ចាស់ជីវិតទាំងពីរព្រះអង្គ ឱនសម្តេចព្រះឧប-យុវរាជ ព្រះបិតាឯករាជ្យជាតិ សូមព្រះអង្គស្ថិតនៅគង់ព្រះសិរីរាជសម្បត្តិ បានប្រកបដោយបរមសុខសុភមង្គលសិរីសួស្តីគ្រប់ទិវារាត្រីកាល កុំបីមានសឹកសត្រូវកបដ្តកយុទ្ធ មកបៀតបៀនព្រះអង្គបានឡើយ ហើយសូមព្រះអង្គទ្រង់បានប្រកបដោយព្រះជន្មាទីឃាយុយឺនយូរជាទីពឹងព្រះរាស្ត្រ ដើម្បីទ្រង់ព្រះសណ្តាប់គង់ឋានៈជាព្រះឧត្តមគុណទូសក៏នៃប្រជាពលរដ្ឋតរៀងទៅ ។

ម្យ៉ាងទៀត សូមឲ្យពុទ្ធបរិស័ទទាំងឡាយ បានសម្រេចនូវឥដ្ឋមនុញ្ញផលវិបុលសុខគ្រប់ប្រការ កុំបីឃ្លាតឡើយ ។

រតនត្តយានុភាវេន សតតលោកានុកម្បិនោ
វុឌ្ឍី វិរុឡ្ហី វេបុល្លំ សន្តិការញ្ញ ញាណជា ។

ដោយអានុភាពនៃព្រះរតនត្រ័យ សូមឲ្យប្រជាពលរដ្ឋទាំងឡាយ ដែលអាស្រ័យនៅក្នុងសកលលោកទាំងមូល បានដល់នូវការលូតលាស់កើចំរើនទីងបាននូវសន្តិភាព កុំបីឃ្លាតឆ្ងាយ ទៅជាបរការៈដទៃឡើយ ។

× × ×

# រឿងសត្វចាបនឹងដំរីស្ដ

លោក ប៊ូ-ប៊ូ រៀបរៀង

---

កាលពីព្រេងនាយ មានមេចាបមួយធ្វើសំបុកក្រាបក្រុងកូនខ្ចីនៅដើមភ្ញុំមួយ ត្រង់ផ្លូវដំរីដើររកស៊ី ៗ ថ្ងៃមួយ មានដំរីព្រៃមួយហ្វូង ដើររកស៊ីទៅដល់សំបុកមេចាប ៗ ឃើញហ្វូងដំរីដើរត្រង់មកចំសំបុកខ្លួន ភិតភ័យខ្លាំងណាស់ ក្រែងដំរីជាន់កូនស្លាប់ ក៏ហើរយ៉ាងប្រញាប់ទៅកាន់ស្វាប គោរពចំពោះមុខដំរីជាមេហ្វូងនិយាយអង្វរថា សូមលោកករុណាមេត្តាកុំដើរជាន់កូនខ្ញុំ ព្រោះវានៅតូចណាស់មិនទាន់ផុតក្រាសហើរទៅណារួចទេ ៗ

ឯដំរីជាមេហ្វូងឆ្លើយថា អើ មិនអីទេ ! ឯងកុំភិតភ័យអី ចាំអញជួយការពារឲ្យកូនឯងបានរួចរស់ជីវិត ប្រាប់ហើយក៏ដើរទៅឈរត្រែងជើងពីលើសំបុកចាប ប្រាប់ដំរីឯទៀតដាប់វាឲ្យនាំគ្នាចៀសសំបុកចាបហួសអស់ទៅ ៗ កូនចាបក៏បានរួចពីសេចក្ដីស្លាប់ ៗ ទើបដំរីមេហ្វូងផ្ដាំមេចាបថា នៅមានដំរីស្ដមួយទៀត ដើរមកខាងក្រោយគេម្នាក់វា អាស្ដនោះសាហាវណាស់ បើវាមកដល់សំបុក ចូរឯងខំអង្វរគេ ឲ្យមេនវេទ ក្រែងវាករុណាអាសូរឯងខ្លះ ផ្ដាំរួចដើរហួសទៅ ៗ

មេចាបឃើញកូនខ្លួនរួចរស់ជីវិត ត្រេកអរណាស់ និយាយសរសើរចិត្តទន់អរគុណដំរីមេហ្វូងយ៉ាងក្រៃលែង ៗ មិនយូរប៉ុន្មាន ដំរីស្ដសាហាវនោះ ដើរមកដល់សំបុកមេចាប ៗ ចូលទៅកាន់ស្វាបគោរពអង្វរ

សុំជំរិតកូនដូចលើកមុន ៗ ដំរីស្ដ្រីស្រែកគំហកមេទាបថា "ម៉េចក៏ហ៊ានឯងមកធ្វើសំបុកទុកកូនត្រង់ផ្លូវអញដើរ អញជាន់សម្លាប់កូនហ៊ានឯងឥឡូវហើយ មិនអាណិតទេ កុំថាតែខ្លួនវិញមួយពីរប៉ុណ្ណោះ សូម្បីទាបពប់មុនសែន ក៏អញជាន់ឈ្លីតែនឹងជើងម្ខាងមួយឲ្យល្អិតខ្ទេចខ្ទីដែរ អញមិនផុតជាន់នឹងជើងទាំងបួនទេ" ថារួចស្រុះទៅជាន់ឈ្លីកូនទាបស្លាប់ក្រមល្អិតល្អោចទាំងសំបុកទៀត រួចរត់ទោះយាក់ អណ្ដែតគ្លឹងគ្លែង ពមកូនទាបហូរទៅតាមទឹកទោមរ៉ា រ៉ះសីចក្អាកក្អាយសប្បាយចិត្តដើរហួសទៅ ៗ

មេទាបឃើញដូច្នោះ គេចហើរទៅទំលើមែកឈើក្បែរទីនោះ យំសោកព្រោកខ្លួនភ្លាឡោះអាល័យស្ដាយកូនខ្លាំងណាស់ ស្រែកដេរប្រទេចដំរីស្ដ្រីថា "នែអាពាលកំណាច ! ពេលនេះ អាឯងសប្បាយចិត្តចុះ អាឯងអាងខ្លួនថា អាងមានកម្លាំងខ្លាំងជាងអញ អាធ្វើតាមអំពើពាលទៅចុះ មិនយូរប៉ុន្មានទេ គង់តែអាទន់នឹងពឹងកម្លាំងអញជាទាបមិនខាន ៗ

មេទាបដេរប្រទេចដំរីរួច ហើរទៅរកពពឹកគ្រួកជាសម្លាញ់ និយាយរៀបរាប់ពីដំរីជាន់សម្លាប់កូនឲ្យក្អែកស្ដាប់ តាំងពីដើមដល់ចប់ ហើយអង្វរក្អែកឲ្យទៅចឹកបោះភ្នែកដំរីស្ដ្រី ។ ក្អែកអាណិតមេទាបណាស់ នឹកក្ដៅក្រហាយចិត្តខឹងសម្បើដំរីស្ដ្រីយ៉ាងខ្លាំង ឆ្លើយថា "សម្លាញ់កុំព្រួយ ចាំខ្ញុំជួយឲ្យបានដូចចិត្ត" ថារួចហើរទៅរកដំរីស្ដ្រី ឃើញហើយ ទៅទំលើក្បាលចឹកបោះភ្នែកដំរីពាលតែម្ដងបែកប្រស្រីទាំងពីរហូរឈាមរហាម ហើយមេទាប

ទៅនិយាយនឹងរុយទៀត ។ រុយទទួលយកអាសាទៅពងដាក់ភ្នែកដំរី កើតជាដង្កូវចុះបែនភ្នែកឲ្យដំបៅរាលតែខ្វាក់ទៅ ។ មេចាបទៅពឹងកង្កែបឲ្យជួយទៀត ។ កង្កែបទទួលជួយឡើងទៅស្រែកយំលើក្បែរមាត់ជ្រោះជ្រៅ ។ ឯដំរីខ្វាក់ស្រេកទឹកណាស់ដើរស្វះស្វែងរកទឹកផឹក ឮស្រែកកង្កែបយំ សំគាល់ថាជាត្រពាំងទឹក ក៏ដើរយ៉ាងលឿនដម្រង់ទៅដល់មាត់ជ្រោះ រអិលជើងមុខទាំងដុំប្រមៀលធ្លាក់ ក្នុងជ្រោះស្លាប់គ្រានោះទៅ ។

មេចាបឃើញដំរីសារធ្លាក់ទៅក្នុងជ្រោះក៏ស្លាប់ហើយ ទឹកត្រេកអរណាស់ស្រែកផ្ចាញ់ផ្ចាលដំរីថា "នែអាដំរីពាល កម្លាំងកាយ បើទុកជាខ្លាំងយ៉ាងណា ក៏មិនអាចធ្វើការគ្រប់ចំពូក ឲ្យសម្រេចបានដែរ, កម្លាំងបញ្ញាទើបអាចសម្រេចកិច្ចការសព្វគ្រប់បាន សូម្បីភ្នំដ៏ខ្ពស់ក៏អាចរំលាយឲ្យរាបស្មើនឹងផ្ទៃផែនដីបានដែរ" ។ មេចាបថារួចហើយ ក៏ហើរចេញទៅ ។

និទានមេចាបសម្លាប់ដំរីសារនេះ ដើម្បីបញ្ជាក់សេចក្ដីឲ្យឃើញច្បាស់ថា ការសាមគ្គីរួបរួមគ្នា តែងធ្វើកិច្ចការដែលធំៗ ធ្ងន់ៗ ក្រៗ ឲ្យសម្រេចបានដូចជាមេចាប, ក្អែក, រុយ នឹងកង្កែប តែបួនរូបប៉ុណ្ណោះ រួមគ្នាជាកម្លាំងមួយ អាចសម្លាប់ដំរីសារបានដោយងាយ តាមកម្លាំងបញ្ញារបស់វា ។ អតីតនិទាននេះ ជារឿងខាងគតិលោក ។

ចំណែករឿងខាងគតិធម៌វិញ ក៏មានតែងទុកថា អ្នកផ្ចាញ់កិលេសមារជាសឹកសត្រូវនៅក្នុងខ្លួនក្ដី អ្នកធ្វើបុណ្យមានចំនួនតិច មានកសាង

វត្ត, វិហារ, កុដិ, សាលា ជាដើមក្តី ក៏តែងបានសម្រេចដោយសារកម្លាំងសាមគ្គីព្រមព្រៀងគ្នា ដូចមានសេចក្តីក្នុងអបរិហានិយសូត្រ គម្ពីរអង្គុត្តរនិកាយសត្តកនិបាតថា :

សម័យពុទ្ធកាល វស្សការព្រាហ្មណ៍ជាមហាមាត្យនៃព្រះបាទអជាត-សត្រូវក្រុងរាជគ្រឹះ បានចូលទៅគាល់ព្រះសម្មាសម្ពុទ្ធ លើកគំនិតក្រុងក្រាបទូលថា បពិត្រព្រះអង្គដ៏ចំរើន ! ព្រះបាទអជាតសត្រូវមានព្រះរាជបំណងនឹងលើកកងទ័ពទៅវាយក្សត្រដែនវជ្ជី ជាដែនទៅជិតគ្នា ឲ្យខ្ទេចខ្ទីនៅក្នុងអំណាចរបស់ព្រះអង្គ ។

ព្រះបរមសាស្តាទ្រង់ត្រាស់ថា "ម្នាលព្រាហ្មណ៍! ក្សត្រដែនវជ្ជីគេព្រមព្រៀងគ្នាប្រព្រឹត្តអបរិហានិយធម៌ ជាធម៌ដឹកនាំអ្នកប្រតិបត្តិតាមមិនឲ្យវិនាសសាបសូន្យ ឲ្យមានតែសេចក្តីសុខចំរើនយ៉ាងបរិបូណ៌ គេចុះសម្រុងប្រជុំប្រឹក្សាគ្នាពិគ្រោះរបស់ប្រទេស, គេស្រុះស្រួលគ្នាជួយធ្វើកិច្ចការជាសាធារណប្រយោជន៍, គេគោរពកោតក្រែងស្តាប់ព្រះរាជបញ្ញត្តិនៃព្រះមហាក្សត្ររបស់គេគ្រប់ប្រការ គេកាន់ច្បាប់ទម្លាប់ប្រទេសរបស់គេយ៉ាងម៉ឺងម៉ាត់, គេមិនហ៊ានធ្វើអ្វីតាមអំពើចិត្តគេឡើយ; អាស្រ័យការប្រព្រឹត្តអបរិហានិយធម៌នេះហើយបានជាដែនវជ្ជី មានសេចក្តីសុខចំ-រើនយ៉ាងក្រៃលែង មិនដែលមានសត្រូវណាទៅប្រមាថពាលាសង្កត់សង្កិនបានឡើយ ព្រោះបើសត្រូវនោះ មានឥទ្ធិពលខ្លាំងក្លាយ៉ាងណាក៏ដោយ" ។

វិស្សការព្រាហ្មណ៍ស្ដាប់ព្រះពុទ្ធដីកាចប់ហើយ មានចិត្តត្រេកអរណាស់ ក្រាបថ្វាយបង្គំលាព្រះទសពល ត្រឡប់ទៅក្រាបទូលព្រះបាទអជាតសត្រូវ សូមទ្រង់ជ្រាបអំពីអបរិហានិយធម៌ របស់ក្សត្រដែនវជ្ជីគ្រប់ប្រការ ។

តាមន័យព្រះពុទ្ធដីកា ដែលទ្រង់ទេសនាអំពីអបរិហានិយធម៌នោះ បើយើងសង្កេតមើលស្ថានការក្នុងប្រទេសកម្ពុជា នាសម័យបច្ចុប្បន្ននេះ ឃើញថា សម្ដេចព្រះបិតាឯករាជ្យជាតិ ជាព្រះអគ្គមគ្គុទ្ទេសក៍នៃប្រទេសកម្ពុជា ដែលទ្រង់ដឹកនាំប្រជាពលរដ្ឋឲ្យរួបរួមគ្នា ជាមហាសង្គមមួយក្នុងសង្គមជាតិ, ឲ្យពួតដៃគ្នាជួយធ្វើកិច្ចការ ជាសាធារណប្រយោជន៍ដល់ប្រទេសជាតិមាតុភូមិច្រើនប្រការ មានទ្រង់ដឹកនាំឲ្យប្រមូលគ្នាជួយលើកថ្នល់, លើកទំនប់ទឹក, ជីកស្រះ, ជីកអណ្ដូងជាដើមនោះ ត្រូវតាមគន្លងអបរិហានិយធម៌នោះ ពិតប្រាកដ ។

អាស្រ័យព្រះឧត្តមគតិនៃសម្ដេចព្រះបិតាឯករាជ្យជាតិយ៉ាងនេះ ហើយបានជាពលរដ្ឋខ្មែរគ្រប់ប្រភេទ ទាំងទាហាន ទាំងស៊ីវិល វិញគ្នាជាសាមគ្គី ជាប់ស្អិតណាស់ អាចធ្វើកិច្ចការអ្វីៗ ទោះក្រលំបាកយ៉ាងណាក្ដី ឲ្យបានសម្រេចទាំងអស់ ហើយថែមទាំងមានជ័យជម្នះឈ្នះមារសត្រូវគ្រប់ទិសទីផងទៀត ទោះបីសត្រូវណាប្រាថ្នាទឹងបៀតបៀនប្រទេសខ្មែរ សត្រូវនោះក៏រលាយ ដូចអម្បិលត្រូវទឹក, ក្រមួនត្រូវថ្ងៃ ពុំខានឡើយ ។

x x x

# សុរពជាតក

(តមក)

លោក ចង-វង បម្រួលពីសាស្ត្រាស្លឹករឹត

---

ឯកំ សច្ចំ សេចក្ដីនេះពិតប្រាកដមែនឬ? ។ ឯចៅជោតិកមាណព ក្រាបបង្គំទូលថា បពិត្រមហាពជ ! បើបិតាទូលព្រះបង្គំជាខ្ញុំទិញក្អែកបុរសនេះយកទៅ ទូលព្រះបង្គំជាខ្ញុំនឹងសងវិញ តែសូមឲ្យព្រះអង្គប្រើបុរសនេះធ្មៀលក្អែកម្ចាស់ដែលគង់នៅនោះ មកដាក់ចំពោះព្រះភក្ត្រព្រះអង្គសិន ទូលព្រះបង្គំជាខ្ញុំនឹងធ្មៀលក្អែកទូលព្រះបង្គំជាខ្ញុំ ២ សងវិញ ព្រោះបិតាទូលព្រះបង្គំជាខ្ញុំទិញយកទៅតែ ១ ទេ ។ ព្រះពជាទ្រង់ត្រាស់ថា គោ ចោធគារ ហៃព្រះស្ងួនអ្នកចោទគ៍ ! ក្អែកព្រះស្ងួនម្ចាស់ដែលមាន មិសៈដៀតមានសាច់នៅក្នុងក្អែក ឬព្រះស្ងួនរេរធ្មៀលឲ្យល្អ, ឯក្អែកដែលគង់នៅនោះ ក៏ឬព្រះស្ងួនធ្មៀលឲ្យល្អហើយយកចេញ ជោតិកមាណពនឹងសងក្អែកដ៏ឡើងល្អលើសដើមវិញ ។ បុរសកម្លៅដែលចោទ លុះឮព្រះបន្ទូលដូច្នេះក៏ភិតភ័យតក្កមា លុតជង្គង់ទូលថា បពិត្រព្រះត្រៃប្រសើរអើយ ! ទូលព្រះបង្គំជាខ្ញុំពុំអាចធ្មៀលក្អែកបានឡើយ ។ ទើបស្ដេចត្រាស់ថា បើឲ្យព្រះស្ងួនធ្មៀលក្អែក ព្រះស្ងួនធ្មៀលពុំបាន ចុះកាលព្រះស្ងួនធ្មៀលឲ្យទៅពីឲ្យបណ្ឌិត ព្រះស្ងួនអាចធ្មៀលបានហ៎ះ ! ទើបបុរសនោះក្រាបបង្គំទូលថាៈ ហេតុតែទូលព្រះបង្គំជាខ្ញុំល្ងង់ខ្លៅឥតប្រាជ្ញា និយាយពុំពិតឡើយ ។

ស្ដេចស្ដាប់ហើយទ្រង់ព្រះពិរោធមហិមាមានព្រះបន្ទូលថា អរេ ទុដ្ឋ អន្ធពាល ហៃព្រះស្ដេចអន្ធពាលអប្បលក្ខណ៍ជួជាតិ! ព្រះស្ដេចជាអ្នកមានចិត្តបាបកម្មក្រាសអំពីជាតិមុន ទើបកើតមកក្នុងជាតិនេះមានភ្នែកខ្វាក់ ឥឡូវព្រះស្ដេច ធ្វើកម្មមានទម្ងន់យ៉ាងនេះទៀត តើព្រះស្ដេចប្រាថ្នាអ្វី? ។ បុរសនោះក្រាបបង្គំទូលថា ព្រោះតែចង់បានទ្រព្យគេណាព្រះអង្គ ។ ទើបស្ដេចត្រាស់ទៅអាមាត្យទាំងឡាយថា ភោន្ដោ ហៃអ្នកទាំងឡាយដ៏ចំរើន បុរសនេះ វាចោទជោតិកមាណពជាអ្នកឥតទោស ធំ គរុកម្មំ ទោសនេះ មានទម្ងន់ក្រៃលែង ចក្ខុនាម បិយំ ភ្នែកជាទីស្រឡាញ់ពេញចិត្តស្មើជីវិត ចូរអ្នកទាំងឡាយគាស់ភ្នែកទាំងពីរលក់ជាថ្លៃ ១ ពាន់ដំឡឹង ហើយលក់បុរសនេះទៅគុណជាក្រយាពន្ទ័យហ្វូង ១ ជា ២ រួចកត់រាជក្រិត្យនេះទុក សម្រាប់ព្រះនគរតទៅ ។ ព្រះមហាក្សត្រត្រាស់ពាក់ទ្រង់មានព្រះតម្រាសទៅជោតិកមាណពថា បុរសនេះមកចោទថា វិជ្ជាអ្នកប្រាជ្ញបិតាទៅឯងមកខ្ចីកូនជ្រូកស ១ យកទៅ ពុំយកមកជូនគេឡើយ តើពិតមែនឬ?។ ជោតិកមាណពក្រាបបង្គំទូលថា បើបិតាទូលព្រះបង្គំជាខ្ញុំខ្ចីកូនជ្រូកយកទៅសមបើ មានបន្ទាល់ខ្លះមិនទេឡើយ ។ បុរសនោះទូលថា ទូលព្រះបង្គំជាខ្ញុំមានភរិយាជាបន្ទាល់ ។ ជោតិកមាណពឆ្លើយថា ប្រពន្ធជាបន្ទាល់ប្ដីក្ដី ប្ដីជាបន្ទាល់ប្រពន្ធក្ដី ពុំដែលមានពីបុរាណរៀងមក លោកពុំឲ្យយកជាបន្ទាល់ឡើយ ដ្បិតប្ដីនឹងប្រពន្ធមានគំនិតតែមួយ ។ បុរសនោះ ស្ដាប់

ហើយទាល់ប្រាជ្ញនៅស្ងៀម ៗ ជោតិកមាណពក្រាបទូលបន្ថែមថា បពិត្រមហារាជ! ដំណើរនេះ ទោះមានបន្ទាល់ក្តី ឥតបន្ទាល់ក្តី មិនជាសំខាន់ទេ, ប៉ុន្តែធម្មតាកូនជ្រូកស រមែងមានពណ៌សម្បុរដូចមេវា សូមព្រះអង្គទ្រង់ត្រាស់ដណ្តឹងបុរសនេះឲ្យប្រាកដ ៗ ទើបព្រះរាជាត្រាស់សួរទៅបុរសនោះថា កូនជ្រូកព្រះស្តេចនោះ មេស ឬ បារ៉ាស ? ។ – បពិត្រក្សត្រថ្លៃប្រសើរអើយ! កូនជ្រូកសនោះ ទូលព្រះបង្គំជាខ្ញុំមិនមានឡើយ ។ – បើដូច្នោះព្រះស្តេចចោទដាក់ទោសកំហុសគេឬទេ ? ។-ក្រាបទូល ។ ទើបស្តេចត្រាស់ថា ហៃអ្នកទាំងឡាយ! បុរសនេះមិនមែនចោរ ទុកស្មើចោរ ត្បិតវាប្រាថ្នាបង់បានទ្រព្យគេ ទើបវាហ៊ានចោទដាក់ទោសកំហុសឲ្យគេ, ហៃអាមាត្យទាំងឡាយ! ត្រូវលក់បុរសនេះតាមតម្លៃកូនជ្រូកស ព្រោះធម្មតាកូនជ្រូកស លោកទុកស្មើត្បូងចិញ្ចៀនកាត់ថ្លៃមិនបាន ពុំដែលទៅកើតត្រកូលចោរតាមឡើយ តែងទៅកើតត្រកូលក្សត្រសដ្ឋជាសត្វមង្គល ចូរអ្នកទាំងឡាយកាត់ជាថ្លៃ ១ ម៉ឺនឡើង ហើយលក់ទ្រព្យរូបហើយ ត្រូវកត់ទុកជារាជក្រិត្យសម្រាប់ព្រះនគរតទៅ ។ ចាប់តាំងពីថ្ងៃដែលបុរសទាំង ៤ នាក់ចាញ់មាណពទៅ ពុំមានអ្នកណាមកចោទប្តឹងសេចក្តីដូច្នេះទៀតឡើយ ។ រីឯជោតិកមាណពក៏ផ្តុំចំណិញចេញទៅជួញក្នុងស្រុកពហុលនគរនោះឯង ។

តទា បនេសការដាទោ កាលនោះ មានស្តេចបរទេសរាជ៣ព្រះ

អគ្គ សោយរាជ្យនៅនគរផ្សេងពីគ្នា, ថ្ងៃមួយ បានដំណឹងថា ព្រះរាជបុត្រីព្រះចៅពហុលនគរ ដ៏ទ្រង់នូវរូបឆោមល្អប្រពៃ ដូចស្រីទេពអប្សរបរិកញ្ញា ក្សត្រទាំង ៣ ព្រះអង្គចង់បានដូចគ្នា ទើបធ្វើជាប្រស្នាដោយព្រះទំរង់ក្នុង ១ ព្រះអង្គបី ៗ ប្រស្នា ឃោកា គឺត្បូងព្រះទំរង់ ១ កើតនៅទៀបឆ្នេរសមុទ្រ, ឃោកា ត្បូងព្រះទំរង់ ១ កើតពីផ្ទៃមហាសមុទ្រ, ឃោកា ត្បូងព្រះទំរង់ ១ កើតនៅនាព្រៃព្រះហិមពាន្ត ព្រះទំរង់នីមួយគិតថ្លៃជាមាស ១ សែនដំឡឹង ៗ ឃោកា រាជា ឯស្ដេចមួយព្រះ-អង្គទៀត ធ្វើប្រស្នាដូចគ្នា តែថា ត្បូងព្រះទំរង់ ១ កើតនៅភ្នំវិបុលបព៌ត ត្បូងព្រះទំរង់ ១ កើតនៅនាគពិភព, ត្បូងព្រះទំរង់ ១ កើតនៅផ្ចិតព្រះធរ-ណី, ត្បូងព្រះទំរង់ទាំងបីនេះ មានតម្លៃ ១ សែនដំឡឹង ៗ ឃោកា ឯស្ដេចមួយព្រះអង្គទៀត ធ្វើប្រស្នាដូចគ្នាគឺ ត្បូងព្រះទំរង់ ១ កើតក្នុងភ្នំព្រះសុមេរុ ត្បូងព្រះទំរង់ ១ កើតក្នុងភ្នំសុវណ្ណគិរី, ត្បូងព្រះទំរង់ ១ កើតនៅក្នុងគិរីនាថបព៌ត; ព្រះទំរង់ទាំង ៣ នេះមានតម្លៃជាមាស ១ សែនដំឡឹងៗ ស្ដេចទាំង៣ព្រះអង្គនេះ ក៏ដាក់ត្បូងព្រះទំរង់ក្នុងប្រអប់មាសបិទយ៉ាងជិត ហើយតែងព្រះរាជសារមានសេចក្ដីថា អម្ភោ ពហុលរាជ ! ហៃព្រះបាទពហុលរាជដ៏ចំរើន ! ឥឡូវយើងឲ្យនាំប្រស្នាត្បូងព្រះទំរង់ទាំង៣នេះ មកឲ្យស្ដេចពិចារណារកទីបានកំណើត បើស្ដេចរកឃើញ យើងនឹងបូជាសក្ការៈផ្សេង ៗ បើស្ដេចរកពុំឃើញ ត្រូវជូនព្រះរាជធីតាមកយើង

ទាំង ៣ ព្រះអង្គ បើស្ដេចមិនព្រមជូនទេ យើងនឹងលើករេហ៍ពលសកល យោធាមកវាយព្រះនគរឲ្យខ្ទេចផង់ធូលី ៗ ព្រះរាជសារទាំង ៣ មានសេចក្ដីដូចៗគ្នា រួចហើយព្រះរាជាទ្រង់ចាត់រាជទូតទាំងឡាយឲ្យនាំព្រះរាជសារចូលទៅថ្វាយព្រះបាទពហុលរាជ ៗ រាជទូតទាំងឡាយក៏ចូលទៅឈរនៅខ្លោងទ្វារ ហើយប្រាប់ឆ្មាំទ្វារឲ្យចូលទៅក្រាបទូលព្រះបាទពហុលរាជៗ ស្ដេចជ្រាបហើយ ទ្រង់ហៅរាជទូតឲ្យចូលទៅ ៗ ពួករាជទូតក៏ចូលទៅក្រាបថ្វាយបង្គំ ហើយអង្គុយក្នុងទីដ៏សមគួរ ៗ ព្រះចៅពហុលនគរត្រាស់សួរថា ភោន្តោ អាគតា ព្រះស្ដេចទាំងបីអញ្ជើញមកពីនគរណា ? ៗ រាជទូតទាំង ៣ ក៏ក្រាបទូលតាមដំណើររៀងខ្លួន ៗ

កស្មា អាគតា អ្នកទាំងឡាយមកមានហេតុដូចម្ដេច ? ៗ រាជទូតទាំងឡាយក៏ក្រាបទូលតាមសេចក្ដី រួចហើយថ្វាយព្រះរាជសារគ្រប់គ្នា ៗ ស្ដេចទតហើយត្រាស់ថា ភោតំ ករណោ ម្នាលព្រះស្ដេច ឯព្រះរាជហាររៀនព្រះទំរង់នេះដូចម្ដេច? ៗ ទើបពួករាជទូតថ្វាយប្រអប់ព្រះទំរង់គ្រប់ៗគ្នា ៗ ព្រះរាជាទ្រង់ចាត់ឲ្យសង់ព្រះរាជរោង ១ ជប់លៀងពួករាជទូតទាំងនោះស្រេចហើយ ទ្រង់ឲ្យហៅអស់ពួកមុខមន្ត្រីមកប្រជុំគ្នា ហើយត្រាស់ថា ភោន្តោ ម្នាលអ្នកទាំងឡាយដ៏ចំរើន! អ្នកណាដឹងជាតិកំណើតនៃកែវនេះដែរឬ ? បើដឹងប្រាកដ យើងនឹងបូជាគុណអ្នកនោះ ៗ ពួកអាមាត្យជំនុំគ្នាពិចារណា ហើយក្រាបទូលថា ឆ ជាឆាម ឆ ជាឆាម

យើងខ្ញុំទាំងឡាយពុំដឹង ពុំស្គាល់ឡើយ ។ ស្ដេចស្ដាប់ហើយទ្រង់ព្រួយព្រះរាជហឫទ័យ ត្រាស់ឲ្យអាមាត្យប៉ាវគងរកបុរសស្ត្រីណាមួយក្រែងដឹង ស្គាល់ លុះប៉ាវគងសព្វស្រុកក្រៅលំនៅផងបង ក៏ឥតមានអ្នកណាមួយដឹងឡើយ ។ ព្រះរាជាទ្រង់ព្រួយព្រះរាជហឫទ័យក្រៃពេក ហើយត្រាស់ថា មយ្ហំ ឆត្តំ វិនស្សតិ ព្រះឆត្រអញនឹងវិនាសប្រាកដហោង ហើយចូលទៅដំណេកក្នុងប្រាសាទអស់រយៈ ៣ ថ្ងៃ លុះចូលថ្ងៃទី ៤ ក៏គ្មាននរណាមួយដឹងបាន ស្ដេចទ្រង់ព្រះកន្សែងសោយសោកថា វិនាសហើយៗ ឥទានិ បន រាជធីតា សព្វជេដ្ឋកា កាលនោះឯង ព្រះរាជធីតាច្បង ទ្រង់ព្រះនាមជោតិកទេវី មានប្រាជ្ញាឈ្លាសវៃ លើសនាងទាំងអស់ លុះឃើញព្រះរាជបិតាកើតទុក្ខដូច្នោះ ព្រះនាងទូលសួរថា ហេតុដូចម្ដេច ក៏ព្រះបិតាទ្រង់ព្រះកន្សែងដល់ម៉្លេះ ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលប្រាប់ព្រះរាជធីតាច្បងរបស់ព្រះអង្គសព្វគ្រប់ប្រការ ។ ព្រះនាងក្រាបទូលព្រះបិតាថា សូមទ្រង់ព្រះមេត្តាប្រោស ចុះជោតិកមាណពកម្លោះនោះ តើព្រះអង្គដណ្ដឹងសួរហើយឬនៅ ? ។ ស្ដេចស្ដាប់ហើយឆ្លើយថា ករុណា ម្នាលនាងជំទាវ! អស់នាហ្មឺនចាស់ទុំគិតគេមិនឃើញទៅហើយ ចំណង់បើទៅជោតិកមាណពកម្លោះខ្ចីសេចក្ដីនឹងចេះអ្វីឡើយៗ ព្រះនាងស្ដាប់ហើយឆ្លើយថា នរេ ឧត្តា ឧប្បញ្ញជាតិកា កុ-តោ ជានិស្សន្តិ; ឧទាហរំ ជោតិកមាណវំ នាម ជាវិតាំ

រូបបញ្ញាសមន្នាគតំ បុច្ឆិស្សំ បពិត្រព្រះបិតា! អស់ពួកទាហ៊ាន
មានអាយុវែងរាស់ទុំកំពិតមែន ឧក្ខា សឹងតែល្ងង់ខ្លៅឥតប្រាជ្ញអំពី
កំណើត ទីងដីងដូចម្តេចបាន សូមព្រះអង្គត្រាស់សួរនាយសំពៅៈឈ្មោះ
ជោតិកមាណពអ្នកចេះទប្បាយដំចំណាន ដែលប្រកបដោយរូបទីងប្រាជ្ញា
ចុះ ៗ ស្តេចស្តាប់ហើយទ្រង់ព្រះចិន្តាថា ព្រោះពិធូរអ្នកប្រាជ្ញជាបិតា
ជោតិកមាណពនេះ បានសំដែងដោះសា សតបនិកាបញ្ហា, ទន
យើងបានសុខសប្បាយម្តងហើយ អយំ បឋសស្សំ បុត្តោ ឯចៅ
ជោតិកមាណពនេះ ជាកូនវៃព្រះពិធូរកប្រាជ្ញប្រហែលជាចេះមុខិកប្រាជ្ញ
ពុំខាន ទើបស្តេចបញ្ជូនមកចូនព្រះរាជពានត្រាស់ឲ្យអាមាត្យទៅហៅ
ជោតិកមាណពឲ្យចូលមក ៗ លុះជោតិកមាណពមកដល់ហើយ, ស្តេច
ត្រាស់សួរថា ឆាវិកាវែតានាយសំពៅ! ឥន្ទានិ តយោ កាដាគោ
ឥឡូវនេះ មានស្តេចពាព្រះខគ ឲ្យនាំមុខិកប្រាជ្ញ ឥឡូវនៃវៃព្រះចំណែនាំក
ញមក បើដឹងហានកំណើតវៃតាំងៗ វៃមកនេះជាក្លារល្អ បើមិនដឹងគេនឹង
លើកពលមកវាយនគរ យើងឲ្យខ្ទេចខ្ទី ដូច្នេះ ចៅចៅនឹងដាក់ចូរចៅប្រាប់
យើងនាកាលឥឡូវនេះ ៗ ជាធាមិត្ត វត្ថា ចៅជោតិកមាណពក្រាប
ទូលថា ទូលព្រះបង្គំជាខ្ញុំស្គាល់ជាក់ប្រាកដ ព្រោះទូលព្រះបង្គំជាខ្ញុំបាន
រៀនសូត្រមក ៗ ចៅចៅដឹង ចូរចៅសំដែងមកហោង ៗ ទើបចៅជោតិក-
មាណពក្រាបទូលថា គោ ច មម សតត្ថិ ទូលព្រះបង្គំជាខ្ញុំសំដែង

ឥឡូវនេះ ទីដ៏មាននរណាជាបន្ទាល់សាក្សីនៃទូលព្រះបង្គំជាខ្ញុំ តស្មា ព្រោះហេតុនោះ សូមព្រះអង្គប្រដាប់ពីការ,. ផ្សេងអស់ទេវតាសូមជួយជាបន្ទាល់សាក្សីនៃខ្ញុំ ។ ព្រះពជាម្រង់ត្រាស់បង្គាប់ ឲ្យប្រដាប់គ្រឿងពីការសំពប់អញ្ជើញទេវតា ។ គ្រានោះ ចៅជាតិកមាណពនមស្ការអញ្ជើញទេវតាទាំង ៨ ទិសថា ភោន្តោ ទេវសង្ឃាយោ បពិត្រអស់ពពួកទេវតាដែលបិតនៅក្នុងទិសទាំង ៨ សូមអញ្ជើញមកជាបន្ទាល់សាក្សីនៃខ្ញុំ ត្បិតខ្ញុំទីងរកប្រស្នាក្នុងកាលឥឡូវនេះ បើខុសសូមជួយជំរង់ បើពោលត្រូវត្រង់ សូមជួយឲ្យពរសព្ទសាធុការ ។ ភោន្តោ បពិត្រទេវតាដ៏ចំរើន! មួយសោត ខ្ញុំសូមនមស្ការភាពជនាអញ្ជើញភុម្មទេវតា អាកាសទេវតា រុក្ខទេវតា វិមានទេវតា សូមស្តាប់ខ្ញុំ បើខ្ញុំឆ្លើយត្រូវ សូមអ្នកសំដែងខ្លួនឲ្យប្រាកដដល់អ្នកនគរនេះ ។ លំដាប់នោះព្រះពជាម្រង់យកប្រអប់ព្រះទំរង់មកដាក់នៅមុខជាតិកមាណព ហើយត្រាស់ហៅពជទូតទាំង ៣ នូវអស់មុខមន្ត្រីអាមាត្យពជបុរោហិត ឲ្យមកអង្គុយជិតចាំស្តាប់លើប្រាសាទនោះ ភោ ច ជោតិកាមាណវោ ឯចៅជាតិកមាណពនោះ កាលបើក្រឡេកមើលព្រះទំរង់ក្នុងប្រអប់នេះហើយ ក៏ស្គាល់ជាក់ ឯគាំ គណ្ហិត្វា ក៏ចាប់កែវ ១ ពិនិត្យមើលហើយទូលថា បពិត្រមហារាជ! សមុទ្ទតីរេ ជាតំ ត្បូង ១ នេះ កើតទៀបឆ្នេរមហាសមុទ្រ, ឥទំ សមុទ្ទមជ្ឈេ ជាតំ ត្បូង ១ នេះកើតនាកណ្តាលមហាសមុទ្រ,

ផុំ ហិមវន្តបព្វតោ ត្បូង ១ នេះ កើតនៅក្នុងព្រះហិមពាន្ត; កែវ ទាំង ៣ នេះ មានតម្លៃជាមាស ៣ សែនដំឡឹង អបិច ប្រការមួយទៀត កែវដែលកើតនៅកណ្តាលផ្ទៃសមុទ្រនោះ មានគុណប្រសើរលើសកែវទាំង ២ ៗ ស្តេចជ្រាបហើយ ទ្រង់បើកប្រអប់ព្រះទំរង់១ទៀត ហុចទៅជោតិកមាណពដោយពាក្យថា វិចារេហិ ចូរអ្នកពិចារណាមើលត្បូងនេះទៀត ៗ សោ តំ បដិគ្គណ្ហិត្វា ជោតិកមាណព ទទួលអំពីព្រះហស្តព្រះរាជា យកមកពិនិត្យមើលហើយទូលថា រីត្បូង ១ នេះ កើតក្នុងគិរិវិបុលបពិត, ត្បូង ១ នេះ កើតនៅនាពិភពនាគ, ត្បូង ១ នេះ កើតនៅនាផ្ទៃព្រះធរណី· រីត្បូងទាំង ៣ នេះ គិតតម្លៃជាមាស ១ សែនដំឡឹង; មួយសោត ត្បូងដែលកើតនាផ្ទៃព្រះធរណី មានគុណប្រសើរលើសត្បូងទាំង ២ ៗ ពួករាជទូតត្រុះហើយសួរថា ឱចៅមាណព! ហេតុដូចម្តេច បានជាត្បូងកើតនៅនាផ្ទៃព្រះធរណី មានគុណប្រសើរលើសត្បូងទាំងពីរ ៗ ជោតិកមាណពឆ្លើយថា ម្នាលរាជទូត? ត្បូងដែលកើតក្នុងគិរិវិបុលបពិតនេះ ជារបស់ប្រើប្រាស់សំរាប់ស្តេចចក្រពត្រាធិរាជ មានសិរីសួស្តី ជារបស់សំរាប់បំបាត់ទុក្ខចង្រៃផ្សេងៗ , ត្បូងដែលកើតនៅពិភពនាគនោះ ជាគ្រឿងធ្មប់អក្ខរ មានសិរីសួស្តីបំបាត់ទុក្ខស្រួលទៅ បើតុះផងភ្លើងទឹងកើតទោសទុក្ខទប្រពៃចង្រៃផ្សេង ៗ, រីត្បូងកើតនាផ្ទៃព្រះធរណី មានគុណប្រសើរលើសត្បូងទាំងពីរ ព្រោះជារបស់កើតពីផ្សាលាក្លាយ

ពីខ្សាច់យ៉ាងត្រជាក់បំផុត មួយ សាកទីដែលកើតនោះមានដំណៅក្រៃលែង តោះកំដៅថ្ងៃក្តី ខ្យល់ក្តី ភ្លៀងក្តី ពុំអាចប៉ះពាល់បានឡើយ, ប្រសិនបើ ទំរណាមួយបានកែវដែលកើតនាផ្ទៃព្រះធរណីនោះ សឹងកើតលាភសក្ការៈទីងសុខសួស្តី ព្រោះឥតគណនា ទើបខ្ញុំហ៊ានពោលថា កែវនេះមានគុណប្រសើរលើសកែវទាំងពីរ គឺ សុត្តា សត្វ នេះ ផុសពពួកទៀត លុះព្រះជាតិកមាណពដោះស្រាយ អាថ៌ប្រស្នាត្រឹមត្រូវដូច្នោះ ក៏ឲ្យពរស័ព្ទសាធុការ បាចសាចនូវមាលភ្ញីផ្កាទិព្វ ព្រមទាំងសំដែងខ្លួន ឲ្យប្រាកដដល់ភ្នែកអ្នកគនរ ៗ មហាជនោ ច ឯពួកមហាជនឃើញហើយ ក៏បន្លឺនូវសំរែកស័ព្ទសាធុការគន្លំពង ៗ ចំណែកខាងព្រះរាជាទ្រង់ត្រាស់ថា ម្នាលរាជទូត! ពាក្យរបស់មាណពនេះ ត្រឹមត្រូវហើយឬ ? ៗ រាជទូតទាំងនោះក្រាបបង្គំទូលថា បពិត្រក្សត្រថ្លៃប្រសើរអើយ ! វពាក្យជាតិកមាណពដោះសានោះ ត្រូវពិតប្រាកដហើយ ៗ ព្រះរាជាមានព្រះរាជហឫទ័យសោមនស្ស ឥតឧបមា ព្រះហស្តាទ្រង់ចាប់ប្រអប់ព្រះទំរង់ហុចទៅជាតិកមាណព ដោយព្រះរាជឱង្ការថា ចូរទៅរករទីកើតត្បូងព្រះទំរង់នេះទៀត ៗ ទៅជាតិកមាណព ទទួលយកព្រះទំរង់ទាំង ៣ មកហើយក្រាបទូលថា បពិត្រមហារាជ ! រត្បូងព្រះទំរង់ ១ នេះ កើតនាជើងភ្នំព្រះសុមេរុរាជ, ព្រះទំរង់ ១ នេះ កើតកង់ភ្នំសុវណ្ណបពិត, ព្រះទំរង់ ១ នេះកើតនៅនាគិរីនាថបពិត ត្បូងព្រះទំរង់ទាំង ៣ នេះ

គិតតម្លៃជាមាស ១ សែនដំឡឹង មួយសោត ត្បូងដែលកើតនាគិរីនាថបពិត
នោះ មានគុណប្រសើរលើសកែវទាំងពីរ ។ គ្រានោះ រាជទូតស្ដាប់ហើយ
សួរថា ត្បូងព្រះទំរង់ដែលកើតនៅនាគិរីនាថបពិត មានគុណប្រសើរលើស
នោះ តើមានប្រការដូចម្ដេច? ។ ជោតិកមាណពឆ្លើយថា អម្ភោ រាជ-
ទូត ម្នាលរាជទូតដ៏ចំរើន ! កែវត្បូងដែលកើតនាដើមភ្នំព្រះសុមេរុរាជនោះ
សឹងប្រដាប់វិចិត្រដោយកែវ ៦ ប្រការ, កែវត្បូងដែលកើតនៅក្នុងភ្នំសុវណ្ណ-
បពិតនោះ សឹងប្រដាប់ដោយមាសដ៏រុងរឿង ជាវិមានសម្រាប់ប្រតិស្ឋាន
នៃទេវតាទាំងឡាយ តែជាទីសំកបពឹងពាក់មិនបាន, ឯត្បូងដែលកើតនៅ
នាគីរីនាថបពិតនោះ ជារត្នប្រសើរក្រៃលែង ហើយជារត្នសំកបឲ្យកើត
លាភសក្ការៈនិងសំកបពឹងពាក់បាន ត្បិតមានបច្ច័យបុណ្យលោកសំដែង
ទុកមកជាច្រើន ។ រាជទូតឮហើយសួរថា ម្នាលនាយសំពៅ! បុណ្យធម៌
នោះតើដូចម្ដេច? ជោតិកមាណពឆ្លើយថា ហន្ទ ហិ ឯះ តា ម្នាល-
ភោ រាជទូតទាំងឡាយអើយ ! ក្នុងកាលមុនឡើយ មានមាណពម្នាក់
ឈ្មោះជោតិកមាណព នៅក្នុងក្រុងរាជគ្រឹះជាមួយមាតាបិតា ។ ឯកស្មឹ
សមយេ ក្នុងថ្ងៃមួយ ជោតិកមាណពនោះ ក៏កាន់ធ្នូចេញចាកផ្ទះលុះលា
យាត្រាទៅកាន់ព្រៃ ប្រយោជន៍ដើម្បីនឹងបាញ់សត្វ ក៏វង្វេងផ្លូវអស់ ៧ ថ្ងៃ
នឹងរកផ្លូវវិលមកផ្ទះពុំបានឡើយ ម៉្លោះហើយជោតិកមាណពត្រាច់រកក្នុង
ព្រៃជ្រៅ ទៅតាមគោចរហានតែម្នាក់ឯង ដើរទៅដល់គិរីនាថបពិត ។

អថខោ គ្រានោះ មានខ្លាធំមួយ ករវេន្ទឯ តដេវត្តា គ្រហឹមគំរាមដ៏មានសំឡេងខ្ញុំខ្ញារ មុខគួរឲ្យខ្លាចមហិមា ស្ទុះលោតមកប្រុងនឹងខាំហែកស៊ី តែពុំអាចចាប់ជោតិកមាណពបានឡើយ សោ តំ ទិស្វា បលាយិត្វា មាណពនោះ លុះឃើញខ្លាលោតមកដូច្នោះ ក៏ភិតភ័យស្ញើបេត់ស្មារតី ស្ទុះរត់ឡើងភ្នំ ហើយអង្គុយនៅស្ងៀម ៗ ឯខ្លាក៏ដេកចាំនៅជើងភ្នំនោះឯង ៗ ជោតិកមាណពអង្គុយសំកុកមិនហ៊ានចុះពីភ្នំនោះឡើយ ៗ អថខោ ភូតគណា តស្ស សទ្ធំ សុត្វា លំដាប់នោះ អស់ពួកទេវតាលុះឮសំឡេងទួញយំ របស់ជោតិកមាណពនោះក៏មានសេចក្តីករុណាអាសូរ ក៏ធ្វើខ្លានោះឲ្យរត់ចេញទៅ; ឯកច្ចេ ទេវា ទេវតាអង្គខ្លះនាំយកអាហារទិព្វមកឲ្យបរិភោគ ឯកច្ចេ ឆាឆា ជលាជលំ ទេវតាអង្គខ្លះ នាំយកផលាផលមកឲ្យ, ឯកច្ចេ ទិព្វាសនំ ទេវតាអង្គខ្លះ នាំយកពូកខ្នើយមកឲ្យ ៗ ឯកច្ចេ រក្ខន្តិ ទេវតាអង្គខ្លះ ចាំរក្សាព្យាបាល, លុះព្រឹកឡើងទេវតាទាំងនោះ នាំយកជោតិកមាណពទៅដាក់នៅក្នុងសួនឧទ្យាននគរពេជគ្រឹះ ឲ្យដេកលើថ្មមង្គលសិលា ហើយឲ្យកែវ៦ប្រការ ទើបផ្តាំថា ហៃចៅជោតិកមាណព! បើអ្នកណាសួរថា អ្នកមកពីណា ? ចូរចៅនិយាយថា ទេវតានាំមក អស់ពួកទេវតាលុះផ្តាំហើយក៏អន្តរធានបាត់ទៅ ៗ តទា បន រាជា

កាលមកាសិ គ្រានោះឯង ព្រះមហាក្សត្រក្រុងរាជគ្រឹះទ្រង់ទិវង្គត ។ ពួកអាមាត្យរាជបុរោហិតជំនុំគ្នាថា ហៃអ្នកនាងទាំងឡាយអើយ ព្រះមហាក្សត្រនៃយើងទាំងឡាយ ទ្រង់ព្រះរាជសុវណ្ណគតទៅហើយ ឥឡូវ ព្រះរាជបុត្រានៃព្រះអង្គក៏គ្មាន នឹងបានក្សត្រអង្គណាសោយរាជ្យតទៅទៀត,ធម្មតាព្រះនគរដែលពុំមានក្សត្រសោយរាជ្យ រមែងវិនាសអន្តរាយពុំខាន ដូច្នោះគួរយើងអធិដ្ឋានផ្សង បុស្សរថលែងទៅស្វែងរកអ្នកមានបុណ្យ នឹងបានជាម្ចាស់ជីវិតនៃយើងទាំងឡាយ គិតគ្នាស្រេចហើយ ក៏លែងបុស្សរថនោះទៅ ។ បុស្សរថក៏ប្រទក្សិណព្រះនគរហើយ ឈមមុខឆ្ពោះទៅកាន់ឧទ្យាន លុះចូលទៅដល់ហើយ ធ្វើប្រទក្សិណថ្មសិលា ហើយឈប់នៅក្បែរបាតជើងនៃជោតិកមាណពនោះ ។ អស់ពួកបុរោហិតនិងអាមាត្យទាំងឡាយឃើញដូច្នោះហើយ ស្រែកប្រាប់គ្នាថា ហៃអស់អ្នកទាំងឡាយអើយ ឥឡូវនេះ មានបុរសម្នាក់ដេកលើគ្រែមនោសិលានេះ ចូរអ្នកទាំងឡាយប្រគំដូរ្យតន្ត្រីឡើង ឲ្យព្រមគ្នាតែម្ដង, បើបុរសនេះឥតបុណ្យ ឥតវាសនា កាលបើឮសូរសព្ទសំឡេងដូរ្យតន្ត្រីកងរំពង ក៏នឹងភ័យផ្អើលរត់ទៅ, បើមានបុណ្យអំណាច ទោះឮសូរស័ព្ទដូរ្យតន្ត្រីប៉ុន្មានក្ដី ពុំអាចភិតភ័យឡើយ អស់មហាជនទាំងនោះ ក៏ប្រគំនូវដូរ្យតន្ត្រី ជមានស័ព្ទសូរនោះទ្រហឹងអឺងកង សោ អភីតោ វ អដ្ឋាសិ ឯចៅជោតិកមាណពនោះ ក៏ពុំអាចភិតភ័យភ្ញាក់ផ្អើលឡើយ សឹងឋិតនៅស្ងៀមដដែល ។ ទើប

បុរោហិតចូលទៅជិត ហើយលើកប្រណាម្យអញ្ជលីអញ្ជើញថា បពិត្រអ្នកមានបុណ្យ យើងទាំងឡាយសូមអញ្ជើញទៅសោយរាជសម្បត្តិបិតនៅព្រះនគរជាសុខសួស្តីហោង ។ ឯចៅជោតិកមាណពក្រោកឡើងអង្គុយតាំងសមាធិលើអាសនៈ ។ បុរោហិតសួរថា កុតោ អាគតោសិ បពិត្រអ្នកដ៏មានបុណ្យ ព្រះអង្គស្តេចហោងមកពីប្រទេសណា ? ។ ជោតិកមាណពថា យើងនេះ គឺពួកទេវតានាំមកដាក់នៅសួនច្បារនេះ ។ គ្រានោះ ពួកអាមាត្យរាជបុរោហិត ក្រាបទូលអញ្ជើញជោតិកមាណពឲ្យឡើងគង់លើបុស្សរថ ដង្ហែនាំចូលទៅកាន់ព្រះនគរអភិសេកជាមួយព្រះរាជធីតាទ្រង់ព្រះនាម ជោតិយរាជទេវី ជាឯកអគ្គមហេសី ។ ឯចៅជោតិកមាណពក៏ឡើងព្រះនាមថា ព្រះបាទជោតិករាជ, ចាប់ដើមតាំងពីនោះមក ព្រះអង្គតែងមានព្រះរាជហឫទ័យសង្គ្រោះដល់អ្នកនគរដោយសង្គហធម៌ ៤ យ៉ាង ទ្រង់គ្រប់គ្រងបាលអាមាត្យរាជបុរោហិត តាមប្រវេណីធម៌ពីបុរាណ, មិនត្រឹមតែប៉ុណ្ណោះ ព្រះអង្គទ្រង់រក្សាទសពិធរាជធម៌ (ធម៌សំរាប់ស្តេច ១០ យ៉ាង) ទៀត ហើយស្តេចនឹកដល់គុណទេវតានៅនាភ្នំគីរីនាថបពិត ស្តេចបានបង្គាប់មហាជនឲ្យទៅតាំងស្រុកនៅទៀបជើងភ្នំគីរីនាថបពិត ឲ្យឈ្មោះថា មហាគ្រាម ហើយឲ្យធ្វើនមស្ការបូជាដល់ទេវតាទាំងឡាយរាល់ឆ្នាំ ពុំដែលខានឡើយ ។ ឯភ្នំនោះ ក៏មានឈ្មោះថា គីរីនាថបពិត តាំងពីពេលនោះមក ។ ហៃរាជទូត!! ហេតុ

មានបុណ្យធម៌មកដូច្នេះ ទើបយើងហ៊ានពោលថា កែវដែលកើតក្នុង ក្កុតិរបតិត ជាកែវមានគុណប្រសើរលើសកែវទាំងពីរនោះឯង ។ កាលដែលជាតិកមាណព សំដែងនូវគុណនៃត្បូងនោះចប់ហើយ , ទៅតាដែលក្រុងស្វេតច្ឆត្រនាំគ្នា ប្រោយពាយនូវរតនបុប្ផាគឺក្រីប្រាក់ក្រីមាស ហើយឲ្យពរសព្ទសាធុការផ្សេង ៗ ចំណែកខាងមហាជនទាំងឡាយ គឺអាមាត្យរាជបុរោហិត សឹងឲ្យសព្ទសាធុការគង់រំពង ៗ ឯរាជទូតទាំង ៣ យកនូវព្រះទំរង់ទាំងអស់ថ្វាយដល់ព្រះបាទពហុលរាជ ថ្វាយបង្គំលាទៅឯកងទ័ពអាត្មារៀងៗ ខ្លួន នាំសេចក្តីទៅក្រាបទូលស្តេចរបស់ខ្លួន តាមដំណើរក្សត្រទាំង ៣ នគរលុះជ្រាបហើយ ក៏ចាត់រាជទូតឲ្យនាំមាស ១អង្គ ១ពាន់ដំឡឹង ទៅជូនជាតិកមាណពនោះ ហើយលើកទ័ពវិលទៅកាន់ព្រះនគរវិញ ៗ ថ្ងៃពីព្រះបាទពហុលរាជ ស្តេចទ្រង់ព្រះចិន្តាថា ព្រះពិធូរអ្នកប្រាជ្ញជាបិតានៃជាតិកមាណពនេះ មានគុណឧបការៈលើអាត្មាអញអនេកអនន្តណាស់ គាត់បានដោះស្រាយនូវសតបទិកបញ្ហា ហាក់ដូចជាគាត់លើករាជសម្បត្តិឲ្យអាត្មាអញ, ក្នុងកាលនោះ បើកុំតែបានពិធូរអ្នកប្រាជ្ញនោះ ព្រះនគរក៏និងវិនាសអន្តរាយ , ចំណែកខាងចៅជាតិកមាណពនេះ ក៏មានប្រាជ្ញាឈ្លាសវៃ ដូចព្រះពិធូរអ្នកប្រាជ្ញដែលជាឪពុកដែរ បានដោះស្រាយនូវមុទ្ទិកប្រស្នារួចឥតទើសទាក់បើកុំតែបានគាត់ នគរអាត្មាអញ មុខជាវិនាសឥតសង្ស័យឡើយ ហើយបើគាត់ចេញពី

ព្រះនគរនេះទៅ ខានសឹកសត្រូវមកដណ្តឹងសួរប្រស្នាដូច្នេះទៀត គោ វិសជ្ជេសូត្រ អ្នកណាឡើយមិនដោះស្រាយបាន, យថា សោ ឆគរម្នា ដូច្នោះ ដើម្បីកុំឲ្យគាត់ចេញពីព្រះនគរនេះបាន គួរអាត្មាអញយកព្រះរាជធីតា ឲ្យជាភរិយាគាត់ចុះ, លុះទ្រង់ព្រះចិន្តាស្រេច ស្តេចយកព្រះរាជធីតា មកប្រដាប់រៀបមង្គលការ ជាមួយ ជាតិកមាណព ។ អបរភាគេ តមកពេលក្រោយ ព្រះរាជាទ្រង់លើកអស់សម្បត្តិទាំងពួងមកប្រគល់ឲ្យព្រះរាជធីតានៃព្រះអង្គ លុះទ្រង់ចាស់ជរាអានរោគាមកបៀតបៀនព្រះកាយក៏សោយព្រះទិវង្គតកំពីមនុស្សលោកនេះបានទៅកើតឯឋានសួគ៌ទេវលោកនាយហោង ។ លំដាប់នោះ អាមាត្យរាជបុរោហិតក៏រណ្តាប់លើកសពសំស្ការព្រះមហាក្សត្របស់ខ្លួនរួចស្រេច ជំនុំគ្នាអភិសេកជាតិ-កមាណព ឲ្យសោយរាជសម្បត្តិ ថ្វាយព្រះនាមថា ព្រះបាទជាតិករាជ ។ តតោ បដ្ឋាយ ចាប់ដើមអំពីថ្ងៃនោះមក ព្រះបាទជាតិកុរាជ តែងរក្សាឧបោសថសីល ក្នុងថ្ងៃ៨កើត ៨ រោច១៥កើត១៥រោច ស្តេចទ្រង់ប្រជុំអស់មហាជនទាំងឡាយ ហើយទេសនាទូន្មាន ដោយព្រះរាជឱង្ការថា ភោ ហៃអ្នកទាំងឡាយដ៏ចំរើន យាវតា ដែលមកប្រជុំគ្នាមានប៉ុន្មាន ៗ ក្តី និស្សាមេថ ចូរប្រុងស្តាប់សំដីសេចក្តីពីរោះណាព្រេងនាយ យេ ច ជនា បុរសបុគ្គលណាមួយ សម្លាប់សត្វបំផ្លាញជីវិតអ្នកដទៃ លួចប្លន់ឆបោកអ្នកដទៃក្តី ប្រព្រឹត្តល្មើសគានទៅលើប្រពន្ធប្តីអ្នកដទៃក្តី

និយាយពាក្យកុហកអ្នកដទៃក្តី ផឹកនូវទឹកស្រវឹង គឺសុរាមេរ័យក្តី បុគ្គលនោះ លុះស្លាប់ពីមនុស្សលោកនេះទៅ រមែងទៅសោយទុក្ខវេទនាក្នុងនរកពុំខាន ។ យេ ច សីលានិ រក្ខន្តិ បើអ្នកណាមួយមានចិត្តគាត់តម្កល់សទ្ធា រក្សាសីលឲ្យបានខ្ជាប់ខ្ជួន លុះអស់អាយុពីមនុស្សនេះទៅ រមែងទៅកើតក្នុងឋានសួគ៌ ទេវលោកនាយហោង, ដូច្នេះ អ្នកទាំងឡាយចូរបបួលគ្នាធ្វើការកុសល ទានា និការេថ ចូរវៀរចាកបាប ទុច្ចរិតានិ បជហាថ ចូរលះលែងនូវអំពើទុច្ចរិត ។ ឥតិ រាជា ឱវទិត្វា ព្រះបរមក្សត្រាធិរាជទ្រង់ទូន្មានអស់មនុស្សម្នា មហាជនទាំងពួងយ៉ាងនេះ ឯខ្លួនព្រះអង្គសោតទ្រង់ប្រព្រឹត្តនូវទសពិធរាជធម៌ ពុំមានព្រះរាជហឫទ័យកាយមាយឡើយ ព្រះអង្គទ្រង់សង្គ្រោះមហាជនដោយសង្គហវត្ថុ ៤ប្រការ, ព្រះកិត្តិនាមរបស់ព្រះអង្គតែងប្រាកដទៅក្នុងសកលលោក ។ ឯស្តេចសាមន្តរាជក្នុងជម្ពូទ្វីប លុះជ្រាបមានដូច្នេះ តែងមានចិត្តត្រេកអរសាទរ ខ្លាចនូវអំណាចគ្រប់ ៗ អង្គ សុំនាំគ្រឿងសក្ការៈផ្សេងៗ មកថ្វាយ ។ តតោ បដ្ឋាយ ចាប់ដើមតាំងពីថ្ងៃដែលព្រះបាទធោតករាជ សោយរាជសម្បត្តិមក សុភិក្ខំ ស្រូវក្ដីល្អបរិបូណ៌ក៏ជោគ អន្តរាយា សេចក្តីអន្តរាយដោយហេតុណាមួយក៏ពុំមាន ប្រជារាស្ត្រទាំងឡាយសឹងនៅជាសុខសប្បាយគ្រប់ ៗ គ្នា ។

ឥតិ សុរតោ សោរតិសទ្ធោ ព្រះបរមរាជាធិរាជទ្រង់ព្រះ

នាមសុវេត កាលបើនាំមកនូវឧទាហរណ៍ ដូច្នេះហើយ ស្ដេចទ្រង់ទេសនាគាថាថា អសេវនា ច ពាលានំ បណ្ឌិតានញ្ច សេវនា ការមិនសេពគប់នឹងមនុស្សពាល ១ ការសេពគប់នឹងបណ្ឌិត ១ ទាំងពីរនេះជាមង្គលឧត្តម, អ្នកប្រាជ្ញទាំងឡាយមានព្រះសម្ពុទ្ធជាដើម តែងសរសើរយ៉ាងក្រៃលែង, អន្តរាយ រឺសេចក្ដីអន្តរាយទាំងពួង ពុំមានឡើយ ដូចព្រះបាទពហុលរាជ បានស្ម័គ្រសមាគមនឹងពិធួរអ្នកប្រាជ្ញនូវជាតិកទា-ណាព សឹងបានសុខសួស្ដី និរាសទុក្ខភ័យ ។ ព្រោះហេតុនោះ បុគ្គលគ្រប់រូប គួរតែស្ម័គ្រសមាគម ជាមួយនឹងបណ្ឌិតកុំខាន ។ យ៉ាងនារីបណ្ឌិតា ឥត្ថី ស្ត្រីណាមួយ ជាបណ្ឌិតប្រតិពល គួរបុគ្គលស្ម័គ្រសមាគម ដូចស្រីម្នាក់ជាស្រីស្នំរបស់ព្រះមហាក្សត្រាធិរាជ ដែលមានព្រះរាជហឫទ័យសហ៊ចសាហាវ ។ រីនាងនោះមានបុណ្យមានប្រាជ្ញាច្រើន, តាកុសលា ជាស្ត្រីឈ្លាស ចេះនិយាយសំដីពីរោះ ចេះទូន្មានព្រះមហាក្សត្រនោះបាន ដោយពាក្យរបស់នាង ។ ព្រះសាស្ដាត្រាស់ដូច្នោះហើយ ទ្រង់នាំមកនូវអតីតនិទានពីព្រេងនាយមកសំដែងថា អតីតេ ឯកស្មិំ ឆតរេ ក្នុងកាលដែលកន្លងទៅហើយ មានព្រះមហាក្សត្រាធិរាជមួយព្រះអង្គ ទ្រង់ព្រះនាម ចន្ទរាជ សោយរាជសម្បត្តិនៅនគរមួយមាននាមពុំប្រាកដ ព្រះអង្គមានព្រះរាជហឫទ័យកាចសាហាវមហិមា គោរាចរសគោ លុះដោយសេចក្ដីក្រោធ តែងសម្លាប់អស់ស្រីស្នំមេនំ

ពលៀរពល់ ថ្ងៃ ពុំដែលខានឡើយ ៗ ឯស្រីស្នំដែលចូលបំរើដោយតាម
គុណ បើគាប់ព្រះរាជហឫទ័យក៏បានរួចខ្លួន បើមិនគាប់ព្រះរាជហឫទ័យ
ទេ តែងសម្លាប់ចោលចេញ ៗ ព្រះអង្គតែងពិឃាតស្រីស្នំបែបនេះចួន
កាល ១ ចួនកាល ២-៣-៤ ។ បពិត្រអើយ ! ក្នុងកាលនោះ មានស្រី
ស្នំម្នាក់ មានប្រាជ្ញាឈ្លាសវៃយល់សេចក្ដីគាប់ខុស លុះមកដល់វេនរបស់
នាងក៏គិតថា កឹ ការោមិ ឱអញ! គិតបំរើដូចម្ដេច ? កឹ ការេមិ
ស្រង់ដូចម្ដេច? ចិន្តយិស្សាមិ គិតដូចម្ដេច? កឹ ជីវិតំ អញនឹង
រក្សាជីវិតដូចម្ដេច, បើដូច្នេះ គួរអញនាំនិទានផ្សេងៗមកនិយាយថ្វាយ
ទើបល្អ លុះដល់ពេលល្ងាចក៏ចូលទៅគាល់ បន្ទាប់មក ដល់យាមទី១ ក៏
ក្រាបទូលថា បពិត្រព្រះអង្គដ៏មានគុណធំ ខ្ញុំម្ចាស់បានស្ដាប់និទានមួយ
តុម្ហាកំ តំ ការេស្សាមិ ខ្ញុំម្ចាស់នឹងនាំរឿងនោះមកថ្វាយព្រះអង្គ
និទាននេះ ជាសុភាសិតថា សម្រាប់ខ្លួនព្រះមហាក្សត្រអំពីបុរាណ
រៀងមក, ហើយព្រះមហាក្សត្រទាំងនោះតែងប្រតិបត្តិតាម ទ្រង់រក្សាអស់
អាណាប្រជានុរាស្ត្រទាំងឡាយ តាមគន្លងធម៌, កិត្តិសព្ទរបស់ព្រះអង្គល្បី
ល្បាញក្រៃលែង យោ ហិ អត្ថោ កតិកោ បើអ្នកណាមួយ
ជាអ្នកមានចិត្តស្មោះត្រង់ចំពោះព្រះមហាក្សត្រខ្លួន បើដឹងគួរសម ពុំមាន
ចិត្តទ្រុស្តមិត្រ, អ្នកនោះគួរចិញ្ចឹមឲ្យជារាជអាមាត្យ ដូចជាព្រះបាទ
មាទិត្តរាជ, មួយសោត ព្រះមហាក្សត្រណាចិញ្ចឹមទុករាជអាមាត្យ

មានចិត្តវៀចវេរអកតញ្ញូ ក៏នឹងកើតសេចក្ដីក្ដៅក្រហាយដល់អាណាប្រជានុ-
រាស្ត្រ ដូចព្រះបាទវេស្សរាជ ។ ម្យ៉ាងទៀត ព្រះមហាក្សត្រណាដំកល់
អគ្គមហេសី ត្រូវដំកល់ស្រីឲ្យបានដូចនាងកល្យាណី , បើស្រីឯណាមាន
ចិត្តបើងរើងរូសច្រស្យា ដូចនាងរាជសីហ៍ ឬនាងយក្ខិនី ពុំគួរដំកល់
ជាមហេសីឡើយ ។ សោ ចន្ទោ រាជា ។ ព្រះចៅចន្ទរាជទ្រង់
ព្រះសណ្ដាប់ដូច្នោះហើយ សួរថា រឿងនិទានរបស់នាងកល្យាណីនោះ តើ
មានប្រការដូចម្ដេច ? ។ នាងបុញ្ញាក់ក្រាបទូលថា :

អតីតេ ឃតោ រាជា ក្នុងកាលដែលកន្លងរំលងទៅហើយ
មានព្រះមហាក្សត្រមួយព្រះអង្គទ្រង់ព្រះនាម វេជ្ជាធិតរាជ ពុំមានព្រះ
រាជបុត្រាឡើយ មានតែព្រះរាជបុត្រីមួយព្រះអង្គ ដ៏មានរូបឆោមលោម
ពណ៌ សម្បុរល្អិតល្អ ប្រកបដោយបញ្ចពិធកល្យាណី ហាក់ដូចស្រីទេព
អប្សរកញ្ញា នាស្អាតក្រៃត្រឹស្រស់ស្គួ នាងលីលាយាត្រាយាងយាបដូច
រាជហង្សមាស , ថ្ងៃមួយ នាងចូលទៅគាល់ព្រះវររាជបិតាគង់នៅក្នុងទីដ៏
សមគួរ ។ ព្រះមហាក្សត្រាធិរាជទ្រង់ទតយល់ព្រះរាជធីតាដ៏មានសិរីសួស្ដី
ប្រសើរដូច្នោះ ព្រះអង្គទ្រង់ព្រួយព្រះរាជហឫទ័យថា ព្រះរាជធីតាអញ
នេះ គួរនឹងឲ្យមានស្វាមីហើយ លុះទ្រង់ព្រះចិន្ដាដូច្នោះ ក៏មានព្រះរាជ
ឱង្ការថា ហៃកល្យាណីជាសំឡាញ់បិតា ! បិតាគួរសុះស្វែងរកស្វាមីឲ្យ
កូនហើយ ។ ព្រះនាង លុះឮព្រះរាជបិតាមានព្រះបន្ទូលដូច្នោះ ទ្រង់

ព្រះចិន្តាថា ព្រះរាជកុមារក្នុងជម្ពូទ្វីបនេះ នឹងរកព្រះរាជកុមារណាមាន
ប្រាជ្ញាដូចអាត្មាអញនេះពុំមានសោះ, ឯបុរសអន្ធពាលគប្បីឥតប្រាជ្ញាឥត
បុណ្យវាសនា នោះមានគ្រប់គ្រាក់, បើដូច្នោះ អាត្មាអញកុំនិយាយស្តីនឹង
បុរសដទៃ ទើបជាការល្អ, ចាប់ដើមតាំងពីថ្ងៃនោះមក ព្រះនាងឥតចរចា
នឹងបុរសណាមួយទេ ព្រមទាំងមិនរមិលមើលបុរសទៀតផង ។ ព្រះមហា-
ក្សត្រាធិរាជទ្រង់បង្គាប់រាជអាមាត្យ ឲ្យចារព្រះរាជសារប្រាប់ដល់ស្តេច
ក្នុងជម្ពូទ្វីបថា ភោន្តោ ហៃអស់ស្តេចក្នុងជម្ពូទ្វីបដ៏ចំរើន ! បើអ្នក
ណាមានព្រះរាជបុត្រា ឲ្យរៀបតាក់តែងគ្រឿងប្រដាប់ ដូចទេវតា ហើយ
ជូនព្រះរាជកុមារនោះមក ឲ្យលួងលោមព្រះរាជធីតានៃយើង កាលបើរាជ-
ធីតានៃយើងត្រេកអរស្រដីជាមួយ យើងនឹងអភិសេកព្រះរាជកុមារនោះ
ឲ្យសោយរាជសម្បត្តិតាងយើងហោង លុះតែងព្រះរាជសារស្រេចស្តេច
ឲ្យបោះត្រាហើយ ប្រើរាជទូតឲ្យនាំព្រះរាជសារចេញទៅកាន់នគរផ្សេងៗ
ក្រាបទូលស្តេចទាំងនោះតាមព្រះរាជសារ ។ អស់ស្តេចក្នុងជម្ពូទ្វីបលុះឮព្រះ
រាជសារដូច្នោះ ក៏រៀបប្រដាប់ប្រដាតាក់តែងព្រះរាជបុត្រាដោយខ្លួនទីទៃ ៗ
មានសភាពល្អដូចទេវតា ហើយឲ្យចតុរង្គសេនាហែហម ចោមរោមជា
យសបរិវារ លើកចេញមកតាមគ្នា លុះដល់ព្រះនគរហើយ ក៏បញ្ឈប់កង
ទ័ពនៅខាងក្រៅ ឯព្រះរាជកុមារទាំងនោះ ក៏ទ្រង់គ្រឿងប្រដាប់ចូលមក
គាល់ព្រះបាទវទ្ធមានធិរាជ ជាបិតានៃព្រះនាងគន្ធព្រហ្មណី ។ ព្រះមហា

ក្សត្រាធិរាជមានព្រះបន្ទូលថា ភោន្តោ ហៃអស់ព្រះរាជកុមារទាំងឡាយដ៏ចំរើន! យោ មម ជីវិតំ អនុរក្ខស្សេតិ ព្រះរាជកុមារណាមួយអាចធ្វើធីតាខៃយើងឲ្យគ្រប់ស្រួលត្រេកត្រអាល ឲ្យសើចញញឹម ឬស្រដីជាមួយបក្តី យើងនឹងអភិសេកព្រះរាជធីតាខៃយើង ជាមួយព្រះរាជកុមារនោះ ហើយឲ្យសោយរាជសម្បត្តិសួនយើងហោង ។ ឯព្រះរាជកុមារទាំងឡាយ ថ្វាយបង្គំហើយ ក៏ឡើងទៅកាន់មហាប្រាសាទនៃព្រះនាងកល្យាណី ចូលទៅស្រដីលួងលោមដោយកលឧបាយរៀងរាល់អង្គ ។ ព្រះនាងឥតមានព្រះរាជសវនីយ៍ សូម្បីមួយម៉ាត់សោះ ។ ព្រះរាជកុមារខ្លះធ្វើព្យាយាមបាន ១ យាម អង្គខ្លះបាន ២ យាម អង្គខ្លះបាន៣ យាម អង្គខ្លះទៀតបាន ៤ យាម ព្រះនាងពុំស្រដីផងឡើយ ។ លំដាប់មក ព្រះរាជកុមារអង្គខ្លះ ក៏តាំងព្យាយាមលួងលោមតទៅទៀត អង្គខ្លះបាន ១០ ថ្ងៃ អង្គខ្លះបាន ១ ខែ អង្គខ្លះបាន ៣ ខែ ។ ព្រះរាជធីតាឥតញញឹម ឬចរចាជាមួយផងឡើយ ។ ព្រះរាជកុមារទាំងនោះ ពាល់ចំណេះរាល់ៗព្រះអង្គ; នាំគ្នាចូលទៅគាល់ព្រះបាទវេច្ចមារជិតរាជ ក្រាបថ្វាយបង្គំលាទៅកាន់នគររៀងៗវិញ ។ រឿងនេះពុំបាត់ស្ងាត់ឡើយ ឮខ្ចរទៅក្នុងសកលជម្ពូទ្វីប ។

ក្នុងកាលនោះ មានព្រះមហាក្សត្រមួយព្រះអង្គសោយរាជ្យនៅអញ្ញ-តនគរ មានព្រះរាជបុត្រាព្រះនាមវេច្ចកុមារ បានរៀនសិល្បសាស្ត្រ ១៨

ប្រការនេះស្កាត់បរិបូណ៌ ។ ព្រះរាជកុមារ បានឮថា ព្រះនាងកល្យាណី ដ៏ជាព្រះរាជធីតានៃព្រះបាទវិច្ឆមារជិតរាជ មានរូបឆោមលោមពណ៌ដ៏ល្អ ឥតខ្ចោះត្រង់ណា ពុំបានចរបានឹងបុរសណាមួយ លុះបានឮដូច្នោះ ក៏ទ្រង់ព្រះចិន្តាថា ឃគោ មន្តោ វេទគាគមមួយ ឈ្មោះចិត្តទូរមន្ត គឺមន្តស្រូបទាញ ឬជកចិត្ត, អញមិនទាន់បានរៀននៅឡើយ ឃគោ ហិ មន្តោ វេមន្តនោះឯង អាចបែងចិត្តបានជា ២ រីចិត្តនោះអាចយកទៅដាក់ក្នុងឈើ ឬក្នុងរបស់អ្វីៗ ក៏អាចស្រង់បាន គោ ឃតំ ជាជាតិ វេទ-ណាហ្ន៎! បេះមន្តនេះ លុះទ្រង់ពិចារណាដូច្នោះ ហើយ ក៏បានដឹងច្បាស់ក្នុងព្រះរាជហឫទ័យថា មានតែព្រះមហាឥសីនៅក្នុងព្រៃព្រហិមពាន្ត ទើបចេះ, ក្រៅពីនេះ គ្មានទៅណាចេះឡើយ, បើដូច្នេះ គួរអញទៅរកព្រះមហាឥសីអង្វរគេសូមរៀន លុះរៀនចេះហើយ សឹមអញទៅរកនាងកល្យាណីឯក្រោយ, នាងកល្យាណីនឹងលុះទៅក្នុងអំណាចអញហោង ។ ព្រះរាជកុមារ លុះទ្រង់ពិចារណាស្រេចហើយ ព្រឹកឡើងចូលទៅគាល់ព្រះវររាជបិតាមាតា ក្រាបទូលសូមលាទៅរៀនវិជ្ជាសាស្ត្រនេះ ដោយនាំកូនអាមាត្យម្នាក់ទៅជាមួយផង ឈ្មោះ អុរង្គ គន្ធា ដើរទៅកាន់ព្រៃហិមពាន្ត ហើយចូលទៅកាន់សំណាក់តាបសឫសី ថ្វាយបង្គំសូមការស្រ័យនៅ ឃគោ ហាឡិហំ កុមារតាំងពីប្រតិបត្តិតាបសឫសី ១ ថ្ងៃ ២ ថ្ងៃ ទើបអង្វរសូមរៀនមន្តនោះថា គន្ធេ មមំ អនុគាមេវ្យជ បពិត្រព្រះតាបសដ៏

មានគុណធ្ងន់ សូមអម្ចាស់អនុគ្រោះប្រោសប្រណីដល់ខ្ញុំ ។ ខ្ញុំសូមរៀនចិត្តមន្ត សូមអម្ចាស់ប្រដៅមន្តនោះ ដល់យើងខ្ញុំទាំងពីរនាក់នេះហោង ៗ តាបសប្រាប់ថា ម្នាលកុមារ ! មន្តនោះ គួរចេះតែម្នាក់ឯង ទើបជាការល្អ ។ ព្រះរាជកុមារអង្វរសូមរៀនទាំងពីរនាក់ អស់វារៈ ៣ ដង ៗ តាបសពុំព្រមឡើយ ។ ទើបព្រះរាជកុមារអង្វរថា បពិត្រតាបស ! កុមារនេះ ជាបំឡាញ់ទីនៃខ្ញុំអម្ចាស់ ជាអ្នកធ្លាប់លេងល្បែងជាមួយគ្នាតាំងពីនៅជាកុមារតូចៗ, ហេតុដូច្នោះ សូមអម្ចាស់ប្រដៅយើងខ្ញុំទាំងពីរនាក់នេះផងទាន ។ ឯតាបសបានឮពាក្យដូច្នោះហើយ ក៏ប្រដៅចិត្តមន្តដល់កុមារទាំងពីរ ៗ ព្រះរាជកុមាររៀនចប់សព្វគ្រប់ហើយ ទើបនមស្ការក្រាបថ្វាយបង្គំលាមកនគរ ចូលទៅក្រាបថ្វាយបង្គំសម្តេចព្រះរាជបិតាមាតា ហើយទូលលាទៅឯនគរនៃព្រះបាទវេច្ចមារជិតរាជ ។ ព្រះបិតាព្រះមាតាក៏ព្រមអនុញ្ញាត ឲ្យព្រះរាជកុមារតាមសេចក្តីសុំ ហើយប្រដាប់ចតុរង្គសេនាយោធាជាច្រើន ។ ឯព្រះរាជកុមារក៏ប្រដាប់គ្រឿងបញ្ចកកុធភណ្ឌ ឡើងគង់លើរាជរថដ៏ប្រសើរ បរចេញពីព្រះនគរតាមលំដាប់មាគ៌ា លុះដល់នគរព្រះបាទវេច្ចមារជិតរាជនោះហើយ ស្តេចដាក់កងទ័ពនៅខាងក្រៅ ទើបប្រើរាជទូតចូលទៅក្រាបទូលថា ខ្ញុំអម្ចាស់ឈ្មោះចៅវេច្ចកុមារ ជាព្រះរាជបុត្រចូលមកថ្វាយបង្គំបានព្រះរាជធីតា ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# អក្សរសាស្ត្រខ្មែរក្រោយសម័យអង្គរ

លោក ស៊ុន-ហ៊ិន រៀបរៀង

---

ក្រោយពីសម័យអង្គររុងរឿង ខាងសិល្បៈល្បីល្បាញក្នុងសាកល-លោក, ប្រទេសខ្មែរយើងបានជួបប្រទះនឹងសង្គ្រាមជាញឹកញាប់ ដោយមានចម្បាំងរាំងរាល់ នឹងប្រទេសជិតខាងផង ច្បាំងដណ្ដើមរាជ្យគ្នាក្នុងស្រុកផង ៗ ក្នុងរយៈកើតសង្គ្រាមដូច្នេះ ប្រជាពលរដ្ឋយើង ត្រូវតែគេចវេះ រត់ទ័ព រត់សឹក ឬត្រូវកេណ្ឌធ្វើជាទាហាន ៗ

ខាងសិល្បៈដែលធ្លាប់ល្បីល្បាញមក ក៏ពុំឃើញមានសកម្មភាពអ្វីធំដុំឡើយ ៗ បុរាណវត្ថុធំៗ នៅសម័យអង្គរបានលុបលាយបាត់បង់ទៅវិញ នឹងបានកប់ចោលនៅក្នុងព្រៃជាចំណីរុក្ខជាតិ ហើយពុំសូវមាននរណាដឹងឃើញផងទេ ៗ ខាងសាសនា ប្រជាពលរដ្ឋខ្មែរយើងនៅប្រកាន់ជឿព្រះពុទ្ធសាសនាយ៉ាងមុតមាំ ៗ

ចំណែកខាងអក្សរសាស្ត្រវិញ កវីជំនាញ ៗ ក្នុងសម័យលង្វែកនឹងឧត្តុង្គ ច្រើនតែដកស្រង់រឿងពីគម្ពីរពុទ្ធសាសនាមានរឿងទសជាតក៍ ដែលនិទានពីកំណើតព្រះពុទ្ធ ១០ ជាតិ កាលនៅជាព្រះពោធិសត្វជាដើម, ក្រៅពីនេះ កវីជំនាញជាតិយើង បានខិតខំតុបតែងឡើងនូវសាស្ត្រាល្បែង

និងសាស្ត្រច្បាប់ទាំងឡាយជាច្រើនរឿងច្រើនច្បាប់ មានច្បាប់ក្រម, កេរ្តិ៍កាល, កូនចៅ, ត្រៃនេតិជាដើម និងរឿងព្រេងដែលនិយាយត ៗ គ្នាមក មានរឿងអាឡៅ, អាខ្វាក់អាខ្វិន, សុភាទន្សាយ, ធនញ្ជ័យបណ្ឌិតជាដើម ៗ តែរឿងទាំងអស់នោះ ពុំឃើញមានដាក់ឈ្មោះកវីនិពន្ធ និងកាលបរិច្ឆេទនៃការសរសេររៀបរៀង នៅក្នុងពេលណាផងឡើយ ៗ

ចំពោះព្រឹត្តិការណ៍នៃនាមកវីនិពន្ធ, កាលបរិច្ឆេទ, រជ្ជកាលនៃប្រភពអក្សរសាស្ត្រ នៅលើសាស្ត្រច្បាប់ សាស្ត្រល្បែង និងរឿងព្រេងទាំងអស់នោះ ដោយពុំមានគោលបានដាក់ ហេតុដូច្នេះ, យើងជាអ្នកស្រាវជ្រាវអក្សរសាស្ត្រមួយរូប សូមផ្ញើនូវគំនិតការស្រាវជ្រាវអក្សរសាស្ត្រទាំងអស់នោះ ចំពោះអស់លោក-អ្នកអក្សរសាស្ត្រទាំងឡាយ សុំឲ្យជួយស្រាវជ្រាវរកឫសគល់អក្សរសាស្ត្រនោះ ឲ្យមានគោលបានដាក់លាក់ឡើង ជូនជនរួមជាតិយើង, ដើម្បីនឹងលំអ ឫសម្រស់នៃសាស្ត្រច្បាប់រឿងទាំងអស់នោះ ឲ្យមានលក្ខណៈគ្រប់គ្រាន់ ទៅជាមតិកអក្សរ-សាស្ត្រ សម្រាប់សិក្សាកូនខ្មែរ ក្នុងព្រះរាជអាណាចក្រតទៅ ៗ

មុននឹងពិនិត្យមើលអក្សរសាស្ត្រខ្មែរយើងសម័យនោះ ដែលមានអត្តរសដូចម្ដេច យើងសូមធ្វើអត្ថាធិប្បាយអំពីរបៀបការសិក្សានៅសម័យនោះបន្តិច ដូចតទៅនេះ ៖

ក) នៅសម័យនោះរបៀបការសិក្សា, កូនខ្មែរយើងភេទប្រុស អាយុ ៩ ឬ ១០ ឆ្នាំបានចូលទៅនៅវត្ត, ទៅបំរើលោកគ្រូ ដាំទឹក ដងទឹក ពុះអុស តាមលោកគ្រូទៅសូត្រមន្ត ទៅឆាន់ ទៅទេសនា ។ ការរៀនសូត្រ ពុំសូវមានពេលម៉ោងម៉ត់ចត់ទេ , ក្មេងនៅជាមួយលោកគ្រូទាំងអស់នោះ ក្មេងណាដែលយកចិត្តទុកដាក់ជាងគេ ក៏ចាប់បានចេះមើលជាប់ ចេះសរសេរទៅបានខ្លះ ។ គេសង្កេតឃើញក្មេងដែលចេះរៀនចាំមាត់ហូរហៃ តែមើលអក្សរ ឬសរសេរផងមិនកើតក៏មាន ។

ដល់អាយុ១៥-១៦ឆ្នាំ ក្មេងនោះក៏បានប្រែភេទចូលទៅបួសជាសាមណេរ បាន ៥-៦ ឆ្នាំ ក៏បានបួសជាភិក្ខុភាព ឬឃ្លាយក៏សឹកមករៀបចំផ្ទះសម្បែងប្រពន្ធកូនវិញ ។ បណ្ឌិតទាំងនោះ មានខ្លះមកប្រកបការធ្វើស្រែ ខ្លះទៀតក៏បានទៅជាប់គុនបុណ្យស័ក្តិ បានធ្វើស្មៀនស្មេរមន្ត្រីជាច្រើន អ្នកដែលសង្វាតរៀនសូត្រក៏បានចេះដឹងជ្រៅជ្រះដែរ ដោយខ្លះបានទៅរៀនទៅប្រទេសថៃ ។

ខ) គ្រូអាចារ្យនៅសម័យនោះ, វត្តលោកសង្ឃជាសាលារៀន ដោយលោកសង្ឃធ្វើជាគ្រូបង្រៀន ។ លោកសង្ឃជាអ្នកចេះដឹងជាងគេក្នុងជំបន់ស្រែចម្ការ លោកច្រើនទេសនាផ្សាយព្រះពុទ្ធសាសនាពីរឿងធម៌អាថ៌ ដែលសំដែងពីឋានសួគ៌និព្វានឲ្យពុទ្ធបរិស័ទជឿកម្មផលពីបុព្វ ។ ក្រៅពីនេះ លោកបានផ្សាយបង្រៀនជាជំពូក នូវសាស្ត្រាច្បាប់ក្រម,

គេរគាល, ពាក្យចាស់, សាស្ត្រាល្បែងៈ ហង្សយន្ត, ស័ង្ខសិល្បជ័យ, មរណមាតា, ជិនវង្ស, លក្ខណវង្សជាដើម ។

គ) កម្មវិធីសិក្សាកូនខ្មែរនៅសម័យនោះ ច្រើនជួបប្រទះស្ទើរតែគ្រប់គ្នា នូវការរៀនសូត្រវិជ្ជាផ្សេងៗដូចតទៅនេះ ៖

១- រៀនមន្តអាគមអូមអាមស្នេហ៍ និងរបៀនផ្សេងៗដូចរៀនធ្វើគ្រូហ្មធំពិសពស់ ពិសខ្ទួយ ពិសត្រីឈ្លោនជាដើម ដែលជាការពុំសមហេតុសមផល ចំពោះយើងក្នុងសម័យនេះ ។

២- រៀនធ្វើហោរទាយកាត់សព្ទ ជាហេតុឲ្យមានពាក្យខ្មែរបុរាណឆ្លើយប្រាប់ថា "កូតនៅហោរ ចោរនៅជាង" ។

៣- រៀនគណិតសាស្ត្រណាស់, មានចំនួនតិចដែលបានរៀនក្បាច់ចិន ហើយច្រើនទន្ទេញមេលេខជាភាសាចិនផង ។ គេរៀនតែលេខបូកគុណសងចែកព្រួលៗជាការចប់, ចំណោទពុំសូវត្រូវរៀនផងឡើយ ។

៤- ខាងអក្សរសាស្ត្រវិញ គេរៀនច្បាប់ក្រម, គេរគាល, កូនចៅច្បាប់ប្រុស, ច្បាប់ស្រី, សាស្ត្រាល្បែងៈ ល្បើកដុច, ហង្សយន្ត, ស័ង្ខសិល្បជ័យ; គម្ពីរទេសន៍ៈ អភិធម្មប្រាំបួនបរិច្ឆេទ, អភិធម្មប្រាំពីរគម្ពីរ, មហាជាតក៍, មហោសថជាតក៍ជាដើម ។ គេរៀនមើលដាច់ ដើរនិយាយប្រាប់គ្នាបានជាការចប់ ។ គេពុំសូវរៀនពិចារណាលើច្បាប់ទាំងអស់នោះ ឲ្យយល់ឃើញច្បាស់លាស់នូវហេតុនិងផលឡើយ ។

ការសិក្សាអក្សរសាស្ត្រខ្មែរសម័យលង្វែកនិងឧត្តុង មានរបៀបដូចបានពណ៌នាមកខាងលើនេះ តែបើពិចារណាយកអត្ថសេនូវប្រភេទនៃអក្សរសាស្ត្រទាំងអស់នោះទៅឃើញថា កវីបណ្ឌិតបុរាណជាតិយើងជំនាន់នោះ បានខិតខំប្រឹងប្រែងនិពន្ធឡើង ដើម្បីបំពេញសតិអារម្មណ៍នឹងកែអផ្សុកនៃប្រជាពលរដ្ឋខ្លួនទៅ ឬដើម្បីធ្វើជាគតិដល់អ្នកមានជីវភាពរស់នៅក្នុងចំណោមណាមួយ និងដើម្បីធ្វើជាគោលច្បាប់ដំបូន្មានខាងសីលធម៌និងវិជ្ជាជីវៈ សម្រាប់ទាញបតិសម្បជញ្ញៈនៃបណ្ដាជនឲ្យភ្ញាក់រឭកគិតទុកដាក់ខ្លួនទៅតាមគោលនៃសម្មាទិដ្ឋិ ។ អក្សរសាស្ត្រទាំងនេះក៏មានមហិទ្ធិឫទ្ធិខ្លាំងណាស់ ចូលផ្សព្វផ្សាយជ្រួតជ្រាបពាសពេញលើផ្ទៃប្រទេស សូម្បីតែសាមញ្ញជននៅទីកៀនគោះបុងកាត់មាត់ញក ក៏បានទទួលរសជាតិអក្សរសាស្ត្រនេះដែរ ។

ហេតុនេះ បានជាព្រះរាជរដ្ឋាភិបាលខ្មែរ ដោយចង់ឲ្យប្រទេសខ្មែរអាចរក្សាទុកបាននូវកេរ្តិ៍មរតក ព្រមទាំងចង់ឲ្យពង្រីកប្រយោជន៍សំខាន់ៗ ដែលកើតឡើងពីអក្សរសាស្ត្របុរាណនិងទំនើប បានបង្កើតឲ្យមានពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត (សាលាបាលីជាន់ខ្ពស់) និងក្រុមពុទ្ធសាសនបណ្ឌិត្យឡើង ; វិជ្ជាឋានទាំងពីរនេះមាននាទីបង្ហាត់បង្រៀននិងដឹកនាំបណ្ដាជនជាតិខ្មែរទាំងគ្រហស្ថទាំងបព្វជិតឲ្យដើរទៅកាន់អារ្យធម៌ដ៏ប្រសើរផ្នែកខាងសាសនានិងអក្សរសាស្ត្របានចំរើនឡើងតាមលំដាប់ ឲ្យយើង

បានឃើញលទ្ធផលជាក់ស្តែងដូចសព្វថ្ងៃនេះ ។

នៅក្រុមពុទ្ធសាសនបណ្ឌិត្យ មិនមែនត្រឹមតែមាននាទីផ្សាយព្រះពុទ្ធសាសនាដោយការរៀបរៀងតែង និងរៀបចំបោះពុម្ពផ្សាយ នូវសៀវភៅផ្លូវលោកផ្លូវធម៌ផ្សេងៗ ច្រើនមុខប៉ុណ្ណោះទេ ថែមទាំងបានបង្កើតឲ្យមានបណ្ណាល័យមួយតម្កល់ទុកនូវមាតិកអក្សរសាស្ត្រ គឺគម្ពីរដីកាសាស្ត្រាវាំង ក្រាំង សៀវភៅក្បួនខ្នាត តម្រាប់តម្រាផ្សេងៗ របស់បុរាណនិងទំនើបជាច្រើន ។ ឯក្បួនច្បាប់អក្សរសាស្ត្រទាំងអស់ ដែលបានមកដំកល់ទុកក្នុងបណ្ណាល័យនេះ គឺបានមកដោយសារសទ្ធារបស់ពួកពុទ្ធ-បរិស័ទខ្លះ បានមកដោយក្រុមពុទ្ធសាសនបណ្ឌិត្យចាត់ភ្នាក់ងារឲ្យទៅកត់ត្រាស្រាវជ្រាវប្រមែប្រមូលតែអំពីវត្តអារាម ភូមិ-ស្រុក តូច ធំនិគម ជនបទនានាក្នុងព្រះរាជអាណាចក្រទាំងមូលខ្លះ ។ ដូច្នេះយើងយល់ឃើញថា បណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ជាឃ្លាំងមួយសម្បូរបំផុតនូវឯកសារមាតិកអក្សរសាស្ត្រខ្មែរបុរាណ សម័យលង្វែកនិងឧត្តុង្គ និងតម្កល់ទុកនូវសៀវភៅក្បួនខ្នាតអក្សរសាស្ត្រទំនើបជាភាសាបរទេសនិងភាសាខ្មែរជាច្រើន ។

សព្វថ្ងៃបណ្ណាល័យនៃពុទ្ធសាសនបណ្ឌិត្យ ដែលបរិបូណ៌ដោយឯកសារអក្សរសាស្ត្រច្រើនយ៉ាងដូច្នោះ បានក្លាយទៅជាបណ្ណាល័យប្រកបអក្សរសាស្ត្រ ជាឃ្លាំងវិជ្ជាជា វិជ្ជាឋាន សម្រាប់ប្រជាពលរដ្ឋនិងកវីនិពន្ធ

ទាំងផ្នែកគ្រហស្ថទាំងផ្នែកបព្វជិត តែងចេញចូលសិក្សា សាកសួរពិគ្រោះរករកក្បួនច្បាប់ក្នុងមន្ទីរនេះជាហូរហែរាល់ថ្ងៃធ្វើការ ។

ជាទីអវសាន, យើងបានធ្វើអត្ថាធិប្បាយវែកញែកអំពីរបៀបការសិក្សាកិច្ចការជាស្នាដៃអ្នកជំនាន់មុន និងពណ៌នាអំពីមតិកអក្សរសាស្ត្រករជំនាញជំនាន់នោះ ដែលមានឯកសារដំកល់ទុកនៅក្នុងបណ្ណាល័យនៃពុទ្ធ-សាសនបណ្ឌិត្យ ជូនជនរួមជាតិស្តាប់អម្បាញ់មិញនេះ ដោយមានបំណងចង់ណែនាំអ្នកមានគំនិតទាំងឡាយ ឲ្យចូលចិត្តស្រឡាញ់អក្សរសាស្ត្រជាតិ ដែលជាកេរ្តិ៍ដំណែលនៃបុព្វបុរសរបស់យើង ព្រមទាំងចង់ឲ្យដឹងនូវដំណើរអក្សរសាស្ត្រពីដើមមកទុកជាគោលសម្រាប់កសាងអក្សរសាស្ត្រថ្មីឲ្យបានចំរើន ហើយឲ្យមានការប្លែកៗផង, នាំឲ្យយើងចេះប្រើការរិះគន់ដើម្បីប្រយោជន៍ដល់ខ្លួនយើង គឺជៀសវាងការក្តាត់ក្តាំង ហើយកត់សំគាល់នូវសេចក្តីល្អត្រូវទុកជាឧទាហរណ៍បទរៀនតទៅអនាគត ។

-ចប់

× ÷ ×

# រឿងសព្វសិទ្ធិ

(តមក)

របស់ហ្មឺនភក្ដីអក្សររ៉ាន់ លោកប៊ូ-ប៊ូ ចំឡងពីសាស្ត្រាស្លឹករឹត

រីឯកូនស្រីនៃចោរនោះ លន់លុះបានឮពាក្យបញ្ជា អាពុកឲ្យរៀបភោជនា ទទួលមិត្រភ្ញាប្រាំមួយគុ ៗ ឲ្យបានឆាប់កុំបីយូរ នាងនឹកគិតគួរនឹងជាទុក ពិភាល់ធ្ងល់ណាស់សែនវិតក្ក ម្តេចអ្នកអាពុកពោលវៀចវេរ ៗ គៀវនៅឯណាមិនយល់ជាក់ ឃើញតែពីរនាក់នឹងគាត់ទេ នឹងសួរឲ្យស្តែងក្រែងគាត់ជេរ នាងគិតគ្នាន់គ្នេរគ្នាញ់ក្នុងចិត្ត ៗ ទើបតែងតាំងតស្ងួដណ្តាំ រួប ហើយចំព្រាំបុកប្រហិត សម្លប្រហើរឆ្ងាញ់ឈ្ងុយឆ្ងិត បាយសែតសឹងស្រិតអង្ករស ៗ ស្រេចហោះដួសដាក់គ្រប់តុតាំង សំរិតសំពាំងសម្រេចល្អ ប្រាំមួយស្តុកលើកឡើងបន្ត តាំងបាយសម្បូរបូណ៌បាន ៗ គ្រានោះនាយចោរជាបិតា ស្រវាំទាញបាយចាប់ដាក់ពាន គ្រប់តាំងប្រាំមួយដោយប្រមាណ យល់មនុស្សមានប្រាណប៉ុណ្ណោះឯង ៗ ហើយហៅទៅនោះបរិភោគ្គា ដោយក្ដីស្នេហាទើបចាំថែង ថាម្នាក់ដែលលាក់ខ្ញុំឃើញស្តែង ខ្លាក់មកកុំក្រែងគិតល្អែងថ្វី ៗ បុរសនោះស្តាប់ស័ព្ទអតិប្រាយ ពីភាល់ធ្ងល់ឆ្ងាយក្រែតតបី អ្នកនេះម្តេចដឹងដល់ដើមក្តី ឬឃើញទេរុំទើបយល់ការណ៍ ៗ គិតហើយហាមាត់ខ្លាក់ប្រពន្ធ មកតាំងអៀនអន់ឲ្យភោគ្គា ទើបចោរសួរទៀតទៅនាងថា ម្នាក់នោះកាលណានឹងខ្លាក់មក

នាងនោះលុះឮគថាហ្នោះ ខញ់ទាល់អែះអុះទើបទាញយក សហាយតី
មាត់ផាក់ជិតស្តក ទីងគេអ្នកឯណាជងថាអ្ហែ ៗ មហាចោរហាហៅកូនក្រមុំ
មកជុំចំពោះពេចខ្ទី លោមថាម្នាលនាងកូនពិសី ចុះប្ដីឯងម្នាក់
លាក់ឯណា ៗ មិនហៅគ្នាមកបរិភោគផង ឲ្យឆ្អែតបានមួងដូចប្រាថ្នា
កូននោះលុះបានឮបិតា អៀនណាស់តែថាទាល់គំនិត ៗ អម្បាលគេ
លាក់ទុកក្នុងមាត់ ម្ដេចតានគងជងជំណើងពិត បើអញខំលាក់គង់មិនជិត
នាងគិតដូច្នោះអស់ប្រាថ្នា ៗ ទើបទាញសហាយចេញពីផ្ទង សក់ដែល
បទបួងឥតសង្កា ទាល់គ្រប់ទាំងប្រាំមួយកាយា នាំគ្នាកោក្ដាទាំងក្រៀម
ក្រំ ៗ ឯនាយចោរនោះគិតសញ្ជឹង រំពឹងរឹងឈឺដូចគេជំ ថាឲ្យអញអើយ
ឥតគេសម ប្រឹងខំចិញ្ចឹមកូនស្ងួរស្ងាប់ ៗ គ្រប់រូបគ្រប់ប្រាណទាំងអស់
គ្នា បង់ឲ្យបានជាត្រូវនឹងច្បាប់ មិនគួរវាប្រែកែក្រឡាប់ មកធ្វើបង្អាប់មុខ
ទាល់បាន ៗ ឯអ្នកសម្លាញ់ពេញដូចគ្នា ស្រឡាញ់ករិយាលើសខ្លួន
ប្រាណ បៀមទុកក្នុងមាត់គិតប្រមាណ ទឹកស្ងួនថាស្មោះចំពោះល្អ ៗ
តែគេមិនត្រង់គង់កែច្នៀត បៀមសហាយទៀតផាតីគេ ខ្ញុំនឹងសម្លាញ់នេះ
ពេញក្រ ត្រដរនឹងស៊ើដាមនុស្សថ្មី ៗ ថាភ្ញាងទើបផ្ដាំកូនស្រីនោះ នៃ
នាងនៅចុះរកប្ដី ឲ្យសុខសម្រាន្តក្សាន្តចិត្តស្រី កុំបីភ័យភិតភិតបិតា ៗ
ថាហើយនាយចោរលោលបគេច ទៅមួយរំពេចដល់បព្វតា ឡើងលើកំ
ពូលស្រេចកាលណា លោតចុះដីវាំកំក្បាលណាក្បាយ ៗ បុរសសម្លាញ់ឃើញ

ចោរស្លាប់ លោទឹកខឹងឆាប់ញ័រជើងដៃ ថាមេនេ មិញពេញចង្រៃ វាប្រែ
កែខៃហួសប្រាជ្ញា ។ បៀមទុកក្នុងមាត់បេញក្បត់បាន ឲ្យប្រាណអង្គអញ
ពេញអសារ រស់នៅអះសាច់ខ្នាស់ខ្មោចថា ស្លាប់តាមបោពប្រសើរគាប់ ។
ថាហើយដើរដល់កំពូលភ្នំ លោតបំភ្នង់ជ្រោះជាប្រញាប់ ធ្លាក់ខ្ទេចផ្ដិល
ផ្ដាច់ជីវិតឆាប់ បុរសនោះស្លាប់តាមបោព ។

ឯកូនក្រមុំនៃនាយចោរ ក៏យស្ដាលោស្ទឹងរំពឹងថា អញនេះខ្វប
ក្រែះក្រៅមាត្រា ចាលតែបំតាមណោជន ។ ព្រោះអញទុច្ចរិតប្រព្រឹត្តខុស
យកប្រុសមកលាក់ធ្វើជាស្នេហ៍ ឯបុរសនោះព្រោះប្រពន្ធ ចិត្តចោរទុជិន
ទើបគាត់ស្លាប់ ។ ខ្លួនអញគិតទៅត្រូវកុំរស់ ជាមនុស្សមានឈ្មោះឥត
សារសព្ទ គិតភ្ញាន់នាន់ឡើងលើភ្នំឆាប់ លោតធ្លាក់ស្លាប់ឆាប់តាមចិន្ដា ។
ឯភរិយាចោរចិត្តមិត្តទ្រុស្ត ឃើញប៉ីនាក់នោះក្ស័យជីវា ក៏យកិតក្នុងចិត្ត
គិតថប់ថា ប្ដីអញមរណាព្រោះខ្លួនអញ ។ ស្រឡាញ់អញណាស់លើស
ខ្លួនគាត់ គាត់បៀមក្នុងមាត់ព្រោះស្រឡាញ់ អញនេះចិត្តជម្ងឺខ្មួរក្នាញ់
រស់នៅបង់ហាញ់ពេញអប្រិយ ។ ព្រោះខ្លួនបានជាធ្វើមិនត្រូវ គិតទៅគួរ
ស្លាប់តាមស្វាមី បង់រស់ថ្វីទៀតបង្អៀតជី ថាហើយឃ្លាតខ្លួនចេញម៉ឺម៉ា ។
ទៅឡើងលើភ្នំកំពូលខ្ពស់ លោតបុះស្លាប់ភ្លាមតាមវេរ ឯចៅសហាយពីរ
អង្គា ឃើញហើយគិតថាដោយតម្រិះ ។ ខ្លួនយើងប្រព្រឹត្តគិតកាមេ
គាល់តែគេខឹងស្លាប់ដូច្នេះ បង់អើយអាក្រក់ក៏ដល់ម៉េះ មិនបេះអាណិតចិត្ត

គេផង ៗ ចំនៅធ្វើអ្វីអប្រិយឈ្មោះ នឹងរស់ជាមនុស្សក៏សៅហ្មង ថាហើយនាំគ្នាដើរត្រសង ប៉ុនប៉ងផ្តិលផ្តាច់ជន្មជីវ៉ា ៗ លុះដល់លើកគ្គិពូលខ្ពស់ លោតបុះក្នុងជ្រោះពីរកាយា ក្សិណក្ស័យប្រល័យសូន្យសង្ខារ នៅដើនបព្វតាប្រាំមួយប្រាណ ៗ ដំណឹងដឹងដល់ទៅដូនចាស់ ជាកប្លាស់គាតតែគិតរំខាន ថាអញជាហេតុប្រាប់ដើមដាន ទើបបានជាគេសហាយគ្នា ៗ មិនតែប៉ុណ្ណោះកើតហេតុគ វេងវឿងអន្ធការងឹងករិយា នៃចៅប្រុសថែមមួយគ្រា ឥឡូវមរណក្ស័យទាំងអស់ ៗ នេះគឺដើមហេតុពីអញឯង សំដែងសំដីកាលមុនស្មោះ ខ្លួនអញរស់នៅមិនគួរសោះ គួរស្លាប់ទៅបុះរស់ធ្វើអ្វី ៗ ថាហើយដូនចាស់គាត់ប្រញាប់ អត់ដង្ហើមស្លាប់រំពេចខ្ញុំ ដំណើររឿងនេះឆ្ងល់សេចក្តី បងពានព្រះស្រីជួយគិតក៏ ៗ អ្នកទាំងប្រាំពីរដែលស្លាប់នោះ បាបកម្មបំពោះបាននរណា ដួងចិត្តក្នុងពានទើបឆ្លើយថា ត្រូវបានកុមារចៅសហាយ ៗ ដែលទៅលបលួចកូនមហាចោរ ព្រោះវាមោហោកគិតឧបាយ នាំហេតុទាល់តែគេទាំងឡាយអន្តរាយស្លាប់អស់ពីព្រោះវា ៗ

កាលនោះក្សត្រីស្រីរូបល្អ សុវណ្ណកេសរពៅពុំងា នាងគិតរំពឹងក្នុងទ័យា យល់ជាពានថាខុសសេចក្តី ៗ នាងទប់ពុំបានមានវាចាតបថាហៃចៅពានព្រះស្រី ម្តេចឡើយគ្រានេះចៅចេះស្តី ស្តីហើយហេតុអ្វីក៏ខុសផង ៗ បើបានជាថាឲ្យត្រូវ ដោយនូវសុចរិតពិត

ជាមុន ម្ដេចគាត់ក្រឡាសចាស់កោណខ្លួន គាត់នោះឯងហោងជាហេតុ ដើម ៗ ប្រាប់គេទៅកាចទីងកូនចោរ ចិត្តគាត់មោហោហាមិនគិតស្មៀម មិនទេពាល់តែកូនគេដើម គេខឹងញ៉ាំងថ្មើមនាំគ្នាស្លាប់ ៗ ផលកម្មបាប ពៀរតាំងទៀរនោះ ត្រូវបានគាត់ស្មោះនេះតាមច្បាប់ ជាក់ច្បាស់ច្នេះឯង មិនក្លែងប្រាប់ ជាថ្វីពោលលំពៀនសត្យា ៗ

គ្រានោះពួកៈក្លែងតែងចាំស្តាប់ ព្រះដ្ឋានពុស័ព្ទខានចំពោះ ឆ្លើយតប សេចក្តីបីបញ្ហា សឹងសោមនស្សពន់ប្រមាណ ៗ ប្រគំត្រៃបន្ទុំសព្ទ អឹង អាប់គងទាំងប្រាសាទសាន ជ្រាបដល់ព្រះកាណាមហាក្សត្រក្សត្ត ទ្រង់ ព្រឹសប្រាណសោមនស្សា ៗ ថ្ងៃតិក្សាក់ឆាជានាយក្រុម នានាំសព្វ. សិទ្ធិវិទ្ធិកា ខិតបូលទៅនៅជិតធីតា ដល់ជិតសន្ធិយាជាជាន់ក្នុង ៗ ទើប ទៅសព្វសិទ្ធិបុទ្ធិក្រែ ដកយកដួងចៃបុទ្ធរង ពីពានព្រះស្រីបញ្ញពុលង់ - ទៅជាក់ក្នុងវង់ព្រះសន្ធិយា ៗ គ្រាន់ជាទុក្ខាយសួរប្រស្រ័យ ជាហៃហង្ស ននមានប្រាជ្ញា ប៉ុន្មាននានមកឧបមា ឲ្យយើងស្តាប់កាសោះង៉ុយដេក ៗ ដ្បិតអ៊ីយូរយល់ដល់យាមបួន កម្មផលវង់ផ្កាកម្មខវិរេក ស្រវេះស្រវោច លន្ទោចពេក គ្រាន់នឹងតែរេកចិត្តខ្វះវ៉ា ៗ គ្រានោះហង្សននជាស់ក្តួងឆ្លើយ ជាម្ចាស់ខ្ញុំអើយខ្ញុំនេះណា មិនអាចបេះពាំនាំបញ្ហា ព្រោះគ្រាន់តែជាហង្ស ននបិទ ៗ សម្រាប់គេចាំងហង្សប៉ុណ្ណោះ រឿងក៏មិនបេះមិនបូលចិត្ត បើម្ចាស់ បេះបាំនាំភាសិត អាណិតនិយាយឲ្យស្តាប់ផង ៗ

កាលនោះក្សត្រីស្រីល្អឯក ឮពាក្យចំឡែកដល់ប្អូន ន ក៏ងននម្តេច រំពេះសាសន៍ ខ្ទួនល្អនឹងនឹងគិតគេក្ដា ៗ ផ្កាលានឹងទ្វារពានព្រះស្រី ស្តីបីដង៍ហើយគួរអស្ចារ្យ ឥឡូវកំនននមានប្រាជ្ញា នឹងចាំដូចម្តេចទៅ ទៀតអេះ ៗ ឯចៅសព្វសិទ្ធិឫទ្ធិមាន រើសរកនិទានតាមតម្រិះ កំននន ចូរចាំស្តាប់រឿងនេះ យើងចេះតាមចាស់លោកអតិប្រាយ ៗ ថាកាល នោះមានស្រីបួនមាក់ ប្រកបនូវល័ក្ខណ៍ក័ក្រូនោមឆាយ សុទ្ធសឹងក្រមុំ សមអង្គកាយ ស្ទះមកពីឆ្ងាយស្វែងរកប្តី ៗ

ជួនមានកៈម៉ោះចាំងបួននាក់ សុទ្ធតែចិត្តស្ម័គ្រចង់បានស្រី ជួបគ្នា វេណានោះឯងខ្ញី គតបសំដីដោយស្នេហា ៗ ប្រុសមួយសួរថាផ្ទះ នាងឯង ទីស្ថានកន្លែងនៅត្រង់ណា នាងមួយទើបប្រាប់ជាប្រស្នា បង្អុលហត្ថាត្រង់ដើងឈ្មេញ ៗ

ប្រុសមួយសួរស្រីមួយទៀតថា ត្រង់ណានាងប្រាប់កុំអម្ចេញ នាង នោះចាប់សក់ខ្ទប់មុខវិញ ថាផ្ទះខ្ញុំមិញនៅត្រង់ណឹង ៗ

ប្រុសម្នាក់សួរស្រីមួយទៀតលង ថាផ្ទះស្រីឈ្មោះត្រង់ណាដឹង នាង នោះសម្ងក់ធ្មេញខសឹង លើកដៃឡើងឆ្កឹងនឹងផ្ទះខ្ញុំ ៗ

ប្រុសក្រោយសួរស្រីក្រោយទៀតថា ផ្ទះនាងត្រង់ណា ៗ មាសម៉ុំ បងសួរជាការល្អស្រុម ចូរកុំបង្វែងវែកកាយថា ៗ នាងនោះបានស្តាប់ ប្រាប់មកវិញ ថាផ្ទះខ្ញុំមិញនៅត្រង់ផ្សារ ទ្រហឹងនោះឯងផ្ទះខ្ញុំណា បើអ្នក

ត្រូវការទៅរកចុះ ៗ បុរសស្រ្តីប្រាំបីប្រាណ លុះបានសួរសាកពាក្យ
សាយសុះ, ដឹងសព្វគ្រប់គ្នាវេលានោះ ស្រេចវិលវិញឆ្ពោះដល់ទីឋានៗ
ឯប្រុសទាំងបួនជូនពាប់ចិត្ត ចង់ស្និទ្ធគិតស្នេហ៍តែគ្រប់ប្រាណ នាំគ្នា
តោក្តាបាយទឹកបាន ស្រេចហើយសូរ្យគានក៏ជួនយប់ ៗ ទើបចរចុះចេញ
ពីគ្រឹហា ស្រួតរូតគ្មានពាឈរឈឺងឈប់ ត្រាច់រកច្រើនសាសុះសព្វ
គ្រប់ តាំងពីព្រលប់លុះយប់ជ្រៅ ៗ មិនដឹងកន្លែងនៅត្រង់ណា ណោ
ណាន់មាត់ថាឲស្រីពៅ បង្អុលប្រាប់បងថានាងនៅ ដើរធ្វេញឥឡូវនៅ
ត្រង់ណា ៗ បងសូះបងស្វែងរកព្រលឹង ម្ល៉េះហើយសមទឹងក្ស័យជីវ៉
ឯនាងមួយដែលយកហត្ថា មកខ្ទប់កញ្ញានោះក៏ធ្លល់ ៗ មិនដឹងបើទឹងកាត់
ដូចម្តេច ខំត្រាច់តែដើរស្វែរដាច់ខ្យល់ គំនិតដែលគិតក៏ពុំដល់ ពុំដឹង
កិច្ចកលអាថ៌ប្រស្នា ៗ នាងមួយថាផ្ទះនៅត្រង់ដៃ វែតតែសន្សំយខ្ញុំប្រាជ្ញា
នាងមួយថាផ្ទះនៅត្រង់ផ្សារ ទ្រហឹងនោះណាវែតតែក្រ ៗ ឥទ្រួង
យើងអើយវឹងវែងខាន យ៉ាងនេះអស់បាននាងរូបល្អ បបួលគ្នាដើរស្វែរខះក
ប្រហទាំងមាត់ហត់ហៀបស្លាប់ ៗ មិនដឹងបើទៅរកត្រង់ណា ខ្លះថា
អង្កាលដែលគេប្រាប់ ប្រឹងគិតណាស់ដែរតែឥតស័ព្ទ ប្រាជ្ញាវាអាប់
ស្លាប់មិនបាន ៗ ខ្លះថាកាលយប់មិញព្រលឹម ៗ ប្រញាប់តែវិលមកទី
ឋាន មិនទៅឲ្យជាប់ជាមួយប្រាណ ខ្លះថាឯងស្មានជាមិនអី ៗ ខ្លះ
លើកទំនៀមមកប្រាប់ប្រែ គេថាធ្វើស្រែទាន់ក្តៅដី ស្ងៃផ្ទរនាងទាន់នៅខ្ចី

បើនឹងចង់ស្រីតាន់តោចិត្ត ៗ អណ្ដើកនៅមុខចាំក្ដក់ក្ដៃ គិតទៅត្រូវតែគួរកុំស្បៀត ទឹងឲ្យនរណាជួយអាណិត នេះដៀតគំនិតខ្លួនឯងទេ ៗ បុរសប្អូននាក់ហាក់ខ្លួនទៅ ដើរទៅដើរមករកគ្នាន់ក្នេ ទឹកក្នាញ់ក្នុងចិត្តគិតទឹងជេរ តាល់តែទៅទៀបផ្ទះសេដ្ឋី ៗ មួយមានធនធានច្រើនពេកក្ដាត់ គេប្រុងប្រយ័ត្នជាប្រក្រតី តាំងបង្គាប់ប្រាប់ទុក្ខទោសប្រុសស្រី វេលារាត្រីដើរពុំបាន ៗ ថាបើខំដើរខុសវេលា អស់ពួកឆ្មាំទ្វារវាចាប់ប្រាណ មិនចាំសួរសោករកដើមដាន ព្រួតចាប់យកប្រាណក្នាងទាំងរស់ ៗ នាកាលរាត្រីនោះដៀងជាក់ មានមាណពម្នាក់បរបំពោះ ចូលផ្ទះសេដ្ឋីជួនជាគ្រោះ ពួកឆ្មាំទ្វារនោះចាប់ចងបាន ៗ យកទៅធ្វើទោសក្នាងទាំងយប់ មិនមានសួរសព្វរកដើមដាន ទៅនោះសង្វេគឯកអង្គប្រាណ រំពានទល់ទុក្ខទោមនស្ស ៗ

ថ្ងៃពីបុរសតាំងប្អូននាក់ ស្វែងស្វាក់តាមស្រីដែលសញ្ញា បានឃើញអ្នកទោសត្រូវទុក្ខា នាំគ្នាយាត្រាទៅជិតខ្ទី ៗ អ្នកទោសឃើញចៅតាំងប្អូននាក់ មកជិតយល់ជាក់ទើបស្រដី ថានាកដំណើរដើររកអ្វី ចូរប្រាប់សេចក្ដីខ្ញុំផងក៏ ៗ បុរសតាំងប្អូនឮពាក្យពិត ដោយគិតទឹកស្រីណាស់ទើបថា យើងនេះឆាតនៅឡើយប្រាថ្នា រកអាចប្រស្នាស្រីពុំយល់ ៗ ស្រីមួយថាផ្ទះគេនោះមិញ នៅត្រង់ជើងធ្នេញគួរឲ្យធ្ងល់ ប្រាថ្នាយើងនេះបេះមិនដល់ បានជាអំពល់ចិត្តណាស់ណា ៗ ស្រី

មួយបាច់សក់ខ្ទប់មុខចុះ ថាផ្ទះត្រង់ណោះគួរសង្កា ស្រីមួយប្រាប់ឯង
ឋង្វៀនថា ផ្ទះគេនោះណានៅត្រង់ដៃ ៗ ស្រីមួយថាផ្ទះនៅត្រង់ផ្សារ
ទ្រហឹងអ្វីអាតែសព្វថ្ងៃ នេះតើរឹងធ្លល់ពិតាល់ក្រៃ បេះតែអាល័យទ្រូងស៊ើរ
ប្រេះ ៗ ប្រឹងដើរជ្រែករកសព្វប្រក គ្រប់ល្ហកកៀនកោះក៏មិនផេះ
បានជាវង្វេងមកតាំងម៉េះ ពាក្យនេះអ្នកបេះដឹងដែរឬ ? ៗ អ្នកទោស
កំពុងតែស្រេកទឹក លោទឹកឃើញភ្នាមស្តីតាំងឈឺ ប្រាប់ថាពាក្យនោះខ្ញុំ
ធ្លាប់ឮ មិនគឺមិនគួរទេងថាក្រៃ ៗ តែស្រេកទឹកណាស់ហួសប្រមាណ
ទឹងប្រាប់ពុំបានដឿតខះក បើអ្នកអាណិតចិត្តស្មោះសរ ឲ្យទឹកខ្ញុំអរគុណ
ណាស់ណា ៗ ធុរៈផង់អ្នកៗកុំព្រួយ ឆានាខ្ញុំជួយដោះប្រស្នា បុរស
បួនប្រាណបុនឮថា គេមានប្រាជ្ញាកលទបាយ ៗ ហើយយកទឹកមក
ឲ្យមាណព ផឹករួចសព្វគ្រប់ទើបអភិប្រាយ ថាអ្នកអាណិតគិតដោះស្រាយ
ឲ្យយើងទាំងឡាយបានរួចចិត្ត ៗ មាណពបានស្តាប់ប្រាប់មកវិញ ផ្ទះ
ត្រង់ដើងធ្មេញនោះព្រោះដឿត ខាងមុខលំនៅទីស្ថានស្និត ធ្មេញត្រីជុះ
ជិតៗរបង ៗ ទឹង ហើយជាផ្ទះដែលនាងនៅ អ្នកទៅតង់រកឃើញជាម្តង
នាងមួយដែលបាច់សក់បំណង ខ្ទប់មុខនោះហោងក៏ថាត្រូវ ៗ គឺផ្ទះ
នាងនៅជាខាងក្នុង ដើមដៃជ្រសំយ៉ុងប្រេបរងស្បូវ ជុះពន្ធជុំវិញនោះ
ឯងក្បូវ អ្នកដើរតាមផ្លូវនេះទៅចុះ ៗ នាងមួយដែលលើកដៃឡើងច្ពង
កិច្ចនោះខ្ញុំដឹងថាមិនខុស មុខផ្ទះមានដើមដៃខ្លាជុះ នាងនៅត្រង់ណោះ

ប្រាកដជាក់ ៗ មួយថាផ្ទះនៅផ្សារទ្រំហ៊ង ស័ព្ទសូរអឺអឹងមិនដែលអាក់ គឹគុម្ពចុស្បែចាបសំណាក់ ពឹងពាក់ធ្វើជាសំបុកពង ៗ នៅព័ទ្ធជុំវិញ ផ្ទះនាងនោះ អ្នកទៅរកចុះតាមគន្លង បើឃើញកន្ទកាគជាទំនង កុំហួសរម្លងចូលទៅចុះ ៗ បុរសប្អូនប្រាណបានស្តាប់ច្បាស់ ក្រេកអរពេកណាស់ព្រួចព្រឺច្រុះ ដូចជួបជួនតែរឹទ្ធិផ្ទុះ នាំគ្នាស្រួលប្រុះបុះចេញចរ ៗ វិលមករកផ្ទះរបស់ឯង ឡើងលើកខ្ទែងមិនមាត់ក ដេកលក់ព្រឹកឡើងរឹងក្រេកអរ នាំគ្នាដើរស្រួស្រួតទៅរក លុះយល់កន្ទកាគជាក់ចូលភ្នាម ឃើញតាមពាក្យដែលគេប្រាប់មក គ្រប់ទាំងប្អូននាក់គួបឥកក្អក ទើបតែលៃលកគិតបែបផង់ ៗ

ឯស្រីទាំងប្អូនបានឃើញជាក់ ប្រុសទាំងប្អូននាក់ចូលទៅត្រង់ សួរសាកមកវិញមិនបង្អង់ ថាអ្នកកុំបង់ពាក្យសត្យា ៗ ដែលអ្នករកឃើញផ្ទះយើងនេះ អ្នកមានតម្រិះកាត់ប្រស្នា ឃើញឯងឬត្រូគេចរចា ចូរប្រាប់យើងពីកុំកួតករ ៗ

បុរសប្អូននាក់លុះបានស្តាប់ ឆ្លើយប្រាប់មកវិញថាយើងរក៏ ប្រស្នាទាំងនេះបេះតែវ ដើរទៅដើរមករកមិនយល់ ៗ មិនដឹងនឹងគិតការថាម្តេច ទំព្រាច់ដើរទៅបានជួបចាស់ ជួរទិនអ្នកទោសត្រូវទុក្ខទល់ គេមានះយោបល់ប្រាប់ពត៌មាន ៗ ទើបបានដឹងច្បាស់ស្ទះមករក ឃើញស្ទួនពន្ទុកជាប្រធាន ស្រីប្អូនប្តាប់ច្បាស់ក៏រះផ្សាន ពារពានពោលពាក្យ

មកទៀតថា ៗ សំដីយើងប្រាប់ស័ព្ទកំបាំង ឲ្យអ្នកឯងតាំងគិតដោះសា បើឃើញចំពោះលើអ្នកណា ទើបយើងត្រូវការយកជាប្ដី ៗ ឥឡូវប្រស្នាគាត់មិនដឹង ទៅពឹងអ្នកទោសគាត់ទេរុំ គិតយ៉ាងនេះក៏គិតអីខ្លួនយើងជាស្រីយកមិនបាន ៗ ព្រោះអ្នកទាំងអស់លង់ទៅណាស់ ម៉ឹងៗប្រឹងសួរមិនប្រមាណ មើលមុខស្រះមេះផេះបង្រៀន បួលវិលទៅស្ថានខ្លួនវិញបុះ ៗ

បុរសប្អូនគាត់ស្ដាប់ដាក់ហើយ ថាឱយើងអើយកើតជាប្រុស ធ្លាយគិតដូចគេវាយផ្លែខុស ឲ្យស្រីសំណេះបញ្ឆោតបាន ៗ ប្រឹងស្កាត់ខ្វាត់រកជ្រកសព្វប្រក ទៅជាអ្នកឈឺស្កកស្គមប្រាណ ស្មានជាចំណេញវិញមិនខាន ប្រមាណខូចសោះខុសទទេ ៗ ថាហើយនាំគ្នាលីលាចរ មិនហ៊ានមាត់កគិតខ្មាសគេ ដល់ទៅក្នុងផ្ទះខ្ទះទឹកដេរ ខ្ទះកើតទុក្ខៈទ្រួសស្មារតីៗ ឯនាងទាំងប្អូនដូនចាប់ចិត្ត អាណិតដល់ទៅអ្នកត្រូវក្ដី ដែលគេធ្វើទោសគ្មានប្រណី នៅផ្ទះសេដ្ឋីឯនាយណា ៗ នឹកឃើញតម្រិះដែលបេះស្រាយអស់អាចិន្តាយឥតកង្វា អ្នកនេះហៅពេញអានប្រាជ្ញា គ្នាយើងក៏ជាប្រការអ្វី ៗ គួររំរកប្រាក់តាមស័ក្តគ្រស្មោះ ទៅសូកសូមដោះអ្នកត្រូវក្ដី ថាហើយបបួលគ្នាឃ្មាតខ្មី បងការបុលខ្ចីប្រាក់គេបាន ៗ ចំនួនមួយពាន់រៀលរួចរេច ចុះទៅតេចពីទីស្ថាន ដល់ផ្ទះសេដ្ឋីស្រីបួនប្រាណ ប្រមាណជូនប្រាក់លោះមាណព ៗ សេដ្ឋីក៏ស្រួលទទួលយក ដោះទៅនោះ

មករួបសព្វគ្រប់ ឯស្រីទាំងប្អូនជួនមិនឈប់ ប្រារព្ធលោ នាំពៅនោះទៅ ៗ មកដល់មណ្ឌលទីគ្រឹហា ចែកមុខងារគ្នាវេនប្រក្រតី ព្យាបាលរក្សាដូចស្វាមី ឥតបីខាតខានមួយវេលា ៗ ស្រីមួយទទួលរៀបចាត់ចែង គាត់តែងឲ្យទឹកតាមមុខងារ ស្រីមួយរំរៀបភោជនា គ្រប់ទំនងរាំអចិន្ត្រៃយ ៗ ស្រីមួយចាត់ចែងខាងស្វាម្ម បៀកម្ហូរដាក់ពានមានសព្វថ្ងៃ មួយរៀបអាសនាទីសុខសេយ្យ ឈើថ្កាត់ជើងដៃគក់ប្របាច់ ៗ ស្រីប្អូនបំរើផ្សេងៗគ្នាតាមដោយមុខងារដាសម្រេច កំពងនទបូរស្តាប់ស័ព្ទសព្វសេព- ក្តីថាឲ្យដាច់ដោយប្រាជ្ញា ៗ ស្រីណានឹងជាប្រពន្ធធំ ប៉ងថាកុំសមកុំប្រស្យា កំពងនបានស្តាប់កុមារ ទើបឆ្លើយតបថាបើតាមច្បាប់ ៗ ត្រូវបាននាងដែលស្ទុងដណ្តាំ ព្រោះគេថែទាំតែងសម្រាប់ ឯនាងទាំងបីជាអណ្តាប់ ខ្ញុំប្រាប់តាមត្រង់គ្មាននិន្ទា ៗ សុវណ្ណកេសរនួនល្អល្អះ បានស្តាប់ស័ព្ទច្បាស់ព្រឹកព្រមា ព្រឺព្រះដួងថៃហឫទ័យា កំពងនមេច្ឆដាថាទៀវខុស ៗ ទើបឆ្លើយថាម្នាលសន្ធិយា ម្តេចឡើយបានជាថាផ្តាសន្មោះ អ្នកចាំស្តាប់យើងថាម្តងទុះ យើងកាត់ឲ្យប្រុសនោះត្រូវចិត្ត ៗ ត្រូវបាននាងដែលរៀបដំណេក ឲ្យដេកជាសុខក្នុងស្ថានស្ថិត បានកាន់ប្រចាំសេចបោះបង់ ផ្តេកផ្តិតជិតភ្លេងនាងទាំងបី ៗ គួរជាប្រពន្ធធំផ្អើស់ ឯទៀតរូបសោះមិនដូចស្តី ឯភ្លេងពិណពាទ្យផ្ទុំរៀងទ្រីព្យុព្រះសាវនីយ៍ដូច្នោះហើយ ៗ ប្រគំដំដេញទាំងវិមាន ស័ព្ទសានទេរបព្យុរន្ទឺរន្ថើយ ជ្រាបដល់ព្រះករុណាត្រត្រាក្នុងហើយ ព្រះអង្គបានស្បើយព្រះ

ទ័យា ។ គេរួមក្សាន្តសោមនស្សអស់ឥន្ទ្រិយ ជានាងនារីត្រូពំផា នឹង
ទៅបត្តបទ្ធិរៀងប្តូភា បានសន្ទនាគ្នាជាប្រាកដ ។ ទើបទៅសត្តសិទ្ធិរទ្ធិ
ក្រៃ ដកយកដួងថៃដែលសន្ទូត ទៅដាក់នៅរូគីលៀងត្រូ ដូចដើមកំ
ណត់ឥតមោះហ្មង ។ គឺលៀងកំបានចឹងស្មារតី នាកាលពត្រីនោះឯង
ហាង ប្រជួនយោមបួនប្ញាយដាម្ពង ចប្រាស់ចប្រងចុះកាន់ទីអាស្រ័យ ។

ឯព្រះបិតុរង្គទ្រង់បេស្គា លង់លុះសុរិយាបច្ចូសសម័យ តើនបាក
បន្ទំបរមសុខសេយ្យ ក្សត្រថ្ងៃចូលស្រង់ធារវារី ។ ជំរះព្រះអង្គទ្រង់
គ្រឿងគ្រប់ ទឹកអប់ត្រឡប់សឹងក្លិនគ្រ ស្រេបហើយគង់លើខែនរូចី ភូមី
ត្រេកទ្រង់សោមនស្ស ។ បន្ទូលនឹងអគ្គអគ្គមហេសី ថាហៃបអូនស្រី
កែវកន្និដ្ឋា កូនយើងម្ដងណោះឃើញអស្ចារ្យ ស្ដីនឹងកុមារបាសុត្រូសិទ្ធិ ។
យល់ជាគូសាងពីបុរេ ផងគេប្រាកដតាមយើងគិត គួរនឹងទៅសាកសួរ
ពាក្យពិត ពិនិត្យចង់ដឹងកលបុត្រី ។ ថាហើយស្ដេចយាងព្រះបាទា
មីម្មាព្រមនឹងអគ្គមហេសី ដល់ប្រាង្គវិសុទ្ធបុត្រភូប្រិយ ទើបវរក្សត្រីជា
មាតា ។ មានព្រះសវនីយ៍ត្រាស់ដណ្ដឹង ថាហៃព្រលឹងបុត្រស្នេហា
ពីដើមពុំដែលព្រួចរបា នឹងប្រុសណា ៗ ដល់ម្ដងសោះ ។ យប់មិញហេតុ
អ្វីកូនស្រីម្ដាយ អតិប្រាយនឹងមនុស្សប្រុសកំឡោះ ពីកាលវេលាយាមមួយ
ស្នោះ ដូច្នោះតើដោយប្រការអ្វី ៗ សុវណ្ណកេសរបវរកែត្រ ស្ដាប់ដាក់ទូល
តបសវនីយ៍ ថាខ្ញុំម្ចាស់ពុំមានស្ដី តាមតែប្រណីប្រោសមេត្តា ។

ទើបព្រះជននីទ្រង់ត្រាស់ទៀត សួរទៀតតាមហេតុដែលគង្វា បើនាងគ្មាន
ស្តីទីឯអ្នកណា ហេតុម្តេចក្នាក់ផ្កាដូរជ្រទ្រី ៗ ប្រគំត្រែសង្ខរគាំងគង
រំពងគងតាំងប្រាសាទស្រី ដ្បិតគេព្ធដាក់ទឹងលាក់ថ្មី ប្រាប់ចុះមិនអើ
មាសម្តាយ ៗ នាងទូលតបតទៅវិញថា នាកាលនាឡិកាយាមមួយប៉ុយ
ខ្ញុំស្តីទីឯព្ទា ព្រោះធ្វល់ឆ្ងាយ ព្ទាបេះអកិប្រាយចម្ងកក្រៃ ៗ ឯព្រះ
ទ័យវរជននីនាថ សង្ខាតសួរទៀតដោយសង្ស័យ ថាកាលតែនោះ
តើប្រើថ្ងៃ ប្រស្រ័យនិយាយនឹងនរណា ៗ សុវណ្ណកេសរតែអ្នធិប្បាយ
ថាខ្ញុំនិយាយនោះដោយសារ ចង្កៀងបេះស្តីខ្ញុំស្តីថា សូមព្រះមាតាជ្រាប
សេចក្តី ៗ កុសុមានាងនាថសួរទៀតថា ចុះកាលនាឡិកាវាយយាមបី
ព្ទស័ព្ទប្រគំដូរជ្រទ្រី នោះតើកូនស្តីនឹងនរណា ៗ ទើបនាងលើកករ
ក្រាបបង្គំ ថាខ្ញុំនិយាយនឹងពានស្លា សម្តេចជននីសួរទៀតថា នាកាល
នាឡិកាយាមបួននោះ ៗ ព្ទស័ព្ទគន្ទ្រីប្រគំសាន នាងបានស្តីដែរឬទេ
សោះ ប្រាប់ម្តាយឲ្យត្រង់ដាក់ចំពោះ តែព្រោះម្តាយធ្វល់អំពល់ចិត្ត ៗ
ទើបវរក្សត្រីស្រីត្រកូល ក្រាបទូលតាមដោយពាក្យសុចរិត ថាខ្ញុំម្ចាស់
ត្រង់ពុំនិត ទូលពិតពុំលាក់កុហកមុសា ៗ ខ្ញុំស្តីតែនឹងកំនិនទទេ ព្រះមេសូម
ទ្រង់ព្រះករុណា អត់ទោសម្តងចុះខ្ញុំសម្តងម្តា មេត្តាសន្តោសប្រោស
ប្រណី ៗ

កាលនោះកុសុមាកដជននី ទៅនាងទឹកធ្វល់សេចក្តី ទើបតបថា

ហៃកូនពិសី ម្ដេចស្ដីថ្កែកថ្កើកអស្ចារ្យ ៗ របស់អស់នេះគ្មានវិញ្ញាណ មិនដែលណាមានបេះបោរ ម្ដាយទើបនឹងស្ដាប់កូនប្រាប់ថា ផ្ការនឹងផ្កាលាពានព្រះស្រី ៗ កំណើនដែលបាំងកល់វេលា ត្រឡប់ប្រែជាបេះស្រដី យ៉ាងនេះចម្លែកក្នុងលោកិយ មិនមែនទេវឫកមាសម្ដាយ ៗ ប្រសិនបេះស្ដីប្រាកដស្ដែង កូនឯងសួរទៀតមើលកូនអាយ ឲ្យឮបានម្ដងនៅមុខម្ដាយ នឹងស្ដាប់លេបខាយសោះសង្ស័យៗ សុវណ្ណកេសរទោមសោកី ស្ដាប់ព្រះជននីហើយភ័យក្រៃ ទឹងស្ញៀមយល់ទាស់អធ្យាស្រ័យក្រែងមាតាថ្លៃថាមុសា ៗ ហើយនាងពុំជ្រាបះហេតុកេទពិត ជាទៅសព្វសិទ្ធកុមារ ដកយកដួងចៃដែលសញ្ញា ដំតាពុំទាន់ដឹងដើមក្ដីៗទើបនាងនិយាយទឹងសន្ធិយា នូវផ្ការផ្កាលាពានព្រះស្រី ច្រើនផងច្រើនសាពុំពួស្ដី ក្សត្រីទាល់សោះអស់ប្រាជ្ញា ៗ ឈឺចិត្តរំងឹងរឹតតឹងចង្អៀត ប្រឹងឆ្ងៀតសួរទៀតប្អូនប្រាំសារ ពុំឮឆ្លើយសោះទាល់ប្រាជ្ញា មាតាគង់ផ្ញុញញីមស្ដាប់ ៗ នាងនាថទាល់ចិត្តគិតមិនយល់ អំពល់តឹងទ្រូងស្មើរទឹងស្លាប់ ហាក់ដូចជាខ្ទួនមនុស្សឥតស័ព្ទ ប្រែប្រាប់បង្ខំងក្លែងមុសា ៗ សម្ដេចបិតុរេតកេតមាតុវង្គយល់នាងទោមយំគ្រៀមក្រ្ដា ជ្រាបហេតុថាបុត្រផុតប្រាជ្ញា អៀនខ្មាសទឹងថាត្រង់ពុំបាន ៗ ស្ដេចយល់អធ្យាស្រ័យដូច្នោះ វិលចុះទៅកាន់ប្រាសាទឋាន ឡើងគង់បល្ល័ង្ករត្នសុប្បកាន្ត ក្សត្រក្សាន្តត្រាស់ហៅពជកញ្ញា ៗ មកដល់ទើបមានឱង្ការប្រាប់ កូនអើយចូរស្ដាប់ពាក្យបិតា ដ្បិតទៅ

សព្វសិទ្ធិទ្វីក្លា គេមានប្រាជ្ញាក្លាហៅហាន ៗ ទាំងរូបកំណើតស្មើតសមទ្រង់
ទាំងពន្សក្រឹត្យពុំថោកសន្តាន សណ្តាប់ស្មើព្រមល្មមផ្ញើប្រាណ បិតាប្រមាណ
ឃើញពេញចិត្ត ៗ គួររៀបអភិសេកទឹងកូនរត្ន ជាគូប្រតិព័ទ្ធរួមផ្គុំផ្គិត
ព្រះនាងបានឮព្រឹសិរសិត គោមស្និទ្ធធ្មើមុខហាក់រាហ៊ី ៗ សម្តេច
បិតុរង្គទ្រង់បេស្តា មានព្រះឱង្ការឡើមន្ត្រី ទៅនាំសព្វសិទ្ធិមានបារមី
មកគាល់បក្រីជាឆាប់ ៗ ៗ អាមាត្យទទួលព្រះតម្រាស់ ចុះទៅហែស
ទើបផ្ដល់ប្រាប់ ឯចៅសព្វសិទ្ធិក៏បានស្ដាប់ ប្រញាប់ឡើងមកក្រាប
វន្ទា ៗ ទៀបរត្នបល្ល័ង្កទាំងពារប្រាណ ទើបបានក្រលេកទៅយល់គ្នា
ស្រីប្រវឹបប្រឹបសព្វពេមា ចាប់ព្រះទ័យាដោយសព្វខ្លួន ៗ ព្រះបាទ
ព្រហ្មទត្តត្រៀវត្រធិបតី បក្រីមានព្រះតម្រាស់ជួន ហៃបាសព្វសិទ្ធិ
បុត្រខ្មឺមខ្លួន យើងជួនជួបចៅហៅត្រូវចិត្ត ៗ ព្រោះបានបារទៅថ្លែង
អភិព្រាយ ឱងចាំងនោះឆាយនៅបាងបិត នាងគង់ទតបកាសិត
ឃើញមកសាណិតគិតមេត្តា ៗ ឱងរៀបអភិសេកបង្វឹងកាប ជាមហា
ឧបរាជត្រូវរំផ្ដា ត្បូងពុទ្ធត្រើស្រីកល្យាណ៍ ឲ្យជួបប្រាជ្ញាគ្រានេះហែង ៗ
ឯចៅសព្វសិទ្ធិក្រាបប្រណាម្យ បង្គំទទួលតម្រាស់ហ៊ៃ ស្រេចទើប
សម្តេចព្រះតៀលព្ល័យ ទ្រង់ញៀយផ្ដោយញាណមានឱង្ការ ៗ
ហៃអស់យោធាក្នាក់អារក្រម ចូររៀបចំបទ្ធបាយា ចុកចាំងជំរះឲ្យយាត្រា
ជួសជុលសាលាពន្លាហ៊ាន ៗ ចាត់ចែងតែងតាមចំឡៀមបញ្ហប់ ធ្វើ

ការមហោស្រពបុណ្យសួស្តីកាន្ត  ដ្បិតអញអភិសេកបុត្រពីព្រោណ

ចូររៀបឲ្យបានទាន់ការឆាប់ ៗ  គ្រានោះបានហ្វូងពលស្តី ស្តាប់

ឱង្ការខ្ទរចេញប្រញាប់  ចែកហ្វូងប្រកាសដីកាប្រាប់  មេការគន់គាប់

គ្រប់ដំណាន ៗ  ឲ្យជួសជុលឋានយានប្រទីប  សង់រោងសាមសិប

ប្រាំមួយល្វែង  ពាសសំពត់ពេសចិត្រវែង  ជាន់ក្រៀកកំពែង

តែងតាំងតុ ៗ  មានទាំងឆត្រត្រួតរៀបតាមជាន់  ត្រៀវទាំងកំពាន់ទៅ

ហ្វាយស្រុក  ឯរាំងក្នុងបុស្បុក  មិនឲ្យមានភក់ជង់ធូលី ៗ  បើង

ជាប្រាំផ្ទុំតាមថៃ  ដាំសីងគោមតែត្រានត្រប់ទី  គុះមន្ទីរក្នុងតាមវេណី

បន្ទាររបោះភ្ជុំភ្ជុងរន្ទា ៗ  ខាងក្នុងបង្អួចនោះមានគ្រប់  រោងណាងលេង

យប់សព្វវេលា  រោងហ៊ីហាត់បោយក្រោយមាត់  យោលរោងគាល់

ត្នារស្មព្រត ៗ  មានរោងល្ខោនខោលលេងតាមខណ្ឌ  ដោយគង

កំណាន់មន្ទីរគ្គ  ជុំវិញរាជវាំងតាំងរាជវ័ត  ធ្វើពាក់គ្រប់ពួកមុខការផង ៗ

ខាងក្នុងចុងរោងរៀបផើងផ្កា  ដាក់ជាជួរបារាណ្ឌគន្ធ  ផ្ទៃរោងក្រាលព្រំ

សមឥតហ្មង  ខាងលើសំងចងគោមរយ៉ា ៗ  គ្រប់ល្វែងបន្ទោះដាក់ទីតាំង

បិទបាំងឡប់ឡៃក្បែរពនម៉ា  មានផាកបន្ទប់ទីអាសនា  ត្រៀវការខាង-

ឯល្ខោនស្រីៗ ៗ  សង់សមជុំវិញពេញតាន់តាប់  សំរាប់ឲ្យអ្នកប្រទេស

ថ្មី  ឯព្រះពន្លាមានថ្នាក់បី  ទីទៃនរង្សីសុវណ្ណា ៗ  សំរាប់ស្តេចចេញ

ទតរបាំ  កើយតែសឹងជាំត្បូងមុក្តា  មានតុះខ្ទង់តាំងរៀបក្រឡា  ទីនាំង

នាយោធន្ទាគន៍ ៗ សន្និយាត្រកំរើនទាំងខ័ណ្ឌ គ្រប់តាមល្បែងចំនួនក្នុង
ពេនទ្រង់ ដាសដាំកញ្ចក់ផ្ទេកក្តិយន៍ មើលទៅរលង់មានរស្មី ៗ លុះ
ជួបកំណត់សត្វទ័ព ភ្នាក់ងាររៀបរៀបស្រេចទាំងទី ឡើងចូលគោមពន្យអគ្គ
ធរបតី ចក្រីទើបត្រាស់ប្រាប់អមច្ចា ៗ ថាចូរទៅទៅហៅគោណ្ឌាញ
សេដ្ឋីនោះមិញឲ្យយាត្រា ចរចូលមកឆាប់ផ្សិតត្រូវការ អភិសេកសុ-
ណាសាសព្វសិទ្ធិ ៗ អាមាត្យបង្គំចាប់ផ្គាប់ ក្រាបលាប្រញាប់ចុះដល់ដី
ត្រះដើរចូលផ្ទះសេដ្ឋី ទើបប្រាប់ទៅទាំងតាមបញ្ញា ៗ ថាផ្សិតសម្តេចព្រះ
មហាក្សត្រ ឲ្យលោករៀបចាត់គេកសូភារ ចូលទៅគង់ក្រុងកុំរញ្ញោ
ឲ្យទាន់វេលាស្អែកនេះឯង ៗ ព្រោះផ្សិតសព្វសិទ្ធិកុមារ ចូលទៅចរចា
ពាក្យថ្លាថ្លែង ទឹកពជពុត្រីគប្បីស្នេហ៍ នាងនាថស្តីស្តែងស្រេចបានស្តាប់ ៗ
ឥឡូវទ្រង់ធឹងរៀបអភិសេក ផ្សំគ្នាជាឯកភាមដោយច្បាប់ អាមាត្យថ្លែង
ស្រេចវិលត្រឡប់ សេដ្ឋីប្រញាប់ឆាប់ម៉្នាៗ បបួលបាវព្រាវមកព្រមព្រៀង
ក្តួយដង់ពង់ស្មៀងពាអ្នកងារ ហើយរៀបទ្រព្យក្នុងគ្រឹហា គោក
ពាខម៉ែនថាមានតំឡៃ ៗ សំពត់ហូលព្រែទូវបៀមត្រំ ផាហ៊ុំម្នកគាតសា.
ក្លាតស្បែ ចិញ្ចៀនត្បូងពេញរលេចថ្ងៃ ច្រើនពណ៌ពេកក្រៃគ្រឿងគ្រប់
គ្រាន់ ៗ មានទាំងគុះទៀបរៀបការការ ឋប្វៃចង្កាជ្រុកតាមាន់ រៀបរួប
ប្រញាប់ឆាប់ស្រេច ឲ្យទៅឲ្យទាន់ពេលវេលា ៗ ស្រេចហើយសេដ្ឋីប្តី
ប្រពន្ធ ដឹកនាំទ្រព្យធនចេញម៉្នាៗ ឲ្យលើកដាក់លើខ្នងគជា ចេញបាក

គ្រហឹមកងខាងក្រៅ ៗ ព្រៀងលាន់ចាស់ទុំទ្រុំឮលង់ ប្រចាំត្រៀមទ្រង់
មីរខ្លទៅ សេដ្ឋីតាំងសងសឹងផតសៅ ជះបរសំផៅទៅក្រុងត្រៃ ៗ
មានមនុស្សជិះសេះទេះអម ច្រើនស្ពាំហែហមពេញព្រៃផ្សៃ លុះបរទៅ
ដល់ពាដពាំងថ្ងៃ សេដ្ឋីចុះឮពីគជសារ ៗ ឲ្យឈប់រទេះទ្រព្យសព្វគ្រប់គ្រាន់
មនុស្សម្នាប្រព័ន្ធពេញត្រៀបត្រា សំងំសេងជញ្ជូនបណ្ណាការ ដាក់ក្នុង
សាលាតម្រៀបខ្ទី ៗ ស្រេចទើបកោណ្ឌញ្ញចេញដើរទៅ ចូលគាល់
ទោមចៅព្រះចក្រី ឯក្នុងបុរពេជពាំងជ័យស្រី ក្រួញក្រាបសំសេរីវន្ទា ៗ
ព្រះបាទព្រហ្មទត្តខត្តិយវង្ស ស្តេចទ្រង់ទៀងទតយល់ម្នា ទើបមាន
មច្ឆរសពោះទៅថា ហៃមហាសេដ្ឋីប្រពៃពិត ៗ ដ្បិតព្រះពុទ្ធដីការឿង
ជាបុត្រយើងរឿងរំពឹត ស្តីនឹងបុត្រាបាសព្វសិទ្ធ យើងគិតយល់គួរ
អស្ចារ្យក្រៃ ៗ នេះសមគេស្តួមសាងផងគ្នា ពីមុនបានជាមាននិស្ស័យ
កាលដើមជ្រើសរើសបុត្រក្សត្រថ្លៃ ឲ្យមកប្រស្រ័យពុំស្តីថា ៗ ក្រោយ
ទៀតរើសសព្វកូនសេនីយ សេដ្ឋីកុដុម្ពីមន្ត្រីត្រៀបត្រា លួងលោមអស
ចិត្តផុតប្រាជ្ញា នាងស្បថចរចាថាអ្វីសោះ ៗ តែពុំយល់មិញពេញថ្លៃកពិត
សព្វសិទ្ធបានស្ងួរវ៉ា ថ្មីយដោះ ហេតុនេះយើងគិតគណិតស្មោះ ឪង
រិះរៀបអស់បណ្ណាការ ៗ អតិសេកផ្សំគ្នាជាគូគាប់ តែងតាមទម្លាប់បុរាណា
ប្ញអ្នកចេញទៅស្ពានបុត្រា តាមយសសក្តានាំមកនាប់ ៗ កោណ្ឌញ្ញ
ទទួលព្រះតម្រាស់ បង្គំហ័សចេញប្រញាប់ ដល់ពេជពិធីទីប្រថាប់

ទើបប្រែប្រាយប្រាប់នាងខេមា ៗ ឲ្យរៀបតែងត្បូងពោធិសត្វ ស្រេចនាង
ថែងបាត់គ្រឿងពស្ត្រា ស្រប់ស្រង់ជំរះព្រះកាយា បំពាក់សង្វារវៀនវង្វៀ
បំពេញទ្បែនត្បូងរត្នទាំងប្រាំពីរ ព្រោងប្រុះធ្លុះរលរង់រស្មី ពាក់ម្រាមព្រះ
ហស្ដទាំងប្រាំបី មើលមានសួស្ដីសរវ័ឍ ៗ ទ្រង់ព្រះភូសាសែសសយមាស
ឆុកាសក្ខីផ្ទូកប្លែកល្អក្លាត់ ថាប់ស្លឹកឆ្ងើងគ្រឿងកងហត្ថ ព្រះពស្ត្របាក់
ពទ្ធក្បិសុវណ្ណ ៗ ពាក់មកុដដាំពេជ្ររលេចពណ៌ ល្អះល្អរៀងរឿង៎ផាយ
គ្រឿងទំណួ លាយលាបក្រពេះទ្បូឹងបន ពពាក់ពពន្ធសុវណ្ណ ៗ
រៀបអង្គទ្រង់គ្រឿងអលង្កត វិសុទ្ធិវិសេសឧរេសក្រ ធរាលរង់អង្គកុមារ
បារក់ព្រះសុរិយាហោះទក ៗ ព្រះអាទព្រហ្មទត្តខត្តិយា នូវនាងកុសុ-
មាពជទេវី ទ្រង់ស្អាងព្រះនាងទាថនារី កងទីព្រះថៃទថែនសុវណ្ណ ៗ
បំពាក់ព្រះមកុដវិសុទ្ធសក្ដិ ពាហុទាក់ថាប់ត្បូងបុប្ផា សង្វារស្រោប
អង្គទ្រង់កងទន ប្រកាទប្រគបក្រប់ប្រដាប់ ៗ ទ្រង់ព្រះពស្ត្រ
ផាក់បាក់ខ្សែមាស ជាក្បិលាសល្អចំណាប់ កុសុទ្ធវិចិត្រវិជរបោប៉ រស្មី
ស្រស់ស្រោបផ្ទូកក្ទុយង ៗ ពានោស្បែស្ដេងរៀងពិចិត្រ ប្រសិទ្ធប្រសើរ
ដំណាំទ្រង់ ដូចស្រីសុជាតាវិភាងៀ ចំណើត្បូងរត្នមកុដថៃ ៗ ពិទូរ្យ
ពិទាយលាយទឹកវិល ពេជ្រទិលវទឹមមានតម្លៃ ពាក់ម្រាមព្រះហស្ដ
ល្អះល្អក្រៃ ព្រះកក្ដ្រប៉ប្រែប៉ប្រិមថ្វា ៗ រៀបរួចស្រាប់ស្រេចស្ដេចមាន
បុណ្យ ឲ្យកេរទិមន្ដព្រះសង្ឃគណា ជាទ្រទូងរត្នសត្តកាយា ជុំកុង

ក្រឡាពន្លាគង់ ៗ លុះដល់ព្រលប់យប់បន្ទាប់ នោះម៉ាងពីព្រះចមពង្ស ឲ្យអស់ទាសទុំផ្ទុំពុំលង់ ត្រៀមទ្រង់ហែហាមរាជបុត្រី ៗ ពួកស្នំក្រមការ ស្រីផ្ការផង មូលមីរគើនកងពេញប្រាង្គស្រី ល្មមពេលហែហាមអមចេញខ្មី ចាកទីវង្សមគរពងរម្យ ៗ ដល់ហើយក្រាបចុះលើកម្រាល សិនក្រាល ពូកព្រែទូវបៀមព្រំ មាតាគង់ផ្ចាប់ក្រាបបង្គំ សុខ្ចសិនឱយមះរោមខស្វាៗ គ្រានោះកោណ្ឌញ្ញមហាសេដ្ឋី ឃាតទ្វីព្រមទំង៍នានខេមា ទូវខ្ញុំកំដរយ៉ាបរ-ជារ ហែអង្គព្រះមហាបុរសរ័ត្ន ៗ ឡើងលើពន្លាជាប្រញាប់ មនុស្សផង គាន់គាប់ប្រពួនព័ន្ធ ទើបអង្គសម្តេចព្រះព្រហ្មទត្ត មហាក្សត្របែរព្រះភក្ត្រា វៃ ៗ ឲ្យអាពំធនាព្រះសង្ឃសូត្រ ស្វាធ្យាយចំហុតគ្រានោះនៃ រម្ងាប់សូត្រ មន្តព្រះមហាជ័យ ឬាបសាចមាលៃជាមង្គល ៗ រួចស្រេចស្តេចឲ្យហែ បុត្រី ចូលកាន់ប្រាង្គស្រីទៃនមណ្ឌល ទាំងចៅសព្វសិទ្ធបុត្រនិមិល សិងហែទៅដល់ទីប្រថាប់ ៗ ព្រះសង្ឃក៏វិលទៅកាន់វត្ត ព្រះបាទព្រហ្ម-ទត្តប្រកាសប្រាប់ ឲ្យពួកមហោរីរៀបប្រដាប់ រប៉ាំចេញឆាប់កុំយូរលង់ ស្តេចក៏ទ្រង់ទតក្រសាលលេង ដោយល្បែងមហោស្រពប្រថាប់គង់ លើ ព្រះពន្លាទីពេនទ្រង់ ចក្រពង្សទ្រង់ទតបាប់ព្រះទ័យ ៗ អស់ពពួកល្ខោន សិងតែងគ្រឿង រុងរឿងពេំលូទ់ល្អាស់ល្អៃ ប្រគំភ្លេងខ្លុំពិណរាំងជ័យ ទតរ៉ាស្តេចចូលទៃនបន្ទំ ៗ យប់នោះមានល្បែងលេងដោយឡែក ណាំងស្បែកណាំងតាលុងដោយជ្រុងជ្រុំ ខោលងិវហាត់បោយភ្លេងប្រគំ

លាន់ឮផ្គរផ្ទុំពន្លាំង ៗ មនុស្សភ្ញាប្រព័ទ្ធពួនពេញពាស ក្រស្ពាសឈរ
មើលភ្លឹកភ្លុបភ្លាំង មានពេលប្រកិតផិតផ្ញាំង លក់ម៉ែកទ្រាំងតាំងតុយ
តាវ ៗ លក់ប៉ាយបបរស្ករស ចាប់ឆាយឆ្អកទឹកពិសង៉ាវ ត្រីឆ្អើរសាច់
ឆ្អើរពោះវៀនរាវ គុជភ្លើងគោគាវទាំងគ្រៅក្នុង ៗ មានពេលបៀរប៉ោវយុ
តី_ មនុស្សម្នាលេងម៉ាពេញសាឡុង ឈ្នះចាញ់ខ្លះៗមេហូតតុង ខ្លះប្រុង
ស៊ីជំនីពីអ្នកចាក់ ៗ ខ្លះផឹកខ្លះស៊ីខ្លះសើចសាហាន ខ្លះមានសោហ៊ុយលុយ
កាក់ប្រាក់ ទិញលេងស៊ីលេងមិនស្តាយកាក់ ខ្លះស្ពាក់បង់ស្រី
ស្រូតដើរស្រែ ៗ ឯពួកកំលោះកំឡុងបុណ្យ យ៉ាកពុំខម្តេចម្តាប្រឹងត្រដរ
ដូរទិញសំពត់អុតអាវស សាម៉ីសក្លុកលិអគ្គ ៗ តែងខ្លួន
កុំជាខ្មានស្តាយទ្រព្យ ក្រែងស្រីមិនពប់ចាប់ចិត្តបង ម្លួកឆត្ររំពាត់
ដើរហាន់ ត្រាច់ត្រង់រ៉ាសស្ទុះទៅមក ៗ ឯអស់អ្នកលេង
តែងស្លៀកពាក់ ខ្លះលួចលបធាក់បង្គ្នារ ខ្លះលាត់តួចឡុកក្អកបន្ទរ ខ្លះ
លលួកពាវប៉ាវអស់អ្នក ៗ ខ្លះចង់បានគ្នាជាសហាយ ចាប់ដៃប្រញាយ
ខ្លះលបធាក់ កើតជាជម្លោះឈ្លោះតូចតាក់ ផ្អើលភ្ញាក់ៗសុះរត់លោតគ្រ
លុក ៗ ប្រកួតព្រួតគ្នាកោលាហល ប៉ូលីសមកដល់ចាប់ចូលគុក
ខ្លះរើសឫគាលគោលចំមុខ បេញឈាមគគុកគ្រួអឺតិច ៗ ឯពួកថៅថុន
ប្រុងដើរព្រាត យូរយាត្រក្បែរតុមុខសាលា ខ្លះចូលបន្ទំដើរទំមស្នា
ប្រាថ្នាឲ្យគេហៅថាថៅ ៗ មនុស្សម្នាលីណាយាត្រាត្រាច់ ហូរហែគ្នាដាច់

ទាំងប្រុសស្រី ខ្លះបីខ្លះទ្រពកូនខ្ចី ខ្លះលក់ផ្កាក្បែរផ្កាក ៗ សព្ទលេងភ្លេងឃ្លុំដោយភ្លេង មានលោកអ្នកយើងលបមើលឡាំ អ្នកលេងស្គូត្រមហោរីឡេសស្រាំ ផៃយ៉ុំយ៉ាគ្រឿងអាប៉េឡេក ៗ ខ្លះលបលួចលុយពីហោបៅ ខ្លះតាន់ស្រែកឡោកក្រញោត្បេក ខ្លះលើកដុំផ្ទមិតបោលម៉ក ខ្លះជ្រៀតកេប្រកជ្រកកេតួន ៗ ឯស្រីក្រមុំព្រហ្មចារី ស្លៀកពាក់យ៉ាងថ្មីមាសពេញខ្លួន កម្មោះខ្លះក្អាកុំគុំគួន ខ្លះជូនចូលចិត្តឥតខ្លាចគ្នា ៗ ប្រទះព្រាតព្រោងដូចកែវប្រក់ ស្រីណាអាក្រក់ត្រឡប់ជា ល្អព្រោះគ្រឿងក្ងី កង្វេលា សន្ធ្យាពន្លឺឥតបំអន់ ៗ ខ្លះឃើញគេល្អឈរសម្លឹង ទ្រូងតឹងដាចទុកចុកកុកកួន ក្ដៅក្ដាត់ប្រមាត់ស្ងួតណែនណាន់ ស្ងួតស្ងន់កង់ចិត្តត្បិតស្នេហា ៗ លុះដល់អធ្រាត្រយប់ស្ងាត់ស្ងប់ យ៉ាងពីរដណ្ដប់ល្មោទកំ អ្នកមើលនាំគ្នាចរយាត្រា កាន់ហាំងអាត្មាជាសុខសាន្ត ៗ ជូនព្រះទិនករក្សីឡើងច្បាស់ ទៀបអរុណរះព្រះសុរិយោទ បុរោហិតហោរាដែលដឹងជាទ ប្រមាណយល់ពេលសំពុងអក្សរ ៗ ឲ្យតាំងប្រគំដូរៀងទ្រី គោណ្ឌពាសេដ្ឋីចេញចរ ហែព្រះកុមារថ្ងៃចរ អមអស្រ្សស្រុះលុះដល់ទី ៗកណ្ដាលផ្ទៃព្រះរាជរោងរមៀ ក្រាបចុះបង្គំគួញគាល់ម៉ែ ឯនាងកុសុមារាជទេវី ហែនាងនារីពីប្រាង្គស្រី ៗ បណ្ដាស្រីស្នំបរិវារស្នំ ប្រឡូកប្រឡំជុំឃ្លាតខ្ញី សឹងតាមហែហមអមក្សត្រី ឥតបីគណនាគ្រាប់ថ្លានី ៗ មកដល់មណ្ឌលទីរោងទ្រង់ ឲ្យនាងតោមយង់គង់ប្រញាប់ព្រះណា ស្រីស្នំក្រម

ការអម្ពូលមាន គង់គាល់ពេញបាទមករគ្រៀបត្រា ។ ព្រះបាទព្រហ្ម-
ទត្តខត្តិយារង្ស ស្តេចស្រង់ហើយទ្រង់គ្រឿងក្ងូសា សីហាទាទយានយាត្រ
ចាកអាសនា កាន់ព្រះក្រឡាពជពេជរម្យ ។ ទាំងពីរពជបុត្រវិសុទ្ធសាធ
អាទុនអភិវាទបាទបង្គំ សម្តេចបិតុរង្គទ្រង់និយម ឲ្យតាំងប្រគំដូរ្យដន្ត្រី ។
បង្គាប់ព្រះនាងនាថកុសុមា នាំពជកុមារកុមារី ឡើងគង់លើផ្ទករត្នរង្សី
ទាំងពីរគង្គីទទ្ទីមគ្នា ។ ទ្រង់យកទឹកសង្ខតាំងទឹកក្ងូស ស្រោចស្រប់
អប់អស់ព្រះអង្គ ឯនាងកុសុមាពជជាយា លីលាចូលចងព្រះហស្តរៗ
ពួកព្រាហ្មណ៍ផ្លុំសង្ខសូត្រស្មូត មន្ត្រីតាំងហៅយកសួស្តីជ័យ គំរប់បី
ដងស្រេចហើយនៃ និរភ័យសោមនស្សស្រស់ប្រីតា ។ ប្រជុំព្រះវង្ស-
នុវង្ស គាល់គង់ជុំវិញពេញគ្រៀបត្រា បង្វិលពពិលជាទក្ខិណា
ជាប្រាំបួនសាតាមគេទសៃយ ។ រួចលត់ផាត់ផ្សែងចំភគ្រា ពីរពង្ស
កុមារបុត្រថ្វាថ្ងៃ ស្រេចហើយថ្វាយពរទ្វៃក្រៃ ជាទវៃហលានត្រៃទ្វិទាំង ។
សូមឲ្យចំរើនស្រីសួស្តិ ពិភ័ទ្ធមង្គលឧត្តម ប្រកបក្សេមសុខនិរទុក្ខ បិទ
ប៉ាំងអាពាធព្យាធិយាយ ។ ឲ្យម្ចាស់ពីរប្រាណមានព្រះជន្ម យឺនលន់
កំណត់មួយម៉ឺនឆ្នាំ បាន គ្រងពិភពបបជានទ ជាទពនាកប្រជាជន ។
ទោះភ័ងអរិទូបរប័ក្ស ឲ្យមកពឹងពាក់ព្រះគុណជូន បាក់បបខ្ទប់ខ្ទាប
អំណាចលន់ ចងពន្ធចំណុះចុះវន្ទា ។ សម្បត្តិមហាចក្រទាំងប្រាំពីរ
ឲ្យនាំណ្តតរិលេចូលមកជា សម្រាប់ព្រះពោធិសម្ភារ កុំឲ្យឃ្លាតឃ្លា-

សោះជាមួន ៗ បណ្តាប្រជាជនប្រុសស្រី ទាំងផែនបូរីថ្វាយពរផង បាចសាចលាជផ្កាមាលាក្រូន សន្ធឹកគឹកកងរោះការណ ៗ ស្រែកការ វិវាហមង្គល ខេមពលព្រហ្មទត្តខត្តិយា ប្រមាទត្រៀងយសព្រះ សុវណ្ណសាម ជាមហាឧបកជាកដើតជាន ៗ ទ្រង់ឱ្យដង្ហែព្រះធីតា គាន់ ប្រាង្គសុវណ្ណមន្ទីរស្ថាន នៃព្រះជននីតែម្នងប្រាណ ពុំទាន់ឡើងបាន នៅឡើមគ្នា ៗ ឯព្រះសុវណ្ណសាមមហាសត្វពិទូ នោះព្រះបពិត្រឱ្យបរិពារ ហែចូលប្រាសាទប្រសើរជា ដែលព្រះបុត្រភ្នាទាន់ធ្លាប់គង់ ៗ លុះ ដល់សន្ធ្យាវេលាយប់ ក្រុមព្រឹទ្ធាចារ្យប្រារព្ធទ្រង់ ឱ្យនាងកុសុមាវតី នាំបុត្រនោមយកទ្រង់ចន្ទ ៗ ព្រះជននីបង្គាប់គាន់បុត្រី ថាហៃកូនស្រីថ្លៃ តិតម្យ ពេលនេះម្ដាយរៀបរៀបចំ តិតនាំអាបម៉ូងឡើងសយ្យា ៗ ឯឯព្រះ ស្វាមីនៃវរមិត្រ ចូរកូនកុំគិតភិតភ័យថា កុំខ្មាសកុំអៀនណា កូនណា កុំឱ្យភ្ញាក់អន់ចិត្ត ៗ ព្រះនាងបានស្ដាប់សព្វមាតា ត្រឹមព្រះកាយា ញាប់ញ័រ នឹកអរហើយអៀនខ្មាសស្ងួន យកស្បៃបាំងបិទព្រះភក្ត្រា ៗ ហើយលើកព្រះករឡើងប្រណម្យ បង្គំទូលតបជននីថា បពិត្រព្រះវរ រាជមាតា សូមទ្រង់មេត្តាប្រោសប្រណី ៗ ព្រោះខ្លួនខ្ញុំនេះដូចអ្នកព្រៃ រៀនរៀបតាំងពីកើតមកខ្ញុំ ពេញប្រុសពុំធ្លាប់ស្ដាប់ពាក្យស្ដី ពុំមាន មេត្រីចាប់ចិត្តបង ៗ ឥឡូវឱ្យទៅនៅនឹងប្រុស ម្ដាយអើយម្ដេចបោះ គ្រានេះម្ដង សូមទ្រង់អាណិតគិតកូនផង កូនអៀនក្រងឥតឧបាយមេយ្យ ៗ

ថាហើយក្សត្រីស្រីទ្រង់ល័ក្ខណ៍ ទុនក៏ក្រដាក់ចុះឆ្ពោះទៀបៗ ព្រះបាទ
មាតាវង់សង្វៀយ សោកសោះអាល័យក្តីសង្សារ ៗ ព្រោះមានវេរ
ពៀរព្យាបាទ កាលនាង់ចាប់ជាតិជាសកុណា បានតាំងវិរតិសត្យសច្ចា
បេដ្ឋាឲ្យកើតចូលចិត្តគិត ៗ តែចាប់ឈ្មោលនោះក៏បានតាំង សច្ចំសច្ចា
ឲ្យជួបជិត កម្មនោះឲ្យផលទិមិលមិត្រ ទៅជាប្រែចិត្តគិតមេត្រី ៗ
នាង់ខំអំណត់សង្កត់ចិត្ត ធ្វើហាក់មិនស្បែតឥតរវើ ការក្រង់គេជាខ្ទាស្តី
គេត្រូវកើតជាស្រីជាតិស្រើបប្រហល ៗ ទំប្រឹង់ទូលតបទៅទៀតថា សូម
ទ្រង់មេត្តាប្រោសកុំភាល កុំឲ្យកូនះទៅពុំត្រូវកាល សូមនៅព្យាបាល
ព្រះមាតា ៗ ជននីនាង់ចុមលោមយកចិត្ត មាសស្និទ្ធគិតបោះខុសមាត្រា
ទំលាប់ប្រវេណីបុរាណ ពុំដែលនរណាទីង់ចៀសបាន ៗ កុំថា
តែមនុស្សទោះទេវតា នៅនកាមាសួគ៌ាស្ថាន គង់រកគូគាប់ប្រុសត្រូវប្រាណ
មិនះឃើញឲ្យមានមានជួបគ្នា ៗ ដែលកូនដោះស្រាយម្តាយគិតគ្នេរ ពាក្យ
នោះខុសទេណាកូនណា ត្រាស់ស្រេចស្រូតនាំនាង់លីលា ទាំង់ពីរអង្គ
កាន់ប្រាង្គស្រី ៗ ពោធិមិលយល់មាភា ទើបក្រាបទមស្សការទុន
សិរសី ជនទីនាង់មានសវនីយ៍ ហៃបុត្រពិសីថ្ងៃថ្មីម្តាយ ៗ ត្បិតពជ
ក្សត្រីថ្ងៃប្រសើរ ម្តាយយកមកធ្វើណាកូនអាយ ប្តូរកូនទទួលស្រស់ស្រួល
ស្រាយ តាំងចិត្តខ្វល់ខ្វាយរកគ្នា ៗ ឲ្យមានអំណរទីង់អំណាត ទុនអត់
អបអរចិត្តធ្វើជា កុំយកពិពេចក្រៅក្រោធា កាគេត្រូវនិន្ទាទោសលោកយ ៗ

សុវណ្ណកេសរបវរ័ត្ន ចូរនាងធ្វើវត្តប្រណិប័តន៍ប្តី ពេលផ្ទំពេលសោយ
សព្វចំណី ពេលស្រង់គប្បីមើលថែថ្នម ៗ ទំនិតការអ្វីឲ្យប្តីដឹង
កុំប្រឹងចចេសចចេះនឹងខ្ញុំ ឲ្យខ្មាសឲ្យណាស់ណាមាសស្ងួន ធ្វើបត្រូវ
ទំនងខ្លួនបុកណា ៗ ស្រីគ្គារបំពារវ៉ានៀយហត់ គួរគត់សំគាល់មើលតាម
ការ ល្មមខ្ញុំលឲ្យទូលសុំករុណា ប្រយោជន៍ឲ្យវាលៀនដីរ ៗ ផ្តាំស្រេច
សម្តេចព្រះមាតា យាងចាកសយនាក្រឡាទី គ្រានោះព្រះនាងនាថនារី
ឃើញព្រះជននីនិលីលា ៗ នាងស្ទុះចុះតាមដាប្រញាប់ ព្រះមាតាចាប់
ប្រាខមាត់ទ្វារ ទាញដិតបិទផាប់ឆាប់ម្ហ៊មា សព្វសិទ្ធិទ្វារទ្វារទតយល់ដាក់ ៗ
ស្ទុះតាមមកទាន់ព្រះធីតា ហត្ថាចាប់ទាញព្រះសុគ៌ត ហើយឱបព្រះអង្គ
អាណុនលក្ខណ៍ ព្រះនាងញ័រញ្ញាក់ដាក់កក្រ្តា ៗ យកព្រះភូសិទ្ធ
បិទមុខចុះ អេះអុះអៀនឱនព្រះអង្សា ព្រះករចែមពង្សកុមារា ប្រកៀក
កាយាកុមារី ៗ ត្រកងដាក់លើបន្ទំ ព្រះនាងចុះពីទេនរង្សី ព្រះព
ស្ទួយឱបក្រសោបបី ព្រះអូនឱនខ្ញុំអៀនព្រះអង្គ ៗ ព្រះឱស្ឋត្រាស់ថា
ឱអូនអើយ ម្តេចធ្វើគោះតើយបែរថ្ពាះបង់ ចៅមិនកាណាិតចិត្តដែលបង់
ចូរងើបមុខត្រង់មើលមកបង នឹងរេះគិតគេចរត់ទៅណា នែអូនដ៏វាល្អ
ល្អះល្អង ម្តេចម្តាចរចាបានតែម្តង ប្អូនស្នេហ៍ស្ងួនផងទេ ៗ បំណាច់
សម្តេចព្រះបិតា មាតារៀបការរួចជាគឺ ឲ្យអូនជាគូគេដ៏ព្រេ ម្តេចធ្វើឲ្យឈឺ
ចិត្តម្តងទៀត ៗ (នៅមានត)

# រឿងហង្សយន្ត

លោក អ៊ិម-គន ចម្លងពីសាស្ត្រាស្លឹករឹត

បទភាកគតិ

អហំយើងខ្ញុំ ក្រុញក្រាបប្រណម្យ ព្រះអង្គឥតឆ្គង កាលកប សទ្ធិក ពោធិព្រឹក្សទន្ទង ព្រះអង្គជាប្បង ទូទាំងត្រៃភព ។ ស្ដេចដូច ការកេ-ត្រាត្រាច់ត្រៃដែត ត្រដឹងស្កល់ស្កប់ ផ្ទុកសត្វទិករ អមរសាយសព្វ នានាំគ្រាន់គ្រប់ ដាក់ដល់និព្វាន ។ បង្គំព្រះធម៌ ប្រសើរមានគាថិ ជាសំណាញ់ញាណ សម្ដេចពុទ្ធពង្ស ស្រោចស្រង់សត្វបាន-បរិបូណ៌បិតឋាន សុខស្អុតទៀងទាត់ ។ បង្គំសង្ឃសាង សីលសុទ្ធ លះលាង បាបបោះបង់បាត់ ទុក្ខសោកព្រោយព្រាស លោភលាសខ្វាយ-ខ្វាត់ សេពសោយសម្បត្តិ សួគ៌ស្ងួតសោដ្ឋ ។ អញខ្ញុំត្រែកអរ លុតលើកទសករ ដោយដាក់សំពះ ក្រុញក្រាបវន្ទា ទៅគុណា សោយ សព្វសុះសោ-ឡូសទាំងបត្រព្រល ។ បង្គំមហាក្សត្រ ថ្ងៃមានបុណ្យ កាត់ ឥស្សរត្តបាល គ្រងឥន្ទបត្ត រាស្ត្រជួបរំពារ ក្សេមក្សេមបុណ្យ បារ- មីអម្ចាស់ថ្លៃ ។ ខ្ញុំបង្គំគុណ គ្រូប្រសើរលន់ ប្រសៅខ្ញុំនៃ បានបរិបូណ៌ចប់ រៀនច្បាប់ប្រពៃ ជាពន្លឺក្រៃ បទគុណគ្រូគាប់ ។ គុណព្រះមាតា គុណព្រះបិតា នៃខ្ញុំគោរព ទូលទុកនៅនា សិរសា សោតសព្វ ថ្ងៃនឹងគារព គុណធម្មឹក ។

បទព្រហ្មគីត

ព្រះគុណចាំងប្រាំពីរ ស្មើជីវិតខ្ញុំថ្ងៃថា ឧត្ដិឧត្ដមា ខ្ពស់អនេក
អនន្តត្រៃ ៗ ធ្ងន់លើសផែនប្រថពី បឋវីភាំងផែនដី ជ្រាលជ្រៅ ៗ
ក្រាស់ក្រៃ លែងសាគរគម្ភីរ ៗ គេងខ្ញុំថ្វាត់ថ្វាយ បង្គំកាយវាចា
សូមសិរីព្រា- កដកបកើតស្រីសួស្ដី ៗ ទើបខ្ញុំទីងស្រង់ស្រាល់ ស្រាយ
ភាសាចាប់ប្រែពាក្យពី សៀមបទប្រាកដរ ជាពាក្យខ្មែរវិញហោងណា ៗ
និទានកាលសម្ដេច ព្រះសព្វជ្ញសម្ពុទ្ធ ស្ដេចសាងបារមីតា ពុំទាន់
ត្រាស់ជាពន្ស្រពុទ្ធ ៗ អន្ទោលទៅដោយខ្វាត ព្រះយកជាតិជាក់ប្រាកដ
ជាស្ដេចស្ដែងសមុទ្ទ នាមព្រះសុវណ្ណកុមារ ៗ ព្រះអង្គត្រាច់រង្គាត់
ទៅក្នុងដង្គស្រព ស្ដេចសាងព្រះបម្ភារ ពុំទាន់ទំព្រះបារមី ៗ

បទកាកគតិ

ឯកោពជា មុនមានព្រះមហា ក្សត្រមួយជាតិជា ឥស្សរប្រាសប្បន
គ្រប់គ្រងភាព ក្រុងទេពបុរី ជាចៅនគរ ៗ ព្រះអង្គជាក្សត្រ
ចមចៅចក្រពត្តិ សម្ដេចភូធរ បំរើនសួស្ដី វិឡៃព្រះពរ ទ្រង់ព្រះនាមករ
ភាទិត្យវង្ស ៗ មានអគ្គមហេសី វរវណ្ណក្សត្រី នាមនាងពិម្ពា ទេវ
វរលក្ខណ៍ អគ្គអគ្គជាយា ទ្រង់ឆោមសោភា សោភ័ណស្រស់ស្រី ៗ
នាងនាថឧត្ដម លើសលើព្រះស្នំ ស្រីស្គ័រនារី ចាំងប្រាំមួយពាន់ ណាស់
ណាន់ប្រក្រតី សម្រាប់ភូមិ ចមចៅចក្រពត្តិ ៗ ស្ដេចគង់ប្រាសាទ

ប្រសើរស្អាងស្អាត ទឹមព្រះអូនកេវ ស្រីស្រស់ស្រីង្គារ បរិញ្ញាបរិសុទ្ធ
មន្ត្រីជុំជិត គង់គាល់ពងជា ៗ ស្ដេចមានអំណាច ទាំងឯកសេតពង
បង្គំពងជា គោរពព្រះបារមី រិទ្ធិទេស្ដា ថ្វាយស្ងួយសព្ទត្រា ជាអចិន្ត្រៃយ៍ៗ
ពីរពន្ធរោះចាមក្សត្រ សេពសោយសម្បត្តិ រម្យកដក្សត្រថ្ងៃ គ្រប់គ្រង
ស្រីង្គារ ព្យាបាលសព្វថ្ងៃ ប្រាំមួយពាន់ឆ្នៃ សឹងនិបុត្រា ៗ កាល
នោះអាមាត្យ ក្រាបទូលព្រះបាទ សម្ដេចជេដ្ឋា បពិត្រអម្ចាស ថ្លៃណាស់
ជាតិជា អស់យើងករុណា ជាខ្ញុំអម្ចាស់ ៗ សូមទានអម្ចាស់ មែនមាន
បុណ្យពេកស់ លើសស្ដេចទាំងឡាយ គឺមោះឥតបុត្រ បរិសុទ្ធនោមងាយ
ប្រាណប្រុសពណ្ណកាយ នឹងសោយពង្សសួង ៗ ចំណេរទៅលង់ ឥត
ទីនព្រះអង្គ អម្ចាស់ហើយហោង ឥតអង្គក្សត្រា ឯណាទៅសួង ស្ដេច
សោយពង្សគ្រង គ្រងទេពបុរី ៗ ស្ដេចស្ដាប់អាមាត្យ ក្រាបទូលព្រះបាទ
មែនដោយសេចក្ដី ស្ដេចរីងទៅថ្កាន បិតហាំខនារី ថ្ងៃងប្រាប់អស់ក្ដី
នៃនាងទាំងឡាយ ៗ អស់ស្រីស្រីង្គារ ស្ដាប់ព្រះឧង្ការ បទូលប្រាប់ប្រាយ
ប្រដាប់កាយា បូជាថ្វាត់ថ្វាយ ទេពតាទាំងឡាយ សឹងសូមបុត្រា ៗ
ស្ដេចចូលបន្ទំ សុខសួស្ដិរម្យ នូវនាងពិម្ពា អភិឥគ្គមហេសី ក្សត្រី
កញ្ញា សំណេះបរបា បទូលប្រាយប្រាប់ ៗ ជាពៃអូនស្ងួន ព្រលឹង
ខ្ញុំមខ្លួន សួនមាសនាងស្ដាប់ ពាក្យពីរៀមរក្សា បង្អួកនឹងប្រាប់ ប្រ
អូនប្រដាប់ ដូចពាក្យបងថា ៗ ពីថ្ងៃនេះទៅ ប្រនាងអូនតៅ ប្រដាប់កាយា

សំអាតសំអាង ហើយនាងបូជា អស់តាំងទេវា សព្វទិនរាត្រី ៗ ហើយ
ចាំសីលា សាងសូមបុត្រា ប្រាណប្រុសពិសី ឲ្យសោយរាជ្យស្នង
គ្រប់គ្រងបុរី តាំងយើងជាត- សួរអស់ពស្រ្តង ៗ នាងស្តាប់ព្រះប-
ន្ទូលទើបស្រីតន់ ធ្វើដោយគន្ធង យកព្រះរាជទ្រព្យ ប្រដាប់ឥតគ្គង
ឲ្យជាទានហោង សព្វទិនទិវា ៗ ហើយនាងប្រដាប់ ផ្កាភ្ញីស្រេចស្រាប់
ទៀនធូបផ្កាលា ថ្វាយសព្វទិសទេស សោឡសសួគ៌ា ចាំសីលការនា
សាងសូមបុត្រថ្ងៃ ៗ នាងថ្វាយភ្ញីផ្កា សព្វទិនទិវា ជាអចិន្ត្រៃយ ទ្រង់
ព្រះបិត្ដា ប្រាថ្នាសព្វថ្ងៃ ស្មោះពីហឫទ័យ នាងសូមបុត្រា ៗ តេជៈបារមី
សម្តេចទេវី ចាំសីលការនា កក្រើកទៅដល់ មណ្ឌលអាសនា ឧម-
ហៅទេវា អង្គឥន្ទកោសិយ ៗ ស្ដេចបើកទិព្វចក្ខុ ទតមកយល់ជាក់
ច្បាស់អស់សេចក្តី សព្វប្រការស្រេច សម្ដេចកោសិយ អ្នកហោះទៅ
នី – មន្ទទេវបុត្តថា ៗ បពិត្រអ្នកមាន បុណ្យអើយសូមទាន ព្រះអង្គ
លីលា ច្យុតចុះចាក លះលោកសួគ៌ា ស្ពានបារមីតា នៅមនុស្ស-
លោកនាយ ៗ ជាបុត្រក្សត្រា អាទិត្យវង្សា- ធិរាជគោមគាយ ទូវ-
នាងពិម្ពា ជាយាពណ្ណរាយ បើអ្នកក្រាយ ខ្ញុំជួយអ្នកណា ៗ កាល
នោះទេវបុត្ត ស្ដែងស្ដេចច្យុត ចុះពីសួគ៌ា ត្រាច់ត្រង់មកចាប់ បដិសន្ធិ
នា ផ្ទៃនាងជាយា ពិម្ពាទេវី ៗ នាងនាថទ្រង់គភ៌ ចូលទៅទូលដល់
ព្រះបាទនរបតី ទូលថាសូមទាន ខ្ញុំមានគភ៌ា ធុតឆាប់ដូចក្តី ខ្ញុំសូម

បុត្រា ៗ ស្តេចស្តាប់នាងនាថ សម្តេចក្លៃនាថ ត្រេកអរសោមនស្ស ស្តេចឲ្យស្រឹង្គារ ព្រោមព្រែងគេ នៃនាងពម្ពា គតិព្រះប្អូនស្រី ៗ លុះទសមាសា ប្រសូតបុត្រា ប្រាណប្រុសពិសី ដូចមាសនព្វគុណ តានតន់ទម្ពណី ទ្រង់កល្យាណី លើសលែងក្សត្រា ៗ ស្តេចឲ្យមេទំ ភីលៀងជិតជុំ ជិះក្រន់គេក្ស ព្រះរាជបុត្រក្សត្រ ពន្ទុកថ្ងៃថ្វា សម្តេច រាជា ថ្នាក់ថ្នមបេតី ៗ លុះចំរើនធំ បុត្ររតន៍ឧត្តម ទ្រង់ឆោមពិសី លែងក្សត្រផងណា វរភ័ក្ត្រប្រិមប្រិយ ដូចចន្ទបូណ៌មី ភ្ញីផ្លូកបាំង បែង ៗ ពុំនោះសោតណា បាក់ដូចទេវតា ប្បុតពុំលែង និម្មិតមកជា បុត្រាស្តេចស្តែង ទ្រង់នាមលើសលែង ក្សត្រផងនានា ៗ សម្តេច ជនទី ជនកនរបតី បន្ទូលត្រាស់ថា ឲ្យក្សត្រព្រាហ្មណ៍ព្រឹទ្ធ បណ្ឌិតហោ-រា គួរកពេលា ប្រសើរឫក្សពារ ៗ ទើបព្រះភូធរ បំរើនព្រះពរ បុត្ររតន៍សង្ហារ ទ្រង់ព្រះនាមហៅ ចៅសុវណ្ណកុមារ ត្រកូលត្រ កាល ពន្ទុកក្សត្រថ្ងៃ ៗ លុះព្រះជន្មស្ស បុត្រស្ងួនពុំឆា សោឡស ឆ្នាំទៃ ព្រះវរបិតា ករុណាពេកក្រៃ ទំនងឲ្យគ្រងថ្ងៃ ក្រោមតានរាជា កាលនោះព្រះបាទ ត្រាស់ប្រើអាមាត្យ ជាអ្នកភ្នាក់ងារ នាំព្រះឱង្ការ រាជសារទៅថា នឹងអស់ក្សត្រា ទាំងរាយឯកក្សត្រ ៗ ដ្បិតអញ្ជឹងឲ្យ កូនអញសេពសោយ រាជម្រុសម្បត្តិ ឲ្យអស់ក្សត្រា នាំនារីរតន៍ បុត្រីមហាក្សត្រ ចូលមកថ្វាតថ្វាយ ៗ ព្រះសុវណ្ណកុមារ ត្រកូលត្រកាល

ជាក្សត្រពណ្ណរាយ ទតសព្វសពាង្គ នៃនានាទាំងឡាយ រើស ឯងឯនាយ តាមសព្វព្រះទ័យ ។ ក្សណនោះអាមាត្យ ក្រាបទូលព្រះបាទ ក្សត្រាជៀសជ័យ នាំព្រះឱង្ការ ពជសារក្សត្រថ្វៃ ចេញទៅគាប់ត្រៃ ដល់អស់ក្សត្រា ។ ថ្វាយព្រះពជសារ ពីព្រះភូបាល អាទិត្យវង្សា ឲ្យនាំសារស័ព្ទ មកប្រាប់ក្សត្រា ឲ្យនាំកញ្ញា អស់បុត្រីក្សត្រ បវចូលទៅថ្វាយ ក្សត្រថ្លៃពណ្ណរាយ ចមទៅចក្រវត្តិ ស្តេចនឹងទៀតជា ពនិតាបុត្រគេន មហេសីមហាក្សត្រ ព្រះសុវណ្ណកុមារ ។ ឯអស់ក្សត្រា ឯកសតពជា ស្តាប់ព្រះឱង្ការ ស្រេចហើយប្រាមប្រាប់ បង្គាប់ភ្នាក់ងារ រៀបចណ្ណការ គាប់ ៗ គេតត្រៃ ។ អាមាត្យវីរថ្កាន ក្រាបទូលក្សត្រកុន្ត ព្រះចៅចមត្រៃ អាទិត្យវង្សា ពជាជៀសជ័យ ស្តេចជ្រាបព្រះទ័យ សព្វប្រការធន៍ ។

បទព្រហ្មគីត

ក្សណនោះអស់ក្សត្រា រៀបចណ្ណការហើយហោន សឹងប្រាប់បុត្រស្ងួនគ្រន់ ឲ្យប្រដាប់តួទៃ ។ ឯអស់ពជកញ្ញា ព្ធបតាប្រាបញោះនៃ ត្រេកអរឯងពេកក្រៃ ចង់ជាអយិអគ្គមហេសី ។ នាងតែងប្រដាប់អង្គ សោតសឹងទ្រង់ព្រះពស្ត្រថ្មី អស់អង្គនាងនារី សឹងតែងតួទៃណា ព្រះពស្ត្រប្រពៃផ្លូង ប្រដាប់អង្គដូចទេវតា ទ្រង់គ្រឿនអម្ពពស្ត្រា ដូចស្រីសួគ៌និម្មិតមក ។ នាងខ្វះទ្រង់ព្រះពស្ត្រ ទិព្វស្រេចស្រស់ហើយ

នាងយក សុភ័គទៀវចំមក ដណ្តាប់ដើរលំអអង្គ ៗ នាងខ្លះព្រះពស្ត្រព្រៃ ស្បៃតាំងនៃល្អបញ្ចូង ដណ្តាប់ជិតជល់អង្គ ដូចស្រទាប់ស្រទំមេឃ ៗ ព្រះភ័ក្ត្រផូរផង់ផាត់ នារីគេទំរូបល្អពេក ស្អាងអង្គឯងអនេក ប្រដាប់ដូចស្រីសួគ៌ា ៗ នាងខ្លះរូបល្មមល្មៃ ទ្រង់កោសេយ្យផុសផលផ្កា ជាក្បូរក្បាចនិមាលា គូតានជាសជកមៃមាស ៗ ទ្រង់ព្រះសុភ័គសចំជាយជរប៉ាក់ដេរជាស ដណ្តាប់ដើរយានយាស យល់ប្រដាប់ស្រគត់គូ ៗ នាងខ្លះទ្រង់ព្រះពស្ត្រ ប៉ាក់ស្រេបស្រស់ធ្លាក់ជាក្បូរ សូត្រសែសយរ៉ះយោល រន្ទាលទៃងទាំងកក្រោ ៗ ទ្រង់ស្បៃកោសេយ្យឯក ល្អិតល្អពេកពណ៌ដូចប្បា សូត្រសៃមកែមកាល់ផ្កា សៃសយសោតរំលេចលាយ ៗ នារីនាថក្រមុំតូច ប្រដាប់ដូចស្រីសួគ៌នាយ អស់អង្គទ្រង់ឆោមឆាយ ដូចស្រីសួគ៌និម្មិតមក ៗ ប្រុសណាយល់សំអាង រូបគេទំនាងនាថពន្ធុកស្រូបចិត្តនឹកគិតរក ស្រីឯទៀតពុំផុនណា ៗ នាងខ្លះព្រះពស្ត្រសស្រេចស្រស់ល្អបរិបូណ៌ជា សឹងប៉ាក់លាក់លៀមជរ ជាយជិតឯងល្អប្រពៃ ៗ ទ្រង់ព្រះសុភ័គស្វាយ ទៀវប្រះលាយគេងកោសេយ្យ សូត្រសៃសយមាសមៃ កែមដោយផ្កាពុម្ពផង ៗ នាងខ្លះស្បៃកោសេយ្យា ប៉ាក់សឹងផ្កាភ្ញីទាំងទង ព្រះពស្ត្រទ្រង់នោះផង សៃសយកែមកាល់ជាប៉ាក់ ៗ ទ្រង់រូបឆោមសោភា ស្រឹកញាសមសោភ័គ សមទ្រូវព្រះពស្ត្រប៉ាក់ ដូចគល់ស្រីទេពអប្សរ ៗ នាងខ្លះព្រះពស្ត្រប៉ាក់ សៃសយ

ឆ្លាក់កែមបុប្ផា សុភ័គខ្វាញក្តាមណា ប្រដាប់ដោយពណ៌ទៃ ៗ ខាង
នាថនារីរត្ន ផន់ផ្ទូរផាត់ស្រស់ល្អថ្លៃ ទ្រង់ធាមឆាយប្រពៃ សមទ្វូរ
គ្រឿងប្រដាប់ក្បាត់ ៗ នាងខ្វះទ្រង់ទៀនដាំ ស្បៃដកគាំសម្បូររត្ន៍ សូត្រ
កែមផ្តល់ផ្តេកផ្តិត ប៉ាក់ផុលជាពណ៌ផ្កាគ្រប់ ៗ ក្រអូបក្រអែបដុំ នាងក្រមុំ
តូបដណ្តប់ ពីដោរដូចអ្នកអប់ ដោយសុភ័គនាងនាថទ្រង់ ៗ ស្រេច
ស្រស់ល្អលើសលន់ នាងស្រីគន់ប្រដាប់អង្គ ប្រុសណាយល់ហើយរ-
ង្វើនចិត្តដោយរូបនៃនាង ៗ នាងខ្វះខ្លួនមូលក្ញុំ ស្ងួរក្រមុំឆោមសោភា
ទ្រង់ស្បៃជម្ពូផ្កា ប្រុះដោយដរសេសយសែម ៗ សំពត់បរិបូណ៌ថ្មី ទេស
ពិសីហើយកាល់កែម សែសយសូត្រសក់សែម រំលេចលាយកែម
កាល់ទង ៗ នាងទ្រង់គ្រឿងប្រដាប់ ប្រដាប់ស្រាប់ស្រេចហើយហោង
ផាត់ផាយដើរលំញង- លំអង្គនាងនារី ៗ សម្លៀកសោតល្អស្រេច
អស់ក្បូរក្បាច់កងបុត្រី សក់សោតបត់បួងថ្មី ស្នៀតសក់សែមកែមដុំដិត ៗ
ព្រះហស្តនាងនាថទ្រង់ ព្រះវររង់រតនពិចិត្រ សីងទ្រង់គ្រឿងល្អពិត
លាបម្សៅផង់ផាត់ណា ៗ ផូរកក្រ្តាស្រស់ស្រេច ស្រីសម្តេចវរសោ-
ភា លាយលាបសឹងបួងបុទ្ធ័ ធុំក្រអូបក្រអែបលន់ ៗ ទាំងសង
នៃព្រះកាណ៌ ទ្រង់ត្រសាល់មាសវែងទង់ ហើយទ្រង់ព្រះសុគន្ធ
បុប្ផាផងកែមកេសា ៗ ហើយនាំយកព្រះឆាយ ទតសព្វសាយអស់
អង្គារ ថ្ពាល់ឡើងដូចផលា មាត់ប្រាងមាសមានរស្មី ៗ ព្រះភក្រ្ត

វង្សបន្ទ ចែងសោភ័ណទានក៏ កម្មោស្រស់ស្រួលស្រី ដូចបុប្ផាយកៅ
ទណ្ឌណា ៗ សុផ្ទនដូចទន្ទាប មាសមកផ្កាប់នៅទុក អស់អង្គកជ
ធីតា សីងពិប័ពិសេសសម ៗ បុត្រីស្តេចយេឯក ល្អពន់ពេកសិន
ក្រមុំ ប្រដាប់អង្គឧត្តម ដោយដំពូកលីលាទៅ ៗ រកលៀនជុំផិត ភ្ញាក់
ផ្ការពុំទូតរស្មិតនៅ តែងមុខសោះឲ្យក្តៅ ពុំឲ្យហ្នឹងសម្បុរស្រី ៗ សៅ
ជ័យខ្ញុំអស់នាង វៃហសនិងខាងជើងហត្ថ ដល់ក្រុងទេពបុរី ទើបអាមាត្យទៅ
ក្រាបទូល ៗ សម្តេចព្រះបិតា ថ្លៃយកជាមេនូសូរ ស្តេចស្តាប់អា-
មាត្យទូល ជ្រាបព្រះទ័យព្រះកូបាល ៗ ស្តេចទ្រង់ព្រះបណ្តាំ ត្រាស់
ឲ្យនាំអស់នាងនារ៉ា រៀបពេងព្រះកូបាល ឲ្យអញ្ជើញរាជបុត្រា ៗ រតន៍
រាជកុមារ ស្តេចត្រាណស្រម៉ឹម មកដល់ព្រះបិតា ព្រះអង្គក្រាបថ្វាយ
បង្គំ ៗ ពីព្រះអង្គត្រាស់ថ្វាត់ ហែកូនរតនមាសឧត្តម អ្នកបេញ្ចរាជ
ពេងមៀ ទុតក្រមុំអស់បុត្រក្សត្រ ៗ តាមតែអ្នកមាសថ្លៃ សព្វព្រះទ័យ
រើសយកថ្វាត់ អស់នាងនារីរតន៍ តាំងរយងការអង្គនោះណា ៗ សម្តេច
ព្រះកូបាល ស្តាប់ឧត្តិព្រះបិតា ស្តេចថ្វាយបង្គំហោ មកប្រដាប់ស្អាង
ព្រះអង្គ ៗ ព្រះពស្ត្រប្រពៃពេក ល្អអនេកទើបទេសធ្នន់ ហាក់រូបរាជ-
ហង្ស ហើរចុះវាបពីកវង់ក្បា ៗ សូត្រសែមសៃសយការ កែមត្រប
ពណ៌ស្រស់សោភី រំលេចដោយពណ៌ក្បា ដេរផាសដោយពណ៌ទំនៃ ៗ
ស្តេចទ្រង់ព្រះកូសា ប៉ាក់ផ្កាលផស្រស់ប្រពៃ កញ្ចក់ក្អកមាសថៃ រំលេច

លាយតាមពណ៌ណា ៗ ព្រះហស្ថទាំងពីរទ្រង់ ព្រះទំរង់រតន៍ឆោមឆាយ
រស្មីឆ្មុះពណ្ណរាយ ភ្លឺប្រវាត់ដូចតារា ៗ ទើបស្តេចទ្រង់ព្រះមកុដ វិសេស
សុទ្ធសឹងសុវណ្ណា ដាំដាសរដាយត្បូងដា កែវកាល់កែមភ្លឺប្រវាត់ ៗ
ស្រេចហើយព្រះរាជា ស្តេចលីលាចេញរោងរតន៍ ព្រះអង្គគង់ថេរបិត
លើគ្រែទេនទិព្វសុវណ្ណា ៗ នាងនាថក្រាបប្រណម្យ ថ្វាយបង្គំព្រះ
រាជា រៀបរោងរាលរាយគ្នា អង្គុយគាល់ព្រះនរបតី ៗ អស់នាងនាថ
និម្មល ហាក់ដូចគល់ទេពសួគ៌ស្រី គង់គាល់ឥន្ទ្រកោសិយ នៅនា
សួគ៌ត្រៃត្រឹង្ស ៗ នាងនាថទាំងរយឯក អតិរេករាជធីតា បងប៉ិត្តគិត
ប្រាជ្ញា ប៉ងស្រឡាញ់ព្រះបមត្រៃ ៗ ក្នុងណោះព្រះរាជា ទតអង្គ
នាងនាថនៃ ពុំសព្វព្រះហឫទ័យ ទឹងអស់នាងដល់តិចឡើយ ៗ ឯ
អស់នាងនាថយល់ ភូបាលក្សត្រត្រាណត្រើយ ពុំសព្វព្រះទ័យឡើយ
នាងក្រាបលាព្រះអង្គទៅ ៗ

បទកាកគតិ

កាលនោះណា ព្រះវរមាតា បិតាចមទៅ ស្តេចបើកព្រះសូរ
បន្ទូលក្រេវ ត្រាស់ដណ្តឹងទៅ បុត្ររតន៍ពុំងា ៗ កូនអើយទុកអ្វី
អស់ទាំងនារី ឯកឯងអង្គា ក៏កូនពន្លក មិនយកនាងនាថ ផលមួយ
ជាតិជា អឃិអគ្គមហេសី ៗ ទើបពុទ្ធង្កូរ ក្រាបបង្គំទូល ព្រះ
ជនកព្រះជននី ថាខ្ញុំមើលជាក់ នរលក្ខណ៍នៃស្រី ទាំងអស់នោះក្តី ពុំបាន

ឡើយណា ៗ សឹងបើកសឹងចង់ សឹងបំពេញឥទ្ធ សឹងស្អាងសាត្វា
សឹងឥតខ្លាសលន់ សសន់មាយា សឹងឥតបរិយា ឥតនរលក្ខណ៍ផង ៗ
ព្រះវរបិតា ស្តាប់បុត្រពុំឆ្លា ក្រាបទូលចោះហោង ស្តេចបើកព្រះសូរ
បន្ទូលវិងស្នង ត្រាស់ថាទៅហោង នឹងបុត្រពុំឆ្លា ៗ បើបាក់ស្រាល់ស្រី
ឲ្យបានដូចក្តី បំណង់ចិត្តបា ពោះរស់ទាំងស្រី លោកិយនេះណា ពុំ
គាប់ចិត្តបា ដល់មួយឡើយហោង ៗ ក្រែងតែស្រីសួគ៌ ប្រពៃគាប់
គួរ ថ្ងៃថ្មាកន្ទង គ្រប់ទ្វារនៃលក្ខណ៍ ឥតអ្នកដូមផង ដូច្នោះឯងហោង
ទើបគាប់ចិត្តបា ៗ រាជកុមារ ស្តាប់ព្រះឱង្ការ ព្រះវរបិតា បន្ទូល
ទ្រគោះ ដូច្នោះហើយណា ព្រះអង្គក្រាបលា ទាំងពីរគ្រៀត្រថ្ងៃ ៗ មក
ថ្កានប្រាសាទ ប្រសើរស្អាងស្អាត ទែនទិព្វមាសថៃ សេពសុខក្សេម
ក្សាន្ត ឥតមានភិតភ័យ ប្រក្រតីសព្វថ្ងៃ ទីងបរិភារផង ៗ កាល
នោះថែនមាន អ្នកការពារប្រាណ សឹងនាយជាងទង ពេះបប់សព្វសារ-
ពើការកន្ទង លើសលែងអ្នកផង ទូទាំងលោកា ៗ មានកាលមួយ
ថ្ងៃ ជាងទាំងពីរនៃ និយាយផង្គា ដំណាលអ្នកការ ថាជាមហិមា
ឥតអង្គអ្នកណា នៃទឹងស្មើបាន ៗ ជាងមួយអួតថា អង្គអញនេះណា
ប្រុសប្រាជ្ញមាន ឆ្លាក់ឆ្លៀកក្បាច់ ម្តេចៗ ទូរប្រាណ អង្គអញឥត
មាន អ្នកណាដួមផង ៗ ជាងមួយអួតថា អង្គអញនេះណា ប្រាជ្ញ
កន្ទង ពោះបទនីធ្វើ សារពើការផង ឥតអ្នកណាហោង ធ្វើដូមអញ

ផុន ៗ ជាងទាំងពីរស្អុត ប្រកែកប្រកួត គ្រោធពន់ប្រមាណ នាំគ្នាចូលទៅ ទូលឲ្យក្សត្រក្សាន្ត ស្ដេចស្ដាប់ហើយមាន ព្រះបន្ទូលថា ៗ ហៃជាងទាំងពីរ បង់ធ្វើការកើត ប្រឡងប្រាជ្ញា បើច្នោះចូរទៅ វិលទៅគ្រឹះហា ៈ ចូរជាងធ្វើជា ការផងទាំងឡាយ ៗ ហៅយកមាសប្រាក់ ដំដែឆ្លាក់ឆ្លាក់ ក្បូរក្បាច់ក្បូរក្លាយ ជាងធ្វើជាភាព ដកបសម្លាយ ធ្វើទាំងអាយនាយ ដោយចំណេះណា ៗ ជាងទាំងពីរស្ដាប់ ព្រះបន្ទូលប្រាប់ ស្រេចហើយក្រាបលា វិលវិញទៅឋាន ដល់ឋានគ្រឹហា ប្រដាប់ប្រដា កាន់ការសារពើ ៗ សឹងប្រកួតគ្នា តែងតាមប្រាជ្ញា សព្វសារពើផង ការតែមក្បូរក្បាច់ ស្រាប់ស្រេចឥតស្មើ ជាងទាំងពីរធ្វើ ដោយតួទៃ ៗ

បទពុំនោល

កាលនោះជាងទាំងពីរនៃ តែងតាក់តាប់ក្រៃ កំសឹងកាន់ការខ្វឃាត ៗ ជាងមួយធ្វើដហ្វាំប្រាសាទ ប្រសើរស្អាងស្អាត គំនូរគំនាប់ប្រពៃ ៗ ទាំង ៤ គ្រោងព្រាយល្អក្រៃ មាសមានដំឡៃ ពិចិត្រនូវរតនរេខា ៗ ប្រាសាទតែមួយនោះណា មានទ្វារបេញជា ប្រាំពីរ-ប្រាំពីរជាន់ជុំ ៗ បគុនៃសសរស្ដក មាលមាសខែនទុំ កំទ្រប្រាសាទប្រាំពីរ ៗ សសរមាសមួយមានពណ៌ ឆ្លាក់ឆ្លាក់វល្លិគ្រប់កបទុមដំបរ ៗ របនាជាងគូររូបមករ កំទ្រសសរ កំពូលហើយ

ពាំក្លីមាស ៗ ក្ងិក្ងក់កញ្ចក់ពេញកាស ដាសដោយដេរដាស រំលេច
រំលោងចុះផ្ទៅ ៗ ប្រាសប្រាលបរន្ទាលល្ហៅ មាលមាសឆ្អិនផ្អៅ
ត្រចង់ត្រចះឆើតឆាយ ៗ ត្របកបទុមរីកពាយ រៀងពល់សត្វសាយ
ប្រពាក់ប្រពន្ធវង់ក្បិ ៗ ក្ការបែនគ្រែខ្ទេនមាសថ្មី ធ្លាក់ផ្ទៅក្បៀល្ងៃ ជា
គ្រុឌកំបាំងនាគា ៗ ហោះទ្រទ្រគ្រែខ្ទេនសុវណ្ណា តែងតោងបាត្ត
ក្រអើតក្រអួនសួយស្អើត ៗ ភាពនាគហើយហាក់បីចំអើត រូបរស់គប
កើត កុម្ភណ្ឌនៅជើងគ្រុឌគ្រប់ ៗ បង្អួចតែងរៀងសាយសត្វ ជើង
ទៀនទល់គ្រប់ របរបស់ពលពាយ ៗ ដោយតួប្រាសាទសត្វសាយ
ជាងជាពយក្លាយ កំបាំងទ្វារទង់ក្បៀល្ងៃ ៗ គ្រប់ជ្រុងសសរតែងពល់
ធ្លាក់ផ្ទៅគ្រប់ពណ៌ កំរៀងកំពបភាពផង ៗ រូបរាជសីហ៍ហារះផ្សង ចុះ
ចាប់ម្រឹគយូង សំដែងទុះតេជះមហិមា ៗ កេសររាជសីហ៍សោតណា
ចេញពីគុហា ហើយចាប់អស់បុដ្ឋផង ៗ រូបគ្រុឌហោះចាប់នាគ
ផង សារពើភាពផង អនេកអន្ទគណនា ៗ រូបហង្សចុះចាប់បុដ្ឋ
ទំទឹមទៀបគ្នា ប្រចឹកប្រចាប់វង់ក្រ ៗ ក្របកបទុមកែវ រូបសត្វបក្សី
កំស្ទួកំសៀវទំទង់ ៗ រូបសេកសារិកាសោតហោង ទំទឹមផ្អៀងផ្អង
កំបិកទូរគេសរផ្កា ៗ រូបបក្សីផងនានា ច្រើនពណ៌ភាសា ខ្លះហើរខ្លះ
លោតខ្ទះលេង ៗ សាយសត្វប្រាសាទធំធេង ដោយផ្ទាំងទូវល្ងៃន
ប្រដាប់របនាពពណ៌ ៗ មុខដាប់ជង្ក្ការរៀងពល់ ហាក់ហង្សកែម

កាច់ មករក៏ពាំគ្គក់កោជ្រ ៗ ស្រក់ស្រកាស្រស់ស្រេច ភ្ញីល្វិ
លូតលេច ត្របកបទុមរ៉កពាយ ៗ ត្រឹស្វា ក៏កំពូលគានឃ្វាយ មាស
មៃរោមឆាយ ត្រដៃតត្រដឹងដោមដួប ៗ កំពូលកំពស់ស្រេងស្រួប
គ្នំគ្គក់កល់រួប ដំណែកដ៏ដណ្តូបទឹកទាល់ ៗ រូបទេពប្រណម្យរៀងពល់
ក៏កាន់ភ្ញីល្វិ ពិពណ៌បដ្ឋានត្រប់ ៗ ប្រាសាទប្រសើរមណ្ឌប ផ្ទាក់
ផ្ទៅសុសសព្វ សំរិទ្ធរូបស្រីទេពអប្សរ កាន់ផ្កាឈូកមាសដំបរ ស្រង់
ពស្ត្រអម្ពរ ក៏ឈរត្រង់រូបរៀងពល់ ៗ កន្ទាលត្រប់ទ្វារមណ្ឌល
រៀងរូបទៅពល់ កំពូលកំពែងក្រមក្រៅ ៗ ក្បាច់ដៃដោយស្ពានហាល
ទៅ រូបទាគទិត្យនៅ សន្ទឹកងសងខាងផ្លូវស្គាំ ៗ ឯក្បាលលើកពពារ
ទាំ ផ្សៀងផ្អងយៀងយ៉ាំ នៅនាប្រាសាទសុវណ្ណ ៗ រាជសីហ៍សឹង
យោរយ៉ាហា គីលែនលៀងកា ក៏ឈរដោជ្ជររៀងកាយ ៗ ប្រែ
ប្រឹងបីសំឡឹងឈ្មោកឆ្ងាយ មៀងមើលសព្វសាយ ប្រយុទ្ធប្រយ័ត្នត្រប់
ទ្វារ ៗ ប្រាសាទមាសមៃរន្ទាល រុងរឿងប្រាសប្រាល ចម្លាក់ចម្លៅ
ស្រស់ស្រេច ៗ រុងរឿងក្បូរក្បាច់រលេច ផ្ទាក់ផ្ទៅស្រស់ស្រេច
រលេចរលង់ផ្អូនផ្អៅ ៗ ម្រឹគាមាសមៃចាំនៅ សាយសព្វហាងក្រៅ
រហិតរហង់សាយនាយ ៗ ល្អល្អះបីត្រចះឆើតឆាយ ផ្អិនផ្អៅព្រាងព្រាយ
ពិចិត្រនូវរៈគន៌រេខា ៗ ហាក់ដូចពិមានឥន្ទ្រា ចុះចាកសួគ៌ា ក៏ស្រុត
មកនៅផែនដី ៗ ដាំងមួយប្រដាប់ឃ្មាតខ្មី ដារូបបក្សី នូវរូបម្រឹគ

សម្ងាយ ៗ សឹងជាងផាយន្តសព្វសាយ រូបសត្វទាំងឡាយ
ផោយពណ៌ទីទៃនានា ៗ យន្តមករបវរថ្ងៃថ្លា ហែលលេងលីលា
លលើកណ្ដាលជលធី ៗ ផ្ទុកផ្ទោះឃ្នោះស្មើទាំងទ្វី ស្រកាទូវស្រកី
រូបហាទវិញ្ញាណរូបរស់ ៗ រាតរាយទឹកខ្វាយខ្ពង់ខ្ពស់ អស់អង្គស្រេច
ស្រស់ ប្រដាប់សឹងមាសប្រោសប្រាល ៗ យន្តទាគលោលោតពពារ
អរឯងត្រអាល ក៏ហែលកណ្ដាលជលសា ៗ ឃ្មាតខ្វាញ់ហាក់ដេញ
មច្ឆា ត្រីផងនានា រេករឹងយន្តទាគនោះ ៗ យន្តរាជសីហ៍ហោះហៀរហោះ
ប្រឹងប្រញាណស្ទូវញាស្ទុះ ក៏ចុះចាប់ម្រឹគយង់យ៉ូង ៗ យន្តកេសររាជ
សីហ៍ឆង ចរចេញលេងលង ក៏ហោះកណ្ដាលវេនភី ៗ ចុះចាប់ក្ដិបក្ដាប់
ទន្ទីក្ន ពោចបាទរូបធី រូហានរូបសត្វវិស័យ ៗ ប្រែប្រឹងបីសន្ធឹងវិល
វៃ ទេត្រនោះបរិតៃ ក្រឡេកក្រឡៅដងសំឡឹង ៗ យន្តមួយធ្វើជា
រូបសិង្ហ ឈរឈប់ប្រែប្រឹង ក្រឡេកក្រឡៅទេត្រា ៗ យន្តគីលៃទន្ទូវ
លៀងគា ប្រយុទ្ធទូវគ្នា កណ្ដាលនៃអាកាសកង ៗ យន្តអៃរាវូបផត
ឆ្គង់ ចរចេញលេងលង ក៏ហោះកណ្ដាលវេហាស៍ ៗ យន្តគីលៃន
សោតលីលា ពើបទឹងអៃរា ក៏ប្រយុទ្ធកណ្ដាលនភី ៗ សីហៈគីលៃទាំងក្បី
ទាំងទន្ទីរកច្នី ត្របកបទុមសុវណ្ណ ៗ យន្តត្រុឌៈធៀងឆាបនាគា
នាគព័ន្ធហត្ថា សំដែងទូវតេជៈបីពន្ទឹក ៗ យន្តខ្វាចាំចាប់ម្រឹគ ក្រាប
ក្រោមព្រៃព្រឹក្ស ក្រឡុះក្រឡាប់ស្ទុះស្ទាត់ ៗ ហាក់រូបរស់វិស័យសត្វ

ស្ទុះសាធពេកក្លាត់ ក៏ស្ទុះកំលោតរំលៃ ៗ យន្តដៈសារសោតស្រមស្រែក គោតគៀងព្រៃព្រៃ ក៏ស្រប់ដោយម្ចប់អង្គា យន្តគោយន្តតាមហឹសា កាពផងនានា អនេកខន្ធណាស់នៃ ៗ យន្តបក្សផងច្រើនក្រៃ ទំដោយ ព្រឹកព្រៃ ប្រចឹកប្រចាប់ទងក្តិ ៗ ខ្លះសោតលេងលោតដោយដី ប្រដាប់ ទងក្តី ក៏ទំលេងលើព្រឹក្សា ៗ យន្តសេកនូវយន្តសារិកា ទំម ទំនូវគ្នា ក៏ចឹកនូវបុប្ផាផង ៗ យន្តកិន្នរីសោតហោង យានយាសផ្សៀង ផង ទាំងគូកំរេពាំ ៗ កេងកោងយាសយានទន្ទាំ ប្លានបទលំនាំ ដរជួរដរដាយកេសរ ៗ យន្តរូបស្រីទេពអប្សរ ទ្រង់ពស្ត្រអម្ពរ ក៏កាន់នូវក្លិទាំងទង ៗ អពំទន់កូនលំញង ស្រេចស្រស់ឥតគ្គង ស្រលួតស្រឡះឆោមឆាយ ៗ អស់រូបសត្វផងសម្ចាយ ហាក់ពីសួគ៌ាឆាយ ច្បុតចុះបាតមកណា ៗ ដាំងទង់ទាំងពីរអង្គា បំណោះសេរីគ្នា អនេក អនន្តពេកក្លាត់ ៗ សម្តេចព្រះបាទចមក្សត្រ ស្តេចឲ្យមណីរតន៍ ពិចិត្រនូវមាសសុវណ្ណ ៗ គួឲ្យដាំងធ្វើផង់គ្នា ទាំងពីរអង្គា ប្រដាប់ធ្វើជាហង្សយន្ត ៗ ទើបដាំងទាំងពីរគិតគន់ ធ្វើជាហង្សយន្ត ប្រដាប់នូវរតន៍រេខា ៗ គួហង្សបញ្ចង់សោតណា មាលមាសថ្ងៃថ្វា ក៏ដាំនូវត្បូងពត់ពយ ៗ ល្អួសលេចក្បូរគ្បាច់ក្ញូបក្លាយ ក្លីរលៀលេចលាយ ក៏ប្រាលរន្ទាលឆេតឆាយ ៗ

(នៅមានត)

# សុភាសិតជាតិយួន

លោក ភ៉យ-ប៊ុក ដកស្រង់ រៀបរៀង

១– ត្រូវរកផ្លូវវែង ដើម្បីនឹងសាកមើលសេះ ត្រូវប្រើពេលយូរ ដើម្បីនឹងសាកមើលមនុស្ស ។

២– ក្រោយដែលបានបរិភោគបាយ ត្រូវលៃលកទុកម្ហូបសម្រាប់-ពេលបាយថ្ងៃក្រោយទៀត ។

៣– ដើម្បីឲ្យបានល្អ ត្រូវជ្រើសរើសពូជឲ្យបានល្អ ។

៤– រឿងធ្វើដំណើរត្រូវសួរចាស់ រឿងនៅផ្ទះឲ្យសួរក្មេង ។

៥– ដើម្បីនឹងធ្វើឲ្យគូក្ដីទាំងសន្ធានជាគ្នាវិញ ត្រូវតែបណ្ដោយឲ្យក្ដីនោះ បិតនៅអស់កាលដ៏យូរ ។

៦– បើចង្កៀងរលត់ហើយ ផ្ទះថ្មនឹងផ្ទះស្បូវគ្មានផ្សេងគ្នាទេ ។

៧– កេរ្តិ៍ឈ្មោះល្អប្រសើរជាងគ្រឿងសំលៀកបំពាក់ល្អ ។

៨– វាយស្គរនៅមុខទ្វារ អ្នកតាផ្គរ ។

៩– បង្ហាញកាន់ប៉ូវថៅទៅមុខជាងឈើ ។

១០– កាន់ត្រីដៃទាំងពីរ ។

១១– បើអ្នកកិនស្រូវ កុំពប្អនទៅដៃ ។

១២- ទឹកខ្លាំង ដេញវិចារណញ្ញាណចេញបាត់ ។

១៣- គុណធម៌សម្លាប់រូបល្អ ។

១៤- បើកាលណាគេមានប្រាក់ គេបង់ទិញនាងទេពធីតាមួយក៏បាន ។

១៥- បើអ្នកលក់ការុងប្រាក់ពេញ អ្នកពោលពាក្យកុហកក្លួតយ៉ាងណា ក៏អ្នកឯទៀតស្តាប់ទាំងអស់ ។

១៦- ដង្កូវមួយដាក់ក្នុងឆ្នាំងសំល្យ នាំឲ្យខូចសំល្យទាំងឆ្នាំង ។

១៧- បើគេមិនចូលទៅក្នុងរូងខ្លា ធ្វើម្តេចគេនឹងចាប់កូនខ្លាបាន ។

១៨- ជើងខ្លួនឯងប្រឡាក់កកមិនគិត ទៅអុជឯចន្លុះឈូលមើលជើងអ្នកដទៃទៅវិញ ។

១៩- ចំពោះកំឡាំងរលកខ្លាំង កុំឲ្យបោះបង់ចែវចោល ។

២០- កុំឲ្យស្ទាបអង្អែលពុកមាត់ខ្លា ។

២១- អ្នកឃ្លានទទួលទានអ្វីក៏ឆ្ងាញ់ ។

២២- កុំទុកឲ្យមាន់ញីអ្នកដទៃកកាយស្រូវរបស់ខ្លួន ។

២៣- បើចង់មានទ្រព្យ ឲ្យសងបំណុល ។

២៤- សំដីច្រើន ការខុសក៏ច្រើន ។

២៥- ទំរកម្ពុលមួយនៅក្នុងបាតសមុទ្រ ។

២៦- បើចូលស្ទឹងតាមបត់ បើចូលផ្ទះតាមប្រពៃណី ។

២៧- អ្នកចេញដើរពេលយប់ញឹកញាប់ទាល់តែប្រទះខ្មោចលង ។

២៨- អ្នកលេងកាំបិតញឹកញាប់ទាល់តែមុតដៃ ។

២៩- កាលគេមកពីឆ្ងាយ និយាយអ្វីក៏គេជឿដែរ ។

៣០- មាត់ពស់ ចិត្តព្រះពុទ្ធ ។

៣១- គ្មានបាយគេត្រូវអាស្រ័យបបរ ។

៣២- បើគ្មានដំរី គេយកក្របីជាសត្វធំជាងគេ ។

៣៣- មេព្រាំមិនដែលមានផ្ទះ ។

៣៤- និយាយដូចជារ ធ្វើការដូចមនុស្សចាស់ ។

៣៥- ធ្វើការស្រេចនឹងមនុស្ស សម្រេចជោជ័យស្រេចនឹងព្រះអាទិទេព ។

## សុភាសិតជាតិចិន

លោក ប៉ុយ-ប៊ុក ជកស្រេង់ រៀបរៀង

១ ត្រូវប្រព្រឹត្តករណីយកិច្ចជាថ្នាក់ទី១ ហើយត្រូវទុកផលដែលបានមកពីករណីយកិច្ចនោះ ជាថ្នាក់ទីពីរ ។

២ សកម្មភាពដែលយើងបំពេញពីអតីតកាល តាមយើងដូចស្រមោល ឲ្យផលល្អផលអាក្រក់មកយើង តាមធម្មជាតិរបស់វា ។

៣- បុរសអ្នកកែប្រែខ្លួន ឲ្យបានពេញលក្ខណៈពល់ ១ ថ្ងៃ ។

៤- ចូរអ្នកគិតរឿងដែលមានស្រាប់ឲ្យញឹកញយ ជាងរឿងដែលគ្មានៗ

៥- អ្នកដែលមានប្រាជ្ញាចង់ឲ្យគេយល់ខ្លួនផង ត្រូវរៀនធ្វើខ្លួនឲ្យមានគុណធម៌សិន ៗ

៦- ចូរអ្នករៀសវាងតែមួយភ្លែត នូវមនុស្សកំពុងខឹង ហើយរៀសវាងជានិច្ច នូវមនុស្សលាក់គំនិត ៗ

៧- សេចក្ដីសុចរិតជាផ្លូវនៃមនុស្ស ៗ

៨- មិនមែនស្មៅទេ ដែលរារាំងមិនឲ្យគ្រាប់ឈើមានផល គឺការប្រមាទនៃកសិករ ៗ

៩- ភោគទ្រព្យនឹងកិត្តិយសជាទីប្រាថ្នារបស់មនុស្ស បើគេមិនអាចបានដោយផ្លូវសុចរិតទេ ត្រូវតែលះបង់កុំបង្អាន ៗ

១០- អណ្ដាតនារីជាដាវ ហើយនារីមិនបានទុកដាវនោះ ឲ្យដុះស្នឹមទេ ៗ

១១ មនុស្សក្នុងលោក ត្រូវបំពេញកិច្ចការសព្វៗខ្លួន ចំពោះរាជការផែនដី ៗ

១២- ឈើពុកគេច្លាក់មិនកើត ជញ្ជាំងកក់គេមិនអាចលាបពណ៌សបានទេ ៗ

១៣- វិជ្ជាជាន់ខ្ពស់ មិនត្រូវផ្ដល់ឲ្យមនុស្សល្ងង់ខ្លៅទេ ៗ

ចប់

x x x

# តាមឯកសាររបស់ក្រុមជំនុំទំនៀមទម្លាប់

## ពិធីបុណ្យចូលឆ្នាំថ្មី

ស្រី-អ៊ូ រៀបរៀង

ជនរួមជាតិជាទីស្រឡាញ់ !

ថ្ងៃនេះ គ្រប់កំណត់ពេលវេលាខួប ១២ ខែ ជាមួយឆ្នាំហើយ ត្រូវផ្លាស់ឆ្នាំចាស់ចេញ រួចចូលឆ្នាំថ្មីទៀត ។

ការចូលឆ្នាំនេះ តែងមានគ្រប់ជាតិគ្រប់ប្រទេស ក្នុងពិភពលោក គ្រាន់តែប្លែកពេលវេលាតាមទំនៀមទម្លាប់ប៉ុណ្ណោះ ដូចយ៉ាងប្រទេសអឺរ៉ុប គេចូលឆ្នាំនៅថ្ងៃទី ១ ខែមករា ដែលជាខាងដើមនៃហេមន្តរដូវ ប្រទេសកម្ពុជាយើង ចូលឆ្នាំនៅថ្ងៃទី ១៣ ឬ ១៤ ខែមេសា គឺខែចេត្រ ជួនកាលជួលទៅដល់ខ្នើតខែពិសាខក៏មាន ក៏គង់នៅក្នុងរវាងថ្ងៃទី ១៣ ឬ ១៤ ខែមេសានោះដែរ ដែលជាខាងដើមនៃគិម្ហរដូវ ។

ដោយការចង់ដឹងពេលវេលាចូលឆ្នាំ ពលរដ្ឋខ្មែរទាំងឡាយ តែងដល់ខែចន្លុះហើយ តែងទន្ទឹងចាំមើល ចាំស្តាប់មហាសង្ក្រាន្ត ដែលលោកបានរៀបរៀង ហើយបោះពុម្ពផ្សាយទូទៅក្នុងប្រទេស ដូចជាក្នុងឆ្នាំនេះ គេបានឃើញមហាសង្ក្រាន្តផ្សាយចេញទៅ មានសេចក្ដីថា ចូលឆ្នាំកុរ នៅថ្ងៃអង្គារ ៦ កើតខែចេត្រ ១៤ មេសា ១៩៥៩ នៅពេលម៉ោង៩ និង១៨នាទីយប់ ព្រះអាទិត្យចរចេញពីមីនរាសី ចូលទៅ

ឋិតនៅគន្ធីមេសពសី ដើរផ្លូវគោវិថី មានទេវបុត្រមួយព្រះអង្គ ដែលត្រូវវេនចុះមករក្សាលោកធាតុ ព្រះនាមកបស្សទេវា ទ្រង់អម្ពរខៀវ ពាក់កែវម្រោក សៀតផ្កាឈូក ព្រះហស្តស្តាំកាន់ធ្នូ ព្រះហស្តឆ្វេងកាន់ត្រីសូល៍ គង់លើសុករាជ លុះបានដឹងដំណឹង ពេលវេលាចូលឆ្នាំសព្វគ្រប់ហើយ ប្រជាពលរដ្ឋខ្មែរទាំងឡាយ ក៏មានសេចក្ដីត្រេកអរសោទរីករាយញញឹមញញែមស្រស់ស្រាយគ្រប់គ្នា ក៏ប្រុងប្រៀបរៀបរណ្ដាប់បំរុងទុកចូលឆ្នាំ ។

ដើម្បីឲ្យយល់ច្បាស់នូវពាក្យថា "មហាសង្ក្រាន្ត" ឬ "សង្ក្រាន្ត" យើងសូមអធិប្បាយតាមសៀវភៅវចនានុក្រមខ្មែរដោយសេចក្ដីសង្ខេប ។

ពាក្យថា "សង្ក្រាន្ត" នាមស័ព្ទជាភាសាសំស្ក្រឹត ប្រែថា "ដំណើរឃ្លាតចាកទី, ការឈានចូលដល់, ដំណើរដែលព្រះអាទិត្យចរចូលដល់ទីជួបមួយជុំកសិចក្រ គឺដំណើរដែលដើមនិងចុងនៃរាសីចក្រជួបគ្នា ពេញគ្រប់ជាមួយឆ្នាំ, ដំណើរដាច់ឆ្នាំចាស់ផ្លាស់ឆ្នាំថ្មី ពិធីចូលឆ្នាំថ្មី ហៅថា "សង្ក្រាន្ត" មាន ៣ ថ្ងៃ គឺ ថ្ងៃទី ១ ជាថ្ងៃចូលឆ្នាំ, ថ្ងៃទី ២ ជាពារគណ្ដាល ឬហៅថា ពារវ័នបត "ថ្ងៃទាក់", ថ្ងៃទី ៣ ជាពារឡើងស័ក គឺផ្លាស់ស័កថ្មីនៅថ្ងៃនេះឯង ។

ចុះខ្មែរយើង មានប្រពៃណីដូចម្ដេចខ្លះ ក្នុងឱកាសចូលឆ្នាំថ្មី? ។

ប្រពៃណីខ្មែរ តាំងពីបុរាណកាលមក ក្នុងឱកាសចូលឆ្នាំថ្មី នៅថ្ងៃទី ១

បណ្តាជនចាស់ក្មេង ទាំងស្រី ទាំងប្រុស ផ្លាស់សំលៀកបំពាក់ចាស់ចោលចេញ ហើយស្លៀកពាក់សំពត់អាវថ្មីៗ ដើម្បីនឹងចាំទទួលពរអំពីទេវតាថ្មី ហើយតាំងមនោសញ្ចេតនាជាថ្មី ខំខ្នះខ្នែងបំពេញបុណ្យកុសលរៀងៗខ្លួន គឺពេលព្រឹក នាំយកភោជនាហារទៅប្រគេនព្រះសង្ឃ សមាទានសីលតាមសមគួរ, ពេលថ្ងៃរសៀលបោសសំអាតទីវត្តអារាម-ព្រះវិហារ កុដិ-សាលា-ទីលានព្រះចេតិយ ដុសលាងព្រះពុទ្ធរូប, នៅខាងមុខព្រះវិហារគេបង្ហូតទង់ ដែលធ្វើដោយសំពត់ផ្ទាំងធំៗវែងៗ បក់ក្ដួយរំភើយៗ ដោយកម្លាំងព្រះពាយផាត់ៗ នៅលើដំបូលព្រះវិហារ ឮសូរសព្ទកណ្ដឹងរងំមុខគួរឲ្យជ្រះថ្លាពន់ពេក ៗ នៅគេហដ្ឋានរបស់គេទៀតសោតក៏គេបោសសំអាតរៀបចំគ្រឿងសក្ការៈសម្រាប់បូជាព្រះរតនត្រ័យ និងទទួលទេវតាថ្មី ដូចនៅទីវត្តដែរ តែពលរដ្ឋខ្មែរ ច្រើនតែទៅជួបជុំទីវត្ត ។ ពេលល្ងាចគេប្រគេនភេសជ្ជៈព្រះសង្ឃ ហើយរៀបចំគ្រឿងសក្ការៈ ធូប ប្រទីបផ្កាលា បះង្ហារគោមបូជាព្រះរតនត្រ័យ និងទទួលទេវតាថ្មី និមន្តព្រះសង្ឃចំរើនបរិត្ត-ទេសនា ។

កាលពីបុរាណ តែដល់ពេលម៉ោងចូលឆ្នាំ តាមមហាសង្ក្រាន្តបង្គាប់មកនោះ លោកគ្រូចៅអធិការជាអ្នកវាយគងធំ អាចារ្យវត្តជាអ្នកវាយស្គរ ធ្វើយគ្គនិងនិងសម្លេងគង ដើម្បីប្រកាសឲ្យដឹងថា ឆ្នាំចាស់ចេញផុតទៅហើយ និងដើម្បីទទួលទេវតាថ្មី ហើយព្រះសង្ឃចាប់ចំរើនបរិត្តទៅៗ

នៅទីវត្តទីមួយៗ ទាំងថ្ងៃទាំងយប់ គេឮតែសូរសម្លេង នៃយុវជន យុវតី កុមារ កុមារី ច្រៀងរាំ ខ្ញៀវខ្ញា គគ្រឹកគគ្រេង ទាំងលេងល្បែងផ្សេងៗ ជាគ្រឿងកំសាន្ត គឺលេងល្បែង បោះឈូង មានប្រុសម្នាក ស្រីម្នាក់ ហើយច្រៀងឆ្លើយឆ្លងគ្នា, ល្បែងអង្គុញ, កូនគោល, ទាញព្រ័ត្រ, ទាត់សី, លោតអន្ទាក់, លាក់កន្សែង ចាប់កូនខ្លែង, បញ្ចូលទា ស្តេចចង់, រាំអង្រែ, បាយខុំ; ចត្រង្គជាដើម ៗ ខ្មែរបុរាណពុំមានលេងល្បែងភ្នាល់ស៊ីសងឡើយ ៗ

មានប្រពៃណីល្អវិសេសមួយរបស់ខ្មែរ ដែលយើងពុំអាចនឹងបំភ្លេចបោះបង់បាន គឺនៅឱកាសចូលឆ្នាំនោះ កូនចៅបាននាំគ្នា ផ្តល់ទឹកជូនមាតាបិតា និងចាស់ព្រឹទ្ធាចារ្យ ហើយជូនសំពត់អាវថ្មីៗ ឲ្យស្លៀកពាក់, បន្ទាប់មក មានការលៀងភោជនាហារ ហើយកូនចៅទាំងអស់ សូមខមាទោសនិងប្រសិទ្ធពរជូនចំពោះមាតាបិតា និងចាស់ព្រឹទ្ធាចារ្យ ៗ

ថ្ងៃទី ២- ពេលព្រឹកវេរភត្ត ពេលរសៀលពូនភ្នំខ្សាច់ ហើយអាចារ្យនាំសូត្របាលីអធិដ្ឋានភ្នំនោះ ឲ្យទៅជាវាលុកចេតិយ ពេលយប់ចំរើនបរិត្ត ទេសនា ៗ

ថ្ងៃទី ៣- ពេលព្រឹកវេរភត្តជាវេន, ពេលរសៀលនិមន្តព្រះសង្ឃបង្សុកូល, ស្រង់ទឹក ប្រគេនសំពត់ស្រង់ទឹក និងទេយ្យទាន, ស្រង់ព្រះពុទ្ធរូប ៗ

x x x

## រឿងសាមកុក

## កណ្ឌទី ៣៥

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងបានឧបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

បានដោយងាយ សូមឲ្យលោកបាតឡៅពីទៅជួយគ្រោ កុំឲ្យសឹកសត្រូវកងនឹងទៅមកបាន ឯខាងជើងជាធុវចូខ្ទីនមកនោះ ជាភ្នាក់ងារលើខ្លួនខ្ញុំបានស្រាប់ហើយ ឡៅពីក៏លាឡៅប៉ៀវត្រឡប់ទៅស្រុកស៊ុនអៀវិញ ខណៈនោះ ឡៅប៉ៀវក៏បាត់បែងទាហានបានពាន់ ឲ្យឡៅគីលើកចេញទៅគ្រោស្រុកគាំងហែ ។

ឯចូឆោ លុះបានស៊ុមាអ៊ីមកទុកជាទីប្រឹក្សា ស៊ុមាអ៊ីនោះជាកូនស៊ុមាហាង នៅហ្វាយស្រុកហោឡោ ចូឆោមានចិត្តគំនិតឲ្យហៅនាម៉ឺនមុខមន្ត្រី នឹងសេនាទាហានមកប្រឹក្សាថា នឹងលើកកងទ័ពទៅវាយអាណាខេត្តខាងត្បូងសម្រេច ឲ្យនៅក្នុងកណ្ដាប់ដៃយើងទាំងអស់ អ្នកទាំងពួង

និងយល់ឃើញប្រការម្ដេច? ។ ហៃហួទុនឆ្លើយថា ឥឡូវខ្ញុំបាទឮដំណឹងថា ឡៅពីះនៅស្រុកស៊ិនអៀ បញ្ចុះបញ្ចូលទាហានបានច្រើន ហើយហ្វឹកហាត់ឲ្យស្ទាញស្ទាត់ចំណានគ្រប់ខ្លួន បើនឹងបង្អង់ទុកឲ្យយូរនឹងកំចាត់ឡៅពីះចេញដោយកម្រណាស់ សូមឲ្យលោកចាត់កងទ័ពទៅវាយស្រុកស៊ិនអៀជាមុន ហើយសឹមគិតការគេទៅទៀត ។ ប៉ូឆ្វយល់ឃើញត្រូវ ទើបប្រើហៃហួទុនជាមេកងទ័ពធំ ឲ្យលីទៀន, អ៊ូគិម, ហៃហួអានទីន ហាន់ហោ នាយទាហានទាំង ៤ នាក់នេះជាបាល័ដ្ឋទ័ព លើកពល ១០ ម៉ឺនទៅវាយស្រុកស៊ិនអៀ ។ ឈីស៊ុនិយាយនឹងហៃហួទុនទុកថា អ្នកនឹងលើកទ័ពទៅគ្រានេះ កុំប្រមាថមើលងាយឡៅពី ព្រោះឡៅពីបានខុងបេងមកទុកជាទីប្រឹក្សា ឧបមាដូចខ្លាដំសាហាវនៅក្នុងព្រៃធំ អ្នកចូររវាំងខ្លួនឲ្យល្អចុះ ។

ប៉ូឆ្វឮដូច្នោះ ក៏មានសេចក្ដីសង្ស័យ ទើបសួរថា ខុងបេងនោះគឺនរណាអេះ! ។ ឈីស៊ុឆ្លើយថា ខុងបេងនោះមានជម្រះប្រាជ្ញាណាស់ ការក្នុងអាកាសនឹងក្រោមផែនដី ក៏ដឹងយល់ស្គាល់បានទាំងអស់ ស្មើទេពតាបញ្ចូលចិត្ត ។ ប៉ូឆ្វសួរថា ខុងបេងមានជម្រះប្រាជ្ញានោះ នឹងប្រៀបប្រហែលខ្លួនអ្នកតើនរណានឹងមានប្រៀបជាងគ្នា ។ ឈីស៊ុតបថា ឯសេចក្ដីត្រិះរិះនឹងគំនិតប្រាជ្ញារបស់ខ្ញុំបាទនេះ ឧបមាដូចអំពិលអំពែក ឯជម្រះប្រាជ្ញាប្រហែលពន្លឺព្រះចន្ទ ។

ហៃហ៊្យូនបានឮដូច្នោះ ក៏អស់សំណើច ហើយដំណើបទៅចុចថា ឈើស៊ីក្លូងកើតជំកើងខុងបេង ប្រាថ្នាចង់ឲ្យលោកកោតញញើតទេ ខ្ញុំបានលើកទ័ពទៅគ្រានេះ ចង់ចាប់ខ្លួនឡើត ចង់ខុងបេងមកឲ្យបាន បើមិនបានពិតដូចមាត់ថា សូមឲ្យលោកកាត់ក្បាលខ្ញុំបានដាដំនួសចុះ ចួចថា បើអ្នកចង់លើកទ័ពទៅវាយស្រុកស៊ុនអៀនោះ តោះបានការមិនបានក៏។ ប្រការម្ដេច ចូរមកសុំសំបុត្រតាមទពជការមកដល់យើងឲ្យរឿយ ៗ ហៃហ៊្យូនទទួលពាក្យ ហើយក៏លាចេញទៅវាត់ថែងទាហានទាំងពួងតាមក្បួនទ័ព លុះរៀបរួចហើយក៏លើកចេញចាកក្រុងហ៊ូតោទៅ ។

ឯឡើត តាំងពីបានខុងបេងមកខុក ក៏ប្រតិបត្តិជាគ្រឿអាហារគ្រប់លោមិនដែលដាច់ គុនអ៊ូ-ឡៀវហ៊ុយឃើញដូច្នោះ ក៏មានសេចក្ដីតាស់តួចចិត្តនិយាយនឹងឡើតថា ខុងបេងនេះអាយុ ២៧ ឆ្នាំ គេធំជាងលោកបើនណាស់ ហើយនៅមិនទាន់ដឹងប្រាកដជាមានជម្រះប្រាជ្ញាយ៉ាងណាពោតម្ដេច ក៏លោកមកគោរពប្រណិប័តន៍ស៊ើគ្រឿអាហារធំដូច្នេះ ឡើតតបថា ខ្លួនយើងនេះ មានចបមាដូចត្រីននៀលទៅលើគោក ដែលបានខុងបេងមកខុក បីដូចយើងននៀលចុះទៅដល់ទឹកបាន បើយើងទាំង ២ មិនដឹងគុណគាលនិយាយថាអ្វីឡើយ ប្រសិនបើដឹងដល់ខុងបេងហើយ ក៏នឹងមានសេចក្ដីតូចចិត្ត ទទួលមានគេយកកេមចាមរមកជូនឡើតដោតមុកលេង ខុងបេងដើរមក ឃើញឡើតកំពុងដោតកេមចាមរដូច្នោះ ក៏

ខ្លាំងណាស់ ទើបថា ការដែលទ្រង់ការពារគេក្នុងខ្លួនមិនគិតរំពឹងគេក្រោយ លោកមកអង្គុយផាត់ពេមចាមលេងផ្លូវច្នោះមិនគួរសោះ ៗ

ទៀវពីហ៊ុនឡុងច្នោះ ក៏ហោះម្លួកចេញហើយគំនាប់ខុងបេងថា ខ្ញុំមិនសប្បាយចិត្ត ទើបយកពេមចាមរមកផាត់ម្លួកបេង ព្រោះថាទ្រង់ឲ្យទៃហ្វូសេចក្ដីទោមនស្សជាទុក្ខ ខុងបេងថា សព្វថ្ងៃនេះ ទាហានយើងមានប្រមាណ ១ ម៉ឺនប្អាយ ដែលលោកទ្រង់នៅស្ងៀមមិនខំរិះគិត ការពារគេក្នុងខ្លួនយ៉ាងនេះ ប្រសិនបើចូចូលើកទ័ពមក លោកទ្រង់រិះគិតប្រការម្ដេច ? ទៀវពីតបថា សព្វថ្ងៃនេះ ខ្ញុំក៏គិតតែក្នុងទុក្ខព្រួយពេកណាស់ បើលោកទ្រង់ឲ្យរិះគិតការពារយ៉ាងណា ក៏សូមឲ្យជួយពន្យល់មកចុះ ខុងបេងថា ឥឡូវទាហានយើងតិចពេកណាស់ ឲ្យលោកខំគិតបញ្ចុះបញ្ចូលមនុស្សឲ្យចូលមកធ្វើទាហានឲ្យច្រើនឡើងទៀត ប្រសិនគេទ័ពចូចូលើកមក ខ្ញុំបានទទួលចាត់ចែងតស៊ូនឹងចូចូមិនឲ្យថ្ងស់ការ ៗ

ទៀវពីព្រះហើយ ក៏ឲ្យបញ្ចុះបញ្ចូលបានទាហានថ្មី ៣ពាន់ បញ្ចូលគ្នានឹងទាហានចាស់ហើយ ក៏ប្រគល់ឲ្យខុងបេងហ្វឹកហាត់មិនដាច់មួយវេលា ខណៈនោះព្រួដំណឹងថា ហែហ៊្វូទុនលើកពល ១០ ម៉ឺន ចេញពីស្រុកហ៊ូដោទ្រង់មកវាយយកស្រុកស៊ុនអៀ ទៀវហ៊ុយក៏និយាយនឹងគួនអ៊ូថា កងទ័ពហែហ៊្វូទុនលើកមកគ្រានេះ យើងធ្វើជាស្ងៀមស្ងំ ឲ្យខុងបេងរិះគិតចេញច្បាំងចុះ ល្បងថ្វីដៃទ្រង់ស្មារតីប្រាជ្ញាដែលពេះដ៏ម្ហឹមមើល ឲ្យជាក់

ប្រាស់ទឹងក្អែកជាល្អប្អកក្រក់ ទៀតពីទើបឲ្យអញ្ជើញខុនផែន មកប្រឹក្សាថា ឥឡូវគេនាំទ័ពចូលមកហើយ លោកនឹងគិតប្រការម្តេច? ខុនផែនឆ្លើយថា ដែលគេនាំទ័ពចូលមកនោះមិនជាអ្វីទេ ល្មមនឹងគិតកែឲ្យយកជ័យជំនះបាន តែប្អូនលោកទាំង ២ នោះ ចិត្តរឹងរូសណាស់ មិនបានជឿស្តាប់ពប់អានគំនិតពាក្យសំដីរបស់ខ្ញុំបាទសោះ ប្រសិនបើលោកនឹងឲ្យខ្ញុំបាទចាត់ចែងតស៊ូនឹងគេនាំទ័ពចូលគ្រានេះ ខ្ញុំបាទត្រូវសូមក្រាបទូលព្រះអាជ្ញាសិទ្ធិទុកនៅខ្លួន នឹងបានបង្គាប់បញ្ជាសេនាហានទាំងពួងឲ្យសិទ្ធដាច់អហង្ការ ទៀតពីព្រះដូច្នោះ ក៏ប្រគល់ក្រមនឹងព្រះអាជ្ញាសិទ្ធិឲ្យខុនផែនហើយពន្យល់ថា បណ្តាពួកពលទាហានទាំងអស់គ្នា ទាំងធំទាំងតូចត្រូវនៅក្រោមបង្គាប់ ស្តាប់បញ្ជាការខុនផែនទាំងអស់ បើអ្នកឯណានឹងទទឹងមិនព្រមធ្វើតាមពាក្យខុនផែនទេ ត្រូវឲ្យខុនផែនកាត់ក្បាលចេញ ទៀតហ៊ុយព្ធះទៀតពីផ្លូវការជាស្រេចដាច់ខាតដូច្នោះ ក៏និយាយនឹងគួនអ៊ីចថា ឥឡូវបងយើងឲ្យអាជ្ញាសិទ្ធិទៅខុនផែនហើយ ប្រសិនបើខុនផែនបង្គាប់បញ្ជាកិច្ចការអ្វីយើងកុំគប្បីនឹងទទឹងសិនចុះ ចូរធ្វើតាមល្បងមើល ១ គ្រាសិន នឹងបានឃើញគំនិតប្រាជ្ញាខុនផែន ។

ឯខុនផែនក៏និយាយនឹងសេនាទាហានទាំងពួងថា ជំបន់ពលកុកបងកង់ដែនស្រុកសៀមនេះជាទីចំណាប់ចន្ទួនណាស់ មានភ្នំអ៊ីសាននៅខាងត្បូង ព្រៃអានលិមនៅខាងជើង ខុនជាៈឃើញនឹងបង្កប់ទាហានបាន ។

ខុងបេងក៏ឲ្យមានសំបុត្រទៅជូឡុងមកពីស្រុកហ៊ួនសៀ ហើយទើបចាត់ប្រើគួនអ៊ូ ទៀវហ៊ុយលើកទាហានម្នាក់ ១ ពាន់ ឲ្យគួនអ៊ូលើកទៅពួនបង្កប់នៅភ្នំអ៊ីសាន ឲ្យទៀវហ៊ុយលើកទៅពួនបង្កប់នៅព្រៃអានលឹម ហើយផ្ដាំផ្ដាច់ថា បើឃើញកងទ័ពហៃហ៊ួទុនលើកមកហើយ អ្នកទាំង ២ ចូរសម្ងំទាហានទុកកុំអាលលើកចេញមកវាយសិន បណ្ដោយឲ្យកងទ័ពគេកន្លងហួសចូលមក បើឃើញពន្លឺភ្លើងខាងទិសទក្សិណកាលណា សឹមឲ្យលើកទាហានចេញមកវាយខ្ទប់ទាំងសង្ខាងកាត់កន្ទុយទ័ព ហើយដុតបំផ្លាញស្បៀងអាហារឲ្យបាន ចាត់គួនបេងនឹងឡៅហង ២ នាក់លើកទាហាន ៥០០ មានគប់ភ្លើងគ្រប់ដៃ ឲ្យទៅពួនបង្កប់នៅចុងវាលភុកបង ហើយកំណត់ថា បើឃើញហៃហ៊ួទុនលើកទាហានមកដល់ទីនោះហើយពេលយាមមួយឲ្យអុជភ្លើងឲ្យឆេះឡើង ចាត់ឲ្យជូឡុងលើកទាហានចេញទៅជាកងមុខ ហើយបង្គាប់ថា អ្នកឯងត្រូវច្បាំងតែដៃនឹងហៃហ៊ួទុនគ្រានេះកុំឲ្យឃើញខាងជ័យជំនះឡើយ ចូរធ្វើជាចាញ់ថយក្រោយទៅឲ្យគេដេញចូលមកចុះ រួចខុងបេងក៏ផ្ដាំថា ដែលពាក្យយើងបង្គាប់ទាំងអស់នេះ អ្នកទាំងអស់គ្នាកុំបីធ្វេសល្ហែស ចូរទទួលធ្វើតាមពាក្យយើងគ្រប់ប្រការ ហើយឲ្យឡៅពីលើកទាហានទៅដាក់ជាជំនួយពីក្រោយជូឡុង ។

គួនអ៊ូក៏សួរខុងបេងថា លោកចាត់ចែងយើងរាល់គ្នាឲ្យលើកទៅធ្វើការសព្វគ្រប់ដូច្នេះក៏ជាការប្រពៃណាស់ហើយ ចុះខ្លួនលោកនឹងត្រូវធ្វើ

អ៊ូទៅវិញសោត ខុងបេងនឿយប្រាប់គួនអ៊ូថា អ្នកទាំងអស់គ្នាលើកទ័ពទៅហើយ យើងត្រូវនៅរក្សាស្រុក ទៀវហ៊ុយទះដៃសើចហើយថា ដែលលោកមានប្រសាសន៍ដូច្នេះ គំឃើញថាលោកមានតម្រិះប្រាជ្ញាមែន គិតយកសុខសប្បាយតែខ្លួនឯង ឯយើងពល់គ្នាត្រូវចេញទៅតស៊ូនឹងសេចក្ដីស្លាប់ លោកចូរនៅរក្សាស្រុកតែឯតុពីសាក្រយាលេងឲ្យសប្បាយចិត្តចុះ ។

ខុងបេងថា ឥឡូវខ្ញុំពីបានអាជ្ញាសិទ្ធិគ្រប់នៅនឹងដៃយើងហើយ បើអ្នកពល់គ្នាមកធ្វើព្រងើយកន្ដើយនឹងទង់ទីនឹងអាជ្ញាដែលយើងបង្គាប់ដូច្នេះក៏មិនបាន បើយើងមិនធ្វើតាមអាជ្ញាសិទ្ធិជាពិតប្រាកដទេ ដំណើរទៅមុខនេះណាទីងបង្គាប់បញ្ជាបានបាន ត្រូវតែខ្ចប់ការអេសារទៅឯង ។

ទៀវតាធ្វើយតបទៅគួនអ៊ូ, ទៀវហ៊ុយថា អ្នកទាំង ២ មិនដឹងឬថា អ្នកមានតម្រិះប្រាជ្ញានោះ តោះបើទីងដេកអង្គុយដេចក្រៃៗនៅក្នុងផ្ទះ មិនបានឃើញកិច្ចការឯណាក្ដី ក៏អាចនឹងគិតយកជ័យជំនះដល់សត្រូវឲ្យពានបាន ឬនយើងទាំង ២ កុំកាលងនឹងខុងបេងឡើយ គួនអ៊ូបានឮដូច្នោះហើយ ក៏និយាយនឹងទៀវហ៊ុយថា បើយើងនឹងទីងក្នុងគ្រានេះ ក៏នឹងពាស់ចិត្តបងយើង ។ ត្រូវធ្វើតាមពាក្យខុងបេងទៅចុះ បើមិនសមប្រកបដូចគំនិតប្រាជ្ញាដែលបានការទេះទេ គេទៅមុខសម្បន្ទោសតាមចិត្តយើងចុះ គួនអ៊ូ, ទៀវហ៊ុយក៏លាទៅការនាំទ័ពទៅរៀបខ្លួន ។

ខុងបេងក៏និយាយទៀតថា វេលាព្រឹកនេះ កងទ័ពហៃហ្វ៊ីទុននឹងលើកមកដល់ហើយ សូមឲ្យលោកលើកទាហានយើងទៅតាំងនៅជាកងជំនួយជួយខាងនៅដើមភ្នំសានចុះ ខ្ញុំបាទនឹងបីតុក, បីហាង នឹងភូតា-ហាននៅក្បែរស្រុក ហើយនឹងតែងតុឲ្យស៊ុនខៀននឹងកាន់យុងលើកចេញទៅទទួលលោកកណ្ដាលផង ឲ្យទាហានស៊ីលៀងលេងសប្បាយចិត្តទៀតពីព្រោះខុងបេងជាដូច្នោះក៏លើកទ័ពចេញទៅ តែជានៅមិនអស់សង្ស័យខឹងនឹងភៀចុះជាប្រាកដ ។

ឯកងទ័ពហៃហ្វ៊ីទុនលើកមកជិតដល់ពលកុកបង់ហើយ ក៏ចាត់ចែងពលទាហានតាំងក្បួនលើកមកជាលំដាប់គ្នា ឲ្យពលស្បៀងលើកតាមមកជាក្រោយ ទទួលពេលព្រលប់ទើបដល់ពលកុកបង់ ក្រឡេកទៅមុខឃើញឆង់ធូលីហុយព្រលោមដូចផ្សែងទៅលើអាកាស ទើបឲ្យឈប់កងទ័ពស្ដាប់ការហើយឲ្យអ៊ុំឃុំក្បួនទាហាន ឯហៃហ្វ៊ីទុនក៏បរសេះស្រូតចេញទៅខាងមុខ ក្រឡេកឃើញកងទ័ពជូឡុងលើកមក ហៃហ្វ៊ីទុនក៏អស់សំណើច ទាហានតាំងក្បួនសួរថា ហេតុម្ដេចបានជាលោកសើច ? ហៃហ្វ៊ីទុនឆ្លើយថា យើងគិតដល់ពាក្យឈីស៊ីបានជាអស់សំណើចពុំបាន ព្រោះឈីស៊ីអួតសរសើរតម្រិះប្រាជ្ញាខុងបេង នៅចំពោះមុខមហាឧបកជ យើងក៏បានឮដែរក្នុងថ្ងៃនោះ ថាបើដូចនឹងដឹងយល់ស្គាល់ហេតុទៅក្នុងអាកាសនឹងក្រោមផែនដី ឥឡូវយើងឃើញមេបខុងបេងរៀបរៀបកងទ័ព

លើកមកប្រហែលនឹងការក ដែលល្ងង់គ្មានប្រាជ្ញាសោះ ពុំនោះបើដូចគេដេញហ្វូងអម្រឹតឲ្យគេចូលទៅក្នុងមាត់ខ្លា ពាក្យដែលយើងបានពោលទុកនឹងមហាឧបកដថា នឹងចាប់យកខ្លួនឡើងពីខ្លួនបេងឲ្យបាននោះ ឃើញខឹងសមប្រកបរបស់យើងគ្រានេះជាប្រាកដហើយ ៗ ហៃហ៊ុនក៏បរពលស្រុតលើកចូលទៅ ។

ឯដូឡុងឃើញដូច្នោះ ក៏បរសេះស្ទុះចេញមកមុខទាហានទាំងពួង ហៃហ៊ុនក៏ស្រែកដេរថា ឯងនេះឆោតល្ងង់គ្មានប្រាជ្ញាសោះ មកនៅជាទាហានឡើងភី បីដូចជាខ្លាចផាច់សន្លែង ស្មើងកស៊ីតែគ្រឿងសំណែនដែលគេសែនស្ទើរអស់ស្ទើរឃ្លាន ដូឡុងឮដូច្នោះ ក៏ខឹងណាស់ បរសេះចូលប្រយុទ្ធគ្នានឹងហៃហ៊ុនបានប្រហែល ៤ ភ្លែង ក៏ធ្វើជាទាញសេះថយក្រោយ នាំទាហានទាំងពួងរត់ថយទៅ ហៃហ៊ុនបានបំណាច់ ក៏ដេញប្រវាច់ចូលទៅ ចម្ងាយផ្លូវប្រហែល ៤០០ សិន ( ២០ គី ) ហានហោក៏បរសេះទៅស្កាត់មុខហៃហ៊ុនហើយឃាត់ថា សូមឲ្យលោករង់មន្ត្រីឈប់នៅទីនេះសិនចុះ ព្រោះដូឡុងនោះមានថ្វីដៃខ្លាំងពូកែណាស់ គប្បីឲ្យលោកមិនទាន់ទៀយហត់ប៉ុន្មាន ញាក់សេះរត់ចេញដូច្នេះជាការប្លែកពេកណាស់ មុខជាធ្វើកលឧបាយបង្កប់ទាហានទុកចាំវាយខ្ចប់ប្រសប់យកជ័យជំនះលោកទេដឹង ហៃហ៊ុនឆ្លើយថា បោះបើជាដូឡុងនឹងធ្វើកលបង្កប់ទាហានទុកប៉ុន្មានអន្ទាក់ យើងក៏មិនត្រូវញញើតខ្លាច ហៃហ៊ុនក៏

បរសេះនាំពាហានស្បៀងតាមទៅ ចម្ងាយផ្លូវប្រហែល ៥០ សិនទៀត (២ គី.) ។

ទៀវពីឃើញវៃហាហ៊ួទនលើកពាហានជាប់តាមមកជិតនឹងពានដូឡុង ដូច្នោះ ក៏ឲ្យអុជផាវផាសញ្ញាឡើង ហើយក៏លើកទ័ពជំនួយចូលទៅ ជួយបំពេញពាហានដូឡុងទៀត ខណៈនោះវៃហាហ៊ួទនឃើញកងទ័ពទៀវ ពីលើកកងទ័ពជំនួយមកដូច្នោះក៏អស់សំណើច ហើយប្រាប់ពាន់ហោថា ខុងបេងរៀបរបៀបកងទ័ពបង្កប់ទុកដូច្នេះ អ្នកឃើញហើយឬ? មុខគួរឲ្យ ខ្លាចណាស់ណា ពេលនេះយើងត្រូវស្រូតលើកទៅផាន់សង្កត់ស្រុកស៊ុនអៀឲ្យបាន បើមិនបានយើងក៏មិនសូមត្រឡប់ទៅឲ្យមហាបពជឃើញមុខឡើយ ហើយវៃហាហ៊ួទនចាប់ពេលស្រូតកេងកាយចូលទៅទៀត ទៀវពីនិងដូឡុងក៏មិនបានតស៊ូ ធ្វើជារត់ថយត្រឡប់ទៅក្រោយវិញ ប្រហែលចូលក្នុងយាម ៣ ជាយ កើតព្យុះខ្យល់ងងឹតមេឃដូចជានឹងធ្លាក់ភ្លៀង ។

ឯអ៊ុគិមនិងលីទៀន ដែលឃុំនាំស្បៀងលើកតាមវៃហាហ៊ួទនមកជាក្រោយនោះ លីទៀនក៏ប្រឹក្សាគ្នាថា ឥឡូវកងទ័ពខាងយើង លើកកងទ័ពហួសចូលទៅក្នុងដែនស្រុកស៊ុនអៀហើយ ពេលនេះក៏យប់ងងឹតផ្លូវ នឹងដើរទៅក៏លំបាកមិនស្រួលសោះ សុទ្ធតែលុយភក់លុយល្បាប់ដូច្នេះបើ សឹកសត្រូវលបមកដុតភ្លើងឲ្យឆេះពីក្រោយយើង ៗ នឹងមិនទាន់គ្នាស្ទាប់ទាំង. អស់ទេឬ? អ៊ុគិមឆ្លើយតបទៅលីទៀនវិញថា អ្នកនិយាយនេះត្រូវណាស់

បើដូច្នោះ អ្នកចូរនាំអ្នកវែកសែងស្បៀងឲ្យឈប់នៅទីនេះសិន ខ្ញុំនឹងស្រូតទៅតាមឃាត់ហៃហ៊ូទុនកុំឲ្យចូលទៅ លីទៀនយល់ឃើញត្រូវក៏ឃាត់ទាហានដែលវែកសែងទាំងអស់គ្នាឲ្យឈប់បង្អង់ អ៊ុគិមក៏បរសេះស្រូតទៅទាន់ហៃហ៊ូទុនហើយឃាត់ថា លោកលើកពលទាហានរំលងដែនចូលមកក្នុងស្រុកស៊ិនអៀហើយដូច្នេះ ពេលនេះជាយប់អធ្រាត្រស្ងាត់ងងឹតផ្លូវដើរពុំឃើញ លំបាកណាស់ ប្រកន្លាងមានភ្នំ ម្ខាងមានព្រៃស្ដុកប្រសិនបើមានសឹកសត្រូវនៅពួនបង្កប់លបដុតភ្លើង យើងក៏នឹងថួសការមិនទាន់ សូមឲ្យលោកបញ្ឈប់ទ័ពនៅទីនេះសិន ។

ហៃហ៊ូទុនបានឮដូច្នោះ ក៏ភ័យស្លុតស្មារតីនឹកលើកឃើញត្រូវទើបឲ្យឈប់ទ័ពនៅទីនោះ ខណៈនោះឮហ៊ោហ៊ីងទឹងគួនបើង ដែលលើកទាហានម្នាក់ ៥០០ បង្កប់ទៅសង្ខាងផ្លូវនោះ ក៏អុជភ្លើងឆេះឡើងព្រមគ្នា ឯគួនអ៊ូដែលលើកទាហានទៅបង្កប់នៅពីក្រោយ ឃើញពន្លឺភ្លើងពីទិសទាំង ២ ដូច្នោះ ព្រោះកំឡាំងខ្យល់ព្យុះខ្លាំង ក៏ស្រែកហ៊ោលើកទាហានចេញមករុកបំពានចូលទៅ ទាហានហៃហ៊ូទុនក៏តក់ស្លុតទាំងអស់គ្នា តែបាក់បែកជាន់គ្នាស្លាប់ជាច្រឡំបល់ ខ្លះរត់ចេញពីភ្លើងមិនទាន់ ក៏ឆេះពេលស្លាប់ ពប់តែស្លាប់ក្នុងភ្លើងនោះច្រើនណាស់ ជូឡុងឃើញប៉ុនចំណាប់ ក៏ដេញទាហានត្រឡប់ចូលមកវិញ ហៃហ៊ូទុនថួសការនឹងមកតស៊ូវិញក៏មិនទាន់ ទើបរបសេះស្ទុះពារទំលាយថយ

ទៅ ឯលីទៀនដែលនាំស្បៀងជាកងក្រោយក្រឡេកឃើញគួនអ៊ូវាយខ្ទប់មកពីក្រោយក៏បានតស៊ូដាយូរណាស់ ប៉ុន្តែទ្រាំមិនបានក៏បរសេះថយរត់ទៅ ។

ហែហ៊ូមានទ័ពហាន់ហោ ដែលនៅក្នុងកងមុខក៏ញាក់សេះវិលត្រឡប់មកក្រោយ ប្រាថ្នានឹងជួយការពារស្បៀងឡុងតពីក្រុង ខ្ទួលឃើញទៀវហ៊ុយយកទួនបាក់ហែហ៊ូមានធ្លាក់ពីលើសេះស្លាប់ ហាន់ហោយល់ថានឹងតទល់ពុំបាន ក៏ញាក់សេះរត់ចេញទៅ ឯពលទាហានខាងឡេវពីក៏លើកគ្នាដេញចាក់កាប់សម្លាប់ទាហានហែហ៊ូទួន ក្នុងពេលយប់នោះឈាមហូរបែកពពុះពេញទាំងព្រៃផងវាល ខ្មោចក៏ស្លាប់ដួលដេកគ្រាលគរលើគ្នា មើលដូចគំនរកប៉េអុស លុះព្រឹកក្តីស្វាងហែហ៊ូទួនបានទាហានដែលនៅសល់ពីស្លាប់បែកទៅនោះ ក៏នាំគ្នាលើកត្រឡប់ទៅស្រុកហ្វូតោវិញ ឯគួនអ៊ូ, ទៀវហ៊ុយ, ជូឡុង លុះមានជ័យជំនះហែហ៊ូទួនដូច្នោះ ក៏នាំគ្នាកោតសរសើរគម្រោងប្រាជ្ញាខុងបេងថា ចេះរិះគិតប្រាកដពិតមែនហើយ ។

ឯខុងបេងលុះព្រឹកព្រាងស្វាងព្រះសុរិយា ក៏តែងខ្លួនយ៉ាងសុភាពឡើងជិះរទេះតូចទាប ១ ហើយនាំទាហានឲ្យរែកសែងតុតាំង និងគ្រឿងអាហារចេញមកតាមឡេវពី លុះឡេវពី, គួនអ៊ូ, ទៀវហ៊ុយ, ជូឡុង, លើកទ័ពត្រឡប់មកជួបនឹងខុងបេងកណ្តាលផ្លូវ ក៏មានសេចក្តីត្រេកអរ

សាទរណាស់ នាំគ្នាទាំងអស់ចូលទៅគំនាប់ខុងបេងៗ ក៏ឲ្យរៀបចំណីអាហារឲ្យបណ្តាពួកទាហាននោះបរិភោគទាំងអស់គ្នាជាទីសប្បាយ រួចក៏លើកត្រឡប់ចូលទៅក្នុងស្រុកស៊ិនអៀវិញ ។

---

## សាមកុកខ្សែ ៣៦

តាំងពីឡេវពីខុងបេងប្រឹក្សាគ្នា ហើយហៃហ៊ូទុនទៅដល់ចូឆូៗ លើកទោស គិតលើកទ័ពមកវាយឡេវពីទៀត ឡេវពីស្ដាប់ចូឆូលើកទ័ព ទៅវាយស្រុកស៊ិនអៀ ឡេវពីរត់ចេញទៅស្រុកស៊ិនយ៉ុង ។

---

ខុងបេងក៏និយាយនឹងឡេវពីថា លោកមានជ័យជំនះហៃហ៊ូទុនគ្រានេះ លោកកុំអាលត្រេកអរសប្បាយឡើយ ព្រោះខ្ញុំប៉ាន់ថា ចូឆូនឹងលើកទ័ពមកទៀត តបកំហឹងនឹងសងសឹកលោកវិញជាប្រាកដ ឡេវពីក៏សួរថាបើដូច្នោះ លោកនឹងត្រូវគិតប្រការម្ដេចទៅទៀត ខុងបេងថាដែលខ្ញុំរិះគិតតស៊ូនឹងចូឆូនោះ ក៏ល្មមនឹងកែខៃបានទេ តែមកឃើញថាស្រុកស៊ិនអៀនេះតូចចង្អៀតណាស់ នឹងគិតការពារបានដោយក្រឥឡូវឡេវប៉ៀវក៏ឈឺធ្ងន់ណាស់ទៅហើយ ដើមឡើយក៏បានអនុញ្ញាតទុកថានឹងឲ្យស្រុកកេងជីវមកលោក គ្រានេះបានបន្ទោរស្រួលហើយ បើប្រ

ប្រសិនជាលោកនឹងលើកទៅស្រុកកេនដ៍វគ្រានេះ   ទោះបីខ្ញុំនឹងលើកកងទ័ពមកយ៉ាងណា   ក៏នឹងបានរិះគិតការផ្លាស់ប្តូរតស៊ូច្បាំងបានយ៉ាងមាំ ព្រោះស្រុកកេនដ៍វនោះធំទូលាយស្រួលណាស់ ។

ឡេវ៉ីតបថា   លោកមានប្រសាសន៍នោះត្រូវហើយ   តែថាឡេវ៉ីបៀវមានឧបការនឹងខ្ញុំមកពីដើមជាច្រើន បើនឹងលើកទៅគ្រានេះ ក៏ដូចទៅដណ្តើមយកស្រុកគេនៅ ខុនបេនតបថា ដែលខ្ញុំជំរាបមកនេះ មិនមែនឲ្យលោកទៅធ្វើអាក្រក់ដល់ឡេវ៉ីបៀវនោះទេ   ព្រោះស្រុកកេនដ៍វមុខជានឹងបានមកលោកជាប្រាកដ ទោះបីលោកមិនលើកទៅតាមខ្ញុំជំរាប យូរទៅក៏នឹងមានអន្តរាយ កាលណាមានហេតុឡើង លោកទើបនឹងជ្រាបតាមការដែលខ្ញុំទុកជាពិត   ឡេវ៉ីថាទោះបីភ័យអន្តរាយមកដល់ខ្លួនយើងដោយប្រការម្តេចៗក្តី យើងក៏ស៊ូតែស្លាប់តាមកម្មផល ដែលនឹងទៅរំលងគុណគេនោះ មិនត្រូវសោះឡើយ   ខុនបេនតបថា ដែលលោកមិនពេញចិត្តនឹងធ្វើតាមខ្ញុំបាទ   ក៏តាមតែអធ្យាស្រ័យលោកចុះ  សូមខ្ញុំបាទនឹងរិះគិតប្រែប្រួលទៅទៀត ។

ឯហែហ្ស៊ីខុនលុះលើកពលទៅដល់ក្រុងហ្វូគោ   ក៏ចងខ្លួនឯងចូលទៅដល់ចូហ្វូដោយគំនាប់ថា   សូមទោសខ្ញុំបាទដល់នូវការសមគួរនាសជីវិត ហើយព្រោះខ្ញុំបាទមានសេចក្តីប្រមាទមិនបានដឹងកលឧបាយខុនបេន ទើបខាតបង់ពលរេហ៍ច្រើនតាំងម្ល៉េះ   កាលខ្ញុំបាទនឹងលើកចូលទៅនោះក៏បាន

សញ្ញាទុកថា បើមិនបានខ្លួនទៀតពី, ខ្ញុំបើនឹងមកជូនលោកទេ នឹងឲ្យលោកកាត់ក្បាលខ្ញុំបាទជំនួស ខ្លួនខ្ញុំបាទក៏ឃើញថាខុសមែនហើយ តាមតែលោកនឹងធ្វើទោសចុះ ។

ចូចូឃើញហែហ៊្វូទុនធ្វើទោសខ្លួនឯងដូច្នោះក៏នឹកគួរឲ្យមានចិត្តអាណិតណាស់ទើបឲ្យស្រាយចំណងដែលចងនោះចេញហើយថា ដែលអ្នកទៅធ្វើសង្គ្រាមឲ្យចួស់ការដល់សឹកសត្រូវដូច្នេះទោសអ្នកក៏ដល់ថ្នាក់ស្លាប់ តែថាខ្លួនអ្នកមានគុណ គាប់ធ្លាប់ធ្វើការសង្គ្រាមមកពីមុនជាច្រើន ទោសនេះយើងត្រូវលើកឲ្យរួចម្តងទៅចុះព្រោះធម្មតាជាតិទាហានធ្វើការសឹកសង្គ្រាមក៏មែនមានចាញ់មានឈ្នះផ្លាស់ទៀនដូច្នេះ ហែហ៊្វូទុនឮដូច្នោះក៏សោមនស្សរីករាយទទួលគំនាប់ហើយថា ខ្ញុំបាទលើកទ័ពទៅគ្រានេះអ៊ុគិមនឹងលីទៀនក៏បានរំពុកជាស់តឿនស្មារតីដែរ តែថាខ្ញុំបាទជាមនុស្សអប្រិយនឹងរូសប្រទូស្តយកតែតាមអំពើចិត្តឯង ទើបចួស់ការដូច្នេះ ព្រោះមើលងាយប្រមាទ ។

ចូចូឮដូច្នោះ ក៏ឲ្យបំណាច់រង្វាន់ដល់អ៊ុគិមនឹងលីទៀនជាច្រើនហើយថា សព្វថ្ងៃនេះ យើងមានសេចក្តីបរិវិតក្កណាស់ ព្រោះឡៅពីនឹងស៊ុនឃ្វួន ២ នាក់នេះមានកំឡាំងលើសលុប ក្រៅពីនេះយើងគ្មានព្រួយបារម្ភសោះ ឥឡូវនេះការសឹកសង្គ្រាមក៏បានធ្វើជាប់ដៃគ្នាមកហើយ នឹងគិតកំចាត់ឡៅពីនឹងស៊ុនឃ្វួនចេញឲ្យបាន ទើបផែនដីនឹងបានរាបទាបជាសុខតទៅ. គ្រា

នោះបូជូក៏ឲ្យគេណ្ហាប្រមូលពាហនបាន ៥០ ម៉ឺន តាំងឲ្យចោហ៊ិនទីង ចោហានលើកពល ១០ ម៉ឺនចេញទៅជាកងទ័ព១ ឲ្យទៀវលៀវ, ទៀវទាប លើកពល១០ម៉ឺនចេញទៅជាកងទី ២. ឲ្យហហ៊ូទុនទីងហៃហ៊ុអៀនលើកពល ១០ ម៉ឺនចេញទៅជាកងទី ៣, ឲ្យអ៊ុតឹមនីងលីទៀមលើកពល ១០ ម៉ឺនចេញទៅជាកងទី ៤, ឲ្យទៅទូលើកពល ៣ ពាន់ចេញទៅជាទ័ពស្រួចសម្រាប់ស៊ើបសួស្តាប់ការ ឯបូជូនោះលើកពល៦ម៉ឺនជាទ័ពហ្លួង ។

ខណៈកាលបូជូកំពុងគេណ្ហាកងទ័ពទីងលើកទៅ គ្រានោះព្រះចៅហៀនតេសោយរាជសម្បត្តិបាន ១៣ ឆ្នាំ ជារដូវខែស្រាពណ៍ ខាងទិស បានបក្សស្លុមឹងឲ្យលើកកងទ័ពចេញទៅ ទទួលខុងយ៉ុងចូលមកដំរបថា ដែលលោកទីងលើកកងទ័ពទៅកំចាត់ទៀតពីគ្រានេះ ទៀតក៏ជាពួកព្រះរាជវង្សព្រះចៅហៀនតេជាការមិនគួរសោះឡើយ ឯស៊ីនគូនទៀតសោតក៏បានតាំងគួមហានមានពាហនពលរេហ៍ជាចំនួន ហើយមានស្រុកចំណុះសម្រាប់ឯក ៦ មណ្ឌល ពលយោធាក៏ច្រើន ឯផ្លូវទីងទៅនោះក៏ឆ្ងាយដាច់ស្រយាល ដែលមហាទំបការជទីងលើកទៅគ្រានេះ ខ្លាចមិនបានកលការជាឱកាសល្អនឹងខូចខាតរេហ៍ពលជាច្រើន សូមឲ្យលោកត្រិះរិះគិត-មើលតាមគួរសិនចុះ ។

បូជូបានឮដូច្នោះក៏ឆ្លើយតបថា ដែលអ្នកមកឃាត់ឃើញ មិនឲ្យលើកទៅកំចាត់ទៀតពីទីងស៊ីនគូននោះមិនត្រូវសោះ ព្រោះមនុស្សទាំង២

នេះជាអកតញ្ញូអាក្រក់ណាស់ ថាហើយក៏បណ្តេញខុនយ៉ឺនចេញថា អ្នកឯងកុំមកចរចាដូច្នោះតទៅទៀត បើមិនស្តាប់យើងនឹងកាត់ក្បាលចេញ ខុនយ៉ឺនឃើញចុចចឹងបណ្តេញដូច្នោះ ក៏ក្រោកចេញទៅធុតហើយដកដង្ហើមធំថា មហាឧបាជនេះជាមនុស្សមិនតាំងនៅក្នុងសត្យសុចរិតសោះ បើខុចរ៉ៃតទៅធ្វើការប្រទូស្តអ្នកដែលត្រង់ល្អក៏គង់នឹងវិនាសទៅឯង ។

ខណៈនោះខុនស៊ីដែលជាទោសហារិក្នាទីងខុនយ៉ឺននោះ បានឮខុនយ៉ឺននិយាយដូច្នោះ ក៏យកសេចក្តីនោះទៅប្រាប់ចុចចុចថា ខុនយ៉ឺននោះជាមនុស្សមិនល្អសោះ លបនិយាយដើមពីលោកអាក្រក់ផ្សេងៗ ហើយកាលគ្រាយើងនឹងមើលងាយប្រមាថលោកនោះ ក៏ព្រោះខុនយ៉ឺនញុះញង់ឲ្យនិយាយ ចុចចុចឮដូច្នោះ ក៏ចូលចិត្តជឿមានសេចក្តីខឹងក្តៅណាស់ ទើបប្រើឲ្យទាហានទៅចាប់ខ្លួនខុនយ៉ឺនប្រហារជីវិត មនុស្សស្និទ្ធរបស់ខុនយ៉ឺនឃើញដូច្នោះ ក៏រត់ទៅប្រាប់ដល់បុត្រខុនយ៉ឺនទាំង ២ នាក់ថា ឥឡូវមហាឧបាជចាប់យកបិតាអ្នកទៅសម្លាប់ហើយ ហេតុម្តេចអ្នកនៅលង់បារាស្តាព្រងើយដូច្នេះ មិនខ្លាចស្លាប់ទេឬ បានជាមិនគិតរត់ចេញ ? បុត្រខុនយ៉ឺនទាំង ២ នាក់ឆ្លើយតបថា ដែលអ្នកអាណិតនាំដំណឹងមកឲ្យយើងដឹងដូច្នេះ ជាគុណគាប់របស់អ្នកជាទម្ងន់ខ្លាំងណាស់ តែជាធម្មតាសត្វបក្សីទាំងពួង ដែលសំពលពងមកនៅក្នុងសំបុកហើយ

(មានត)

ផ្នែកគាំណាត់និងប្រវត្តិការណ៍

# គណៈប្រតិភូខ្មែរខាងសាសនា
# ទៅរួមក្នុងពិធីបុណ្យ ព. ស. ២៥០០ នៅប្រទេសជប៉ុន
# គឺពីដំណើរដែលបានជួនពីថ្ងៃមុន

---

កាលពីខែមេសាមុននេះ ព្រះរាជរដ្ឋាភិបាលបានចាត់គណៈប្រតិភូ ១ ឲ្យទៅរួមក្នុងពិធីបុណ្យ ព. ស. ២៥០០ នៅប្រទេសជប៉ុន, គណៈប្រតិភូនេះ បានត្រឡប់មកវិញហើយ ក្រោយដែលបានធ្វើបុណ្យនោះរួចស្រេច ។

មុននឹងចេញដំណើរត្រឡប់មកកាន់ប្រទេសកម្ពុជាវិញ, លោក យឿន- ចឹម ប្រធានគណៈប្រតិភូខ្មែរ បានធ្វើសេចក្ដីថ្លែងការណ៍មួយ ជូនដល់ស្ថានឯកអគ្គរាជទូតខ្មែរ សុំឲ្យចុះផ្សាយតាមសារព័ត៌មាននានានៅក្រុងតូក្យូ មានសេចក្ដីដូចតទៅនេះ ៖

យើងជាគណៈប្រតិភូខ្មែរ ដែលព្រះរាជរដ្ឋាភិបាលយើងបានចាត់មក ដើម្បីជាតំណាងប្រទេសខ្មែរ ក្នុងពិធីបុណ្យ “ពុទ្ធជយន្តិ” នៅប្រទេសជប៉ុន យើងមានសេចក្ដីសោមនស្សរីករាយជាទីបំផុត ដោយបានមករួមប្រជុំក្នុងពិធីបុណ្យពុទ្ធសាសនាដ៏អធិកអធិកនេះ ដែលចាប់ធ្វើនៅក្រុងតូក្យូពីថ្ងៃទី ២៧ ទៅទល់នឹងថ្ងៃទី ៣១ ខែមីនា ១៩៥៩ ហើយ

នៅទីក្រុងនានា ក្នុងប្រទេសជប៉ុនពីថ្ងៃទី ១ ទៅទល់នឹងថ្ងៃទី ៩ ខែមេសា ១៩៥៩ ។

ការដែលចាត់គណៈប្រតិភូ ឲ្យនាំនូវការប្រស្រ័យជាគាគរគោព របស់ព្រះមហាក្សត្រយើងទាំងពីរព្រះអង្គ, របស់ព្រះរាជរដ្ឋាភិបាល និងរបស់ប្រជារាស្ត្រខ្មែរ ព្រមទាំងសេចក្ដីគោរពដ៏ជ្រាលជ្រៅរបស់ពុទ្ធសាសនិកជនខ្មែរ មកកាន់ពិធីបុណ្យយ៉ាងមហោឡារិកនេះ, គេអាចសំគាល់ថា ប្រទេសកម្ពុជាបានយល់ច្បាស់នូវតម្លៃយ៉ាងខ្ពស់បំផុតនៃមហាសន្និបាតរំលឹកដល់ ព.ស.២៥០០ ហើយគេអាចសំគាល់ទៀតថា ប្រទេសកម្ពុជាទាំងមូលបានចូលរួម ដោយស្មោះចំពោះទាំងចិត្តទាំងកាយជាមួយនឹងអ្នកដែលប្រតិបត្តិតាមពុទ្ធវចនទាំងអម្បាលម៉ាននោះ ។

ម្យ៉ាងទៀត ដោយសារការអញ្ជើញពីគណៈកម្មការបុណ្យទាំងនោះ, គេអាចទុកពេលនេះ ជាឱកាសមួយយ៉ាងថ្លៃថ្លាបំផុត ហុចមកដល់យើងពល់គ្នាជាតំណាងប្រទេសនានាបែកពាងអាស៊ី ឲ្យយើងបានមកជួបជុំគ្នានៅក្នុងប្រទេសជប៉ុន មិនត្រឹមតែធ្វើសក្ការៈបូជានឹងស្ដាប់ជាមួយជនជាតិជប៉ុន នូវពុទ្ធវចនដែលព្រះបរមគ្រូបានប្រៀនប្រដៅទុកមកចំនួន ២៥០០ឆ្នាំហើយប៉ុណ្ណោះទេ គឺថែមទាំងជាឱកាសមួយនាំឲ្យយើងកើតបំណងមិត្តភាពនិងសហការខាងសាសនា ដើម្បីជាប្រយោជន៍ដល់ប្រជារាស្ត្រនៃប្រទេសនានារបស់យើងពល់គ្នាទៀតផង ។

ពិធីបុណ្យ « ពុទ្ធជយន្តិ » នៅប្រទេសជប៉ុន ដែលបានតាក់តែងធ្វើឡើងយ៉ាងសមរម្យនោះ, គួរទុកជាព្រឹត្តិការណ៍មួយយ៉ាងធំនៅក្នុងប្រវត្តិសាស្ត្ររបស់ពុទ្ធពិភពលោក ។

យើងជាគណៈប្រតិភូខ្មែរ បានទៅចូលរួមគ្រប់របៀបពិធីដែលគេបានរៀបចំធ្វើនៅទីក្រុងតូក្យូ និងទីក្រុងនានាក្នុងប្រទេសជប៉ុន ដូចជាទីក្រុងតូក្យូ, ណារ៉ា, អូសាកា, ណាគោយ៉ា និងអ៊ីសីកាវ៉ា ដោយគម្រោងពិធីច្រើនញឹកញាប់បំផុត ។

យើងបានសំគាល់ឃើញថា ធម៌ព្រះពុទ្ធនៅប្រទេសជប៉ុន គេបានថែរក្សាយ៉ាងខ្ជាប់ខ្ជួន ឲ្យនៅរស់រវើក តាមប្រពៃណីប្រទេសរបស់គេ ។

យើងមានសេចក្តីពេញចិត្ត និងមានសេចក្តីកោតសរសើរ ជាជ្រាលជ្រៅបំផុត ចំពោះពិធីផ្សេងៗ ដែលគេបានតុបតែងធ្វើទាំងអម្បាលម៉ាន ។

គ្រប់ទីក្រុងកន្លែង ដែលយើងជាគណៈប្រតិភូនានាបានទៅកាន់ទាំងប៉ុន្មាននោះ, យើងបានទទួលនូវបដិសន្ធារកិច្ចយ៉ាងជិតស្និទ្ធជាទីបំផុត អំពីគណៈកម្មាធិការបុណ្យ, អំពីព្រះសង្ឃនិងគ្រហស្ថ, អំពីសាធារណជនជាតិជប៉ុន ដែលជាមិត្រយើង, ក្រៅពីនេះមានបដិសន្ធារកិច្ចយ៉ាងធំៗទៀត ដែលវរជននៅទីក្រុងតូក្យូ បានរៀបចំជាកិត្តិយសដល់យើងរាល់គ្នា ។

យើងសូមថ្លែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ចំពោះការអញ្ជើញជាមិត្តភាពតាំងអម្បាលម៉ាននោះ ហើយនឹងអំណរគុណយ៉ាងក្រៃលែងចំពោះបដិសន្ថារកិច្ច ដែលគេបានធ្វើចំពោះយើងគ្រប់ទីកន្លែង, យើងសូមសំដែងនូវគារវភាពចំពោះជនទាំងអស់ ដែលមានភ័ក្តិសំណាងបានទៅប្រួមក្នុងពិធីបុណ្យពុទ្ធជយន្តិនេះ ។

ទៅទីអវសាន, យើងសូមប្រសិទ្ធិពរសព្វសាធុការយ៉ាងស្មោះស្ម័គ្រ ដើម្បីសេចក្ដីសុខចំរើនដល់ប្រជាករទូទៅ, ដើម្បីមហិទ្ធិឫទ្ធិដល់មហាប្រទេសជប៉ុន ទ័ង ដើម្បីសន្តិភាពដល់ពិភពលោក !

ធ្វើនៅក្រុងតូក្យូ, នៅថ្ងៃទី ៩ មេសា ១៩៥៩

ហត្ថលេខា : យឿន-ប៉ឹម

ប្រធានគណៈប្រតិភូខ្មែរនៃពិធីពុទ្ធជយន្តិប្រទេសជប៉ុន

## លទ្ធផលនៃការរួមប្រជុំ

ការរួមប្រជុំអ្នកតំណាង
ប្រទេសបើកខាងពុទ្ធសាសនា
នៅស្រុកជប៉ុនពេលនេះណា៎
ឃើញថាចម្រើនសន្តិធម៌ !

ចាប·ពិន

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អជិគីប គុ. ដែលមិនលោភ ។

អជិត គុ. ដែលមិនឈ្នះ, ដែលចាញ់; ពុំ. ព្រះវិស្ណុ ។ – *ត្វតា* ស្ត្រី. ភាពនៃទាសៈដ៏ម្ចាស់មិនតឹងរ៉ឹង, ភាពនៃទាសៈដ៏ម្ចាស់បណ្ដែតបណ្ដោយឲ្យ ។ *អជិតាត្មន* គុ. ដែលមានអាត្មាចាញ់ហើយ ។ *អជិតេន្ទ្រិយ* គុ. ដែលមានឥន្ទ្រិយចាញ់ហើយ ។

អជិន នបុំ. ស្បែក ( ម្រឹគខ្មៅ ): ស្បែក, ស្បែកសត្វម្រឹគ; ហិបស្បែក ។ *អជិនាវ៌តិន* គុ. ដែលស្លៀកពាក់ស្បែក ។ – *វត្ត* នបុំ. ទៃក្លែកវិសេស ។ – *វាសស៏* គុ. ដែលស្លៀកពាក់ស្បែក ។

អជិរ នបុំ. អង្គន,ធ្លា ( មុខគេហដ្ឋាន ,សង្វៀន; សមរភូមិ ។ – *វតី* ស្ត្រី. ដៃទន្លេគង្គា ។

អជិហ្ម គុ. ដែលមិនកោង,ត្រង់ ។ – *គ* គុ. ដែលទៅត្រង់; ពុំ. ត្រី; ព្រួញ; សរ ។ – *ចារិន* គុ. ដែលប្រព្រឹត្តត្រង់រ៉ែង។ – *គប* គុ. ដែលមិនមានពុតអាក្រក់និងមិនលាក់ពុត, ដែលមិនមានពុតឡេត ។

អជិហ្វ គុ. ដែលមិនមានអណ្ដាត ។

អជីគត៌ ពុំ. នាមឫសី ។

(នៅមានត)